# វិទ្យាល័យ ព្រះស៊ីសុវត្ថិ
## សាលារៀនជំនាន់ថ្មី

# សំណួរតេស្តគំរូនៃកម្មវិធីអន្តរជាតិ(PISA)
## ស្តីពីរង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស
## ផ្នែកវិទ្យាសាស្ត្រ

# ជីវវិទ្យា ថ្នាក់ទី ៧



## ២០២៦


រៀបចំដោយ

វិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី

# គណៈកម្មការ

## គណៈកម្មការគ្រប់គ្រង

លោក សម្ប កំសាន្ត

លោក ហួត សៀងហៃ

លោកស្រី ឈិត ស្រីរ័ត្ន

លោក ពេញ ចំរើន

លោក ឌួង រតនា

## គណៈកម្មការរៀបរៀង

លោក ចាន់ធី អូរទី

## គណៈកម្មការត្រួតពិនិត្យ

➢ **គណៈកម្មការពិនិត្យនិងកែលម្អខ្លឹមសារ**

| | | | | | |
|---|---|---|---|---|---|
| លោក | ហៀង សេងហួយ | លោកស្រី | សំអុល ច័ន្ទសិលា | លោកស្រី | ប៉ាន់ សុខេម |
| កញ្ញា | ទុយ វន្នី | កញ្ញា | យាង ស្រីណែត | កញ្ញា | កាំង សាំងលីន |

➢ **គណៈកម្មការទទួលបន្ទុកផ្នែកPISAនៅសាលារៀនជំនាន់ថ្មី**

| | | | | | |
|---|---|---|---|---|---|
| លោក | ផូ មករា | លោក | សាន សុខលី | លោក | កុយ សុវត្ថារិទ្ធ |
| លោកស្រី | ជ្រិន វិច្ឆិកា | លោក | ជា វិចិត្រ | លោកស្រី | រុន វួចនា |
| លោក | ហុង សុវណ្ណមករា | លោក | សាន់ ប៊ុនណាត | លោក | ថៃ ប៊ុនថៃ |
| លោកស្រី | វណ្ណ ជារ៉ា | លោកស្រី | កប គន្ធា | លោកស្រី | នៅ ធយី |
| លោក | ស្រ៊ិន ចិត្រា | លោកស្រី | រ៉ា រំភួន | លោក | មិន សំណាង |

**ផលិតដោយ**

វិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី

**បោះពុម្ពលើកទី១**

**២០២៦**

**©រក្សាសិទ្ធគ្រប់យ៉ាង**

# អារម្ភកថា

ក្នុងបរិបទនៃបដិវត្តន៍ចំណេះដឹង និងបច្ចេកវិទ្យា វិទ្យាសាស្ត្រមិនមែនត្រឹមតែជាមេរៀននៅក្នុងសៀវភៅសម្រាប់ទន្ទេញចាំប៉ុណ្ណោះទេ ប៉ុន្តែគឺជាឧបករណ៍ដ៏មានអានុភាពសម្រាប់ដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ សៀវភៅ **«វិញ្ញាសាតេស្តសមត្ថភាពវិទ្យាសាស្ត្រ(ជីវវិទ្យា)-PISA Test ថ្នាក់ទី ៧»** នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពសិស្សានុសិស្ស មិនត្រឹមតែឱ្យចងចាំមេរៀន ប៉ុន្តែឱ្យចេះវិភាគ បកស្រាយ និងអនុវត្តចំណេះដឹងវិទ្យាសាស្ត្រទៅក្នុងស្ថានភាពជាក់ស្តែង។

ខ្លឹមសារនៅក្នុងសៀវភៅនេះ ត្រូវបានចងក្រងយ៉ាងសម្រិតសម្រាំង ដោយផ្អែកលើកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា រួមផ្សំជាមួយវិធីសាស្ត្រវាយតម្លៃកម្រិតអន្តរជាតិ (PISA)។ យើងបានផ្តោតលើចំណុចសំខាន់ៗចំនួន ៣ គឺ៖

១. **ការផ្សារភ្ជាប់ចំណេះដឹងជាមួយជីវិត៖** សំណួរនីមួយៗត្រូវបានរៀបចំឡើងតាមរយៈស្ថានភាពជាក់ស្តែងដូចជា ការរំលាយអាហារក្នុងរាងកាយ ផលប៉ះពាល់នៃគ្រឿងស្រវឹង និងអនាម័យមាត់ធ្មេញ ដែលជួយឱ្យសិស្សមើលឃើញពីតម្លៃនៃមេរៀនដែលពួកគេកំពុងរៀន។

២. **ការបណ្តុះបំណិនវិភាគ៖** ជាជាងការស្វែរកចម្លើយដែលត្រឹមត្រូវតែមួយមុខ វិញ្ញាសានេះតម្រូវឱ្យសិស្សចេះពន្យល់ពី "ហេតុផលវិទ្យាសាស្ត្រ" និងព្យាករណ៍ពីផលវិបាកដែលកើតមានចំពោះសុខភាព និងបរិស្ថាន។

៣. **ការត្រៀមខ្លួនសម្រាប់អនាគត៖** ការបង្កើនសមត្ថភាពដោះស្រាយបញ្ហា និងការគិតបែបបែបស៊ីជម្រៅ គឺជាគ្រឹះដ៏សំខាន់សម្រាប់សិស្សានុសិស្សក្នុងការបន្តការសិក្សាទៅកម្រិតឧត្តមសិក្សា និងការសម្រេចចិត្តប្រកបដោយបញ្ញាញាណក្នុងនាមជាពលរដ្ឋសកល។

យើងសង្ឃឹមយ៉ាងមុតមាំថា សៀវភៅវិញ្ញាសានេះនឹងក្លាយជាជំនួយស្មារតីដ៏មានតម្លៃសម្រាប់លោកគ្រូ អ្នកគ្រូ ក្នុងការច្នៃប្រឌិតវិធីសាស្ត្របង្រៀន និងជាត្រីវិស័យសម្រាប់សិស្សានុសិស្សក្នុងការរុករកពិភពវិទ្យាសាស្ត្រដ៏អស្ចារ្យ។ សុខភាពមាំមួន និងសតិបញ្ញាឈ្លាសវៃ គឺផ្តើមចេញពីការយល់ដឹងពីធម្មជាតិ និងដំណើរការនៃរាងកាយយើងផ្ទាល់។

សូមជូនពរលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ ទទួលបានជោគជ័យ និងភាពរីករាយក្នុងការសិក្សារៀនសូត្រ!

# របៀបប្រើប្រាស់សៀវភៅវិញ្ញាសា

ដើម្បីឱ្យការសិក្សារបស់អ្នកមានប្រសិទ្ធភាព និងភាពរីករាយ សូមអនុវត្តតាមជំហានណែនាំដូចខាងក្រោម៖

**១. អានអត្ថបទខ្លី**

មុននឹងឆ្លើយសំណួរ អ្នកត្រូវអានអត្ថបទខ្លី ឬស្ថានភាព ដែលនៅដើមមេរៀននីមួយៗឱ្យបានច្បាស់លាស់។ ក្នុងវិញ្ញាសា PISA ចម្លើយភាគច្រើន ឬតម្រុយសំខាន់ៗ ត្រូវបានបង្កប់នៅក្នុងអត្ថបទទាំងនោះ។

**២. សង្កេតរូបភាព និងដ្យាក្រាម**

រូបភាពនៅក្នុងសៀវភៅនេះមិនមែនសម្រាប់តែលម្អទេ ប៉ុន្តែវាជាប្រភពព័ត៌មាន។ ចូរពិនិត្យមើលស្លាកឈ្មោះសរីរាង្គ ចលនានៃព្រួញ និងដ្យាក្រាមនៃដំណើរការផ្សេងៗ ព្រោះវាជួយអ្នកឱ្យយល់ពីលំនាំជីវវិទ្យាកាន់តែស៊ីជម្រៅ។

**៣. យល់ដឹងពីទម្រង់សំណួរ**

សៀវភៅនេះមានទម្រង់សំណួរចម្រុះដើម្បីវាស់ស្ទង់សមត្ថភាពអ្នក៖

- **ពហុជ្រើសរើស៖** ជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុតតែមួយ (ឬច្រើនតាមការណែនាំ)។
- **ផ្គូផ្គង៖** ភ្ជាប់ទំនាក់ទំនងរវាងសរីរាង្គ និងមុខងារ ឬរោគសញ្ញា និងជំងឺ។
- **ចម្លើយឆ្លាស់ (ត្រូវ / ខុស)៖** ពិចារណាលើសេចក្តីថ្លែងការណ៍នីមួយៗឱ្យបានហ្មត់ចត់។
- **សំណួរបើក ៖** ជាផ្នែកសំខាន់បំផុតដែលតម្រូវឱ្យអ្នកសរសេរបកស្រាយដោយប្រើហេតុផលវិទ្យាសាស្ត្រ និងចំណេះដឹងដែលបានរៀន។

**៤. ពិនិត្យតារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

នៅក្រោមសំណួរនីមួយៗ មានតារាងបញ្ជាក់ពី «**កម្រិតសមត្ថភាព**» និង «**លទ្ធផលសិក្សា**»។ វាជួយឱ្យអ្នកដឹងថា តើសំណួរនោះចង់វាស់ស្ទង់ការចងចាំ ការយល់ដឹង ឬការវិភាគរបស់អ្នក។

**៥. ការប្រើប្រាស់អត្រាកំណែ**

បន្ទាប់ពីធ្វើវិញ្ញាសារួច ចូរប្រើប្រាស់អត្រាកំណែនៅផ្នែកខាងក្រោយដើម្បីផ្ទៀងផ្ទាត់។ ចំពោះសំណួរបើក (កម្រិតខ្ពស់) កុំគ្រាន់តែមើលចម្លើយត្រូវ ប៉ុន្តែត្រូវរៀនពី «របៀបបកស្រាយ» ដើម្បីទទួលបានពិន្ទុពេញ ។

**គន្លឹះពិសេស៖** កុំខ្លាចក្នុងការឆ្លើយខុស! វិទ្យាសាស្ត្រគឺជាការរុករក។ ការយល់ពីមូលហេតុដែលយើងឆ្លើយខុស នឹងធ្វើឱ្យយើងកាន់តែឆ្លាតវៃ និងចងចាំបានយូរអង្វែង។

# មាតិកា

**ជំពូកទី១ បរិស្ថានធម្មជាតិ** ........ 1

**មេរៀនទី១ ភាវៈរស់ និងបរិស្ថានរបស់វា** ........ **1**

ប្រធានបទទី ១ : សួនបន្លែសាលារៀន ........ 1

ប្រធានបទទី ៣ : ការរៀបចំអាងចិញ្ចឹមត្រី ........ 11

ប្រធានបទទី៤ : ទំនាក់ទំនងរវាងភាវៈរស់ ........ 17

**ជំពូកទី២ រុក្ខជាតិ** ........ 22

**មេរៀនទី១ រុក្ខជាតិឥតផ្កា : ប៉ប្រេក** ........ **22**

ប្រធានបទទី ៥ : អាចំកំបាំងក្រោមស្លឹកប៉ប្រេក ........ 22

**មេរៀនទី២ រុក្ខជាតិមានផ្កា** ........ **27**

ប្រធានបទទី ៦ : ការសិក្សានៅសួនដំណាំ ........ 27

ប្រធានបទទី ៧ : ពិសោធន៍លើការបង្កកំណើតរបស់ផ្កា ........ 32

**ជំពូកទី៣ កោសិកា** ........ 37

**មេរៀនទី១ រូបផ្តុំកោសិកា** ........ **37**

ប្រធានបទទី ៨ : បច្ចេកវិទ្យាវិទ្យាសាស្ត្រ និងការលូតលាស់នៃភាវៈរស់ ........ 37

ប្រធានបទទី ៩ : កោសិកា - ឯកតាគ្រឹះនៃជីវិត ........ 42

**មេរៀនទី២ កោសិការុក្ខជាតិ** ........ **47**

ប្រធានបទទី ១០ : ថាមពលពណ៌បៃតង និងរូបផ្តុំកោសិកា ........ 47

ប្រធានបទទី ១១ : ភាពខុសប្លែកនៃពណ៌ និងរូបផ្តុំកោសិការុក្ខជាតិ ........ 52

ប្រធានបទ ទី១២ : រុក្ខជាតិ និងតុល្យភាពនៃជីវិត ........ 57

**មេរៀនទី៣ រូបផ្តុំសារពាង្គកាយមនុស្ស** ........ **62**

ប្រធានបទទី ១៣ : ឋានានុក្រមនៃរូបផ្តុំសារពាង្គកាយមនុស្ស ........ 62

ប្រធានបទទី ១៤ : បណ្តាញជាលិកា និងដំណើរការនៃជីវិត ........ 67

ប្រធានបទទី ១៥ : តុល្យភាពនៃប្រព័ន្ធសរីរាង្គក្នុងរាងកាយមនុស្ស ........ 72

ប្រធានបទទី ១៦ : ទំនាក់ទំនង និងការសហការនៃសរីរាង្គមនុស្ស ........ 77
**ជំពូកទី៤ ការរំលាយអាហារ** ........ 82
**មេរៀនទី១ រូបផ្តុំប្រដាប់រំលាយអាហារ** ........ **82**
ប្រធានបទទី ១៧ : ដំណើរផ្លាស់ប្តូរនៃអាហារក្នុងរាងកាយ ........ 82
**មេរៀនទី២ ផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារ** ........ **87**
ប្រធានបទទី ១៨ : ធ្មេញ និងយន្តការកិនបំបែកអាហារ ........ 87
ប្រធានបទ ទី២០ : ក្រពេញរំលាយអាហារ - រោងចក្រផលិតសារធាតុរាវជីវសាស្រ្ត ........ 97
ប្រធានបទ ទី២១ : យន្តការទ្វេដងនៃការរំលាយអាហារ ........ 102
ប្រធានបទទី ២២ : សារធាតុចិញ្ចឹម និងកន្រ្តៃជីវសាស្រ្តអង់ស៊ីម ........ 107
**មេរៀនទី៣ ការរំលាយអាហារ** ........ **112**
ប្រធានបទទី ២៣ : ខ្សែសង្វាក់គីមី និងមេកានិចនៃដំណើរការរំលាយអាហារ ........ 112
ប្រធានបទទី ២៤ : សម្រូបអាហារ និងខ្សែច្រវាក់ចែកចាយសារធាតុចិញ្ចឹម ........ 117
**មេរៀនទី៤ ជំងឺ និងអនាម័យប្រដាប់រំលាយអាហារ** ........ **122**
ប្រធានបទទី ២៥ : អនាម័យមាត់ធ្មេញ និងសុខភាពប្រដាប់រំលាយអាហារ ........ 122
ប្រធានបទទី ២៦ : ទម្លាប់បរិភោគ និងសុខភាពប្រព័ន្ធរំលាយអាហារ ........ 127
ប្រធានបទទី ២៨ : តុល្យភាពអាហារូបត្ថម្ភ និងសុខភាពរាងកាយ ........ 138
**ជំពូកទី៥ អាល់កុល និងថ្នាំជក់** ........ 143
**មេរៀនទី១ ថ្នាំ** ........ **143**
ប្រធានបទទី ២៩ : ថ្នាំ និងឥទ្ធិពលនៃគ្រឿងញៀនលើរាងកាយ ........ 143
ប្រធានបទទី ៣០ : ឱសថ និងខែលការពារសុខភាព ........ 149
ប្រធានបទទី ៣១ : សុវត្ថិភាពឱសថ និងមាគ៌ានៃការស្រូបចូលក្នុងរាងកាយ ........ 154
**មេរៀនទី២ ថ្នាំជក់ និងបារី** ........ **159**
ប្រធានបទទី ៣២ : ថ្នាំជក់ - ឃាតករលាក់មុខ និងមហន្តរាយសុខភាព ........ 159
ប្រធានបទទី ៣៣ : ការជក់បារីអកម្ម ........ 164
ប្រធានបទទី ៣៤ : យុទ្ធសាស្រ្តឈ្នះផ្សែងបារី និងការកសាងសង្គមមានសុខភាពល្អ ........ 169

**មេរៀនទី៣ អាល់កុល និងថ្នាំជក់........................................................................ 174**

ប្រធានបទទី ៣៥ : គ្រឿងស្រវឹង - ឧបសគ្គនៃប្រព័ន្ធប្រសាទ និងសុខភាពរាងកាយ .................. 174

ប្រធានបទ ទី៣៦ : ឥទ្ធិពលគ្រឿងស្រវឹងលើរាងកាយស្ត្រី និងសុខភាពគភ៌ ............................... 180

ប្រធានបទទី ៣៧ : មាគ៌ាឆ្ពោះទៅរកការផ្តាច់គ្រឿងស្រវឹង និងការស្តារកម្លាំងចិត្ត....................... 185

# ជំពូកទី១ បរិស្ថានធម្មជាតិ

## មេរៀនទី១ ភាវៈរស់ និងបរិស្ថានរបស់វា

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ១ : សួនបន្លែសាលារៀន

អត្ថបទខ្លី : សួនបន្លែសាលារៀន



នៅសាលារៀនមួយ ក្រុមសិស្សថ្នាក់ទី ៧ បានសហការគ្នាបង្កើតសួនបន្លែមួយនៅក្រោយអគារសិក្សា។

- ពួកគេបានដាំ **ដើមស្ពៃ** និង **កូនត្រប់**។
- ដើម្បីឱ្យដំណាំលូតលាស់ សិស្សបានជីក **ដី** ពីទន្លេដាក់បន្ថែម និងស្រោច **ទឹក** ជាប្រចាំរាល់ព្រឹក។
- ពីរអាទិត្យក្រោយមក គេសង្កេតឃើញមាន **ដង្កូវ** មកស៊ីស្លឹកស្ពៃ ហើយមាន **សត្វចាប** ហើរមកចឹកដង្កូវស៊ីជាអាហារ។
- នៅគល់ដំណាំ មាន **ផ្សិត** តូចៗដុះលើស្លឹកឈើងាប់ៗដែលរលួយ។

### សំណួរទី ១៖ ធាតុផ្សំនៃបរិស្ថាន

នៅក្នុងសួនបន្លែខាងលើ មានទាំងធាតុផ្សំមានជីវិត និងគ្មានជីវិត។ ចូរគូសសញ្ញា ☑ ក្នុងប្រអប់ "មានជីវិត" ឬ "គ្មានជីវិត" ចំពោះវត្ថុខាងក្រោមឱ្យបានត្រឹមត្រូវ៖

| ឈ្មោះវត្ថុ/ភាវៈ | មានជីវិត | គ្មានជីវិត |
|---|---|---|
| ១. ដី | ☐ | ☐ |
| ២. ផ្សិត | ☐ | ☐ |
| ៣. ទឹក | ☐ | ☐ |
| ៤. ដើមស្ពៃ | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់និងបែងចែករវាងភាវៈមានជីវិត និងភាវៈគ្មានជីវិតនៅក្នុងស្ថានប្រព័ន្ធមួយ |
| កម្រិតពុទ្ធិ | ចងចាំ និងយល់ដឹង |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ តួនាទីក្នុងស្ថានប្រព័ន្ធ

យោងតាមអត្ថបទមេរៀន សារពាង្គកាយត្រូវបានបែងចែកជា ៣ ក្រុមគឺ៖ ស្វ័យជីព (អ្នកផលិត), បរជីព (អ្នកស៊ី), និង អ្នកបំបែក។

តើសារពាង្គកាយខាងក្រោម មានតួនាទីអ្វីនៅក្នុងសួនបន្លែនេះ? ចូរជ្រើសរើសចម្លើយ ត្រឹមត្រូវ។

**១. ដើមស្ពៃ គឺជា...**

☐A. ស្វ័យជីព ☐B. បរជីព ☐C. អ្នកបំបែក

**២. ដង្កូវ គឺជា...**

☐A. ស្វ័យជីព ☐B. បរជីព ☐C. អ្នកបំបែក

**៣. ផ្សិត គឺជា...**

☐A. ស្វ័យជីព ☐B. បរជីព ☐C. អ្នកបំបែក

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់តួនាទីរបស់សារពាង្គកាយ (អ្នកផលិត, អ្នកស៊ី, អ្នកបំបែក) ក្នុងស្ថានប្រព័ន្ធ។ |
| កម្រិតពុទ្ធិ | អនុវត្តន៍ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ពពួក និង សហគមន៍

សិស្សម្នាក់បានរាប់ចំនួនដើមស្ពៃទាំងអស់នៅក្នុងសួន ហើយកត់ត្រាថា "មានដើមស្ពៃចំនួន ៥០ ដើម កំពុងលូតលាស់ក្នុងរងតែមួយ"។ តើក្រុមដើមស្ពៃទាំង ៥០ ដើមនេះ ហៅថាអ្វី?

☐A. ស្ថានប្រព័ន្ធ ☐B. សហគមន៍ ☐C. ពពួក ☐D. លំនៅឋាន

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកភាពខុសគ្នារវាង "ពពួក" និង "សហគមន៍"។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ប្រភេទស្ថានប្រព័ន្ធ

សួនបន្លែនេះត្រូវបានចាត់ទុកថាជា "ស្ថានប្រព័ន្ធច្នៃប្រឌិត"។ តើចំណុចមួយណាខាងក្រោម ដែលជាហេតុផលសំខាន់បំផុតបញ្ជាក់ថាវាជាស្ថានប្រព័ន្ធច្នៃប្រឌិត?

☐A. វាមានពន្លឺព្រះអាទិត្យ និងដីសម្រាប់រុក្ខជាតិលូតលាស់។

☐B. វាមានសត្វល្អិត និងសត្វចាបរស់នៅជាមួយគ្នា។

☐C. វាត្រូវបានបង្កើតឡើង និងថែទាំដោយមនុស្ស (សិស្សស្រោចទឹក និងដាក់ជី)។

☐D. វាមានរុក្ខជាតិពណ៌បៃតងដែលអាចធ្វើរស្មីសំយោគបាន។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ពន្យល់ពីលក្ខណៈសម្គាល់នៃស្ថានប្រព័ន្ធច្នៃប្រឌិតធៀបនឹងធម្មជាតិ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការប្រែប្រួលក្នុងស្ថានប្រព័ន្ធ

ឧបមាថាសាលារៀនបានបាញ់ថ្នាំសម្លាប់សត្វល្អិត ដែលធ្វើឱ្យ ដង្កូវទាំងអស់ស្លាប់។ តើនឹងមានផលប៉ះពាល់អ្វីកើតឡើងចំពោះ ដើមស្ពៃ និង សត្វចាប? សូមសរសេរការព្យាករណ៍របស់អ្នក និងពន្យល់មូលហេតុ។

១. ចំពោះដើមស្ពៃ៖ ..........................................................................................

..........................................................................................

..........................................................................................

២. ចំពោះសត្វចាប៖ ..........................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគ និងព្យាករណ៍ពីផលប៉ះពាល់នៃការផ្លាស់ប្តូរកត្តាមួយនៅក្នុងខ្សែអាហារ។ |
| កម្រិតពុទ្ធិ | បង្កើតថ្មី និងវាយតម្លៃ |
| ទម្រង់សំណួរ | សំណួរទ្រង់បើក( ចម្លើយវែង ) |
| កម្រិតសមត្ថភាព | កម្រិត ៤ |

# អត្រាកំណែ

**សំណួរទី ១៖**

- **ចម្លើយត្រូវ៖**
  - ១.គ្មានជីវិត
  - ២.មានជីវិត
  - ៣.គ្មានជីវិត
  - ៤.មានជីវិត
  - *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុ។*

**សំណួរទី ២៖**

- **ចម្លើយត្រូវ៖**
  - ១.A (ស្វ័យជីព)
  - ២.B (បរជីព)
  - ៣.C (អ្នកបំបែក)-

**សំណួរទី ៣៖**

- **ចម្លើយត្រូវ៖**
  - C. ពពួក
  - ***ហេតុផល:*** ព្រោះវាជាក្រុមសារពាង្គកាយប្រភេទដូចគ្នា(ស្ពែដូចគ្នា)រស់នៅកន្លែងតែមួយ

**សំណួរទី ៤៖**

- **ចម្លើយត្រូវ៖** C. វាត្រូវបានបង្កើតឡើង និងថែទាំដោយមនុស្ស។

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយបានត្រឹមត្រូវទាំងពីរផ្នែកដោយមានហេតុផលសមរម្យ។
  - *ដើមស្មៅ:* នឹងលូតលាស់ល្អជាងមុន ឬកើនចំនួន (ព្រោះគ្មានជង្គ្រស៊ី)។
  - *សត្វចាប:* នឹងថយចុះ ឬហើរទៅរកកន្លែងថ្មី (ព្រោះខ្វះចំណី/ជង្គ្រ)។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវ និងមានហេតុផលសមរម្យតែមួយផ្នែក (ឧ. ឆ្លើយត្រូវតែរឿងស្មៅ តែខុសរឿងចាប)។
- **គ្មានពិន្ទុ** : ឆ្លើយខុសទាំងស្រុង ឬមិនឆ្លើយ។

# ប្រធានបទទី ២ : ស្ថានប្រព័ន្ធវាលស្រែ

**អត្ថបទខ្លី : វាលស្រែរបស់ពូសុខ**

កសិករម្នាក់ឈ្មោះពូសុខ បានធ្វើស្រែលើផ្ទៃដីមួយកន្លែង។ គាត់បានដាំ **គ្រាប់ស្រូវ** (ពូជផ្កាម្លិះ) ដែលកំពុងដុះលូតលាស់យ៉ាងខៀវខ្ចី។ ដើម្បីឱ្យស្រូវលូតលាស់ល្អ ពូសុខបានបូម **ទឹក** បញ្ចូល និងដាក់ **ដី**។ វាលស្រែរបស់គាត់ទទួលបាន **ពន្លឺព្រះអាទិត្យ** គ្រប់គ្រាន់។ នៅក្នុងស្រែមានសត្វ **កណ្តូប** កំពុងស៊ីស្លឹកស្រូវ និងមាន **សត្វកង្កែប** ចាំចាប់កណ្តូបស៊ីជាអាហារ។ ពេលខ្លះ ពូសុខឃើញមាន **សត្វពស់** មកចាប់កង្កែបស៊ី។



## សំណួរទី ១៖ ភាវៈក្នុងស្ថានប្រព័ន្ធ

នៅក្នុងវាលស្រែរបស់ពូសុខ មានធាតុផ្សំជាច្រើន។ ចូរគូសសញ្ញា ☑ ក្នុងប្រអប់ "ភាវៈមានជីវិត" ឬ "ភាវៈគ្មានជីវិត" ចំពោះវត្ថុខាងក្រោមឱ្យបានត្រឹមត្រូវ៖

| ឈ្មោះវត្ថុ/ភាវៈ | មានជីវិត | គ្មានជីវិត |
|---|---|---|
| ១. ពន្លឺព្រះអាទិត្យ | ☐ | ☐ |
| ២. ដើមស្រូវ | ☐ | ☐ |
| ៣. សត្វកណ្តូប | ☐ | ☐ |
| ៤. ទឹក | ☐ | ☐ |

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ និងបែងចែករវាងកត្តាមានជីវិត និងគ្មានជីវិតក្នុងបរិស្ថាន។ |
| កម្រិតពុទ្ធិ | ចងចាំ និងយល់ដឹង |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ខ្សែអាហារ

យោងតាមអត្ថបទខាងលើ តើសារពាង្គកាយនីមួយៗស្ថិតក្នុងក្រុមណា?

ចូរផ្គូផ្គងឈ្មោះសត្វ/រុក្ខជាតិ នៅខាងឆ្វេង ទៅនឹងតួនាទីរបស់វានៅខាងស្តាំ (អាចប្រើចម្លើយម្តង ឬច្រើនដង)។

| ឈ្មោះសារពាង្គកាយ | តួនាទីក្នុងស្ថានប្រព័ន្ធ | ចម្លើយ |
|---|---|---|
| ១. ដើមស្រូវ | A. ភាវៈរស់ស្វ័យជីព (អ្នកផលិត) | ១. ⇨ .......... |
| ២. សត្វកណ្តូប | B. ភាវៈរស់បរជីព (អ្នកស៊ី - រុក្ខាសី) | ២. ⇨ .......... |
| ៣. សត្វកង្កែប | C. ភាវៈរស់បរជីព (អ្នកស៊ី - មំសាសី) | ៣. ⇨ .......... |
| ៤. សត្វពស់ | | ៤. ⇨ .......... |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់តួនាទីរបស់ភាវៈរស់នៅក្នុងខ្សែអាហារ (អ្នកផលិត, អ្នកស៊ី)។ |
| កម្រិតពុទ្ធិ | អនុវត្តន៍ |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

---

## សំណួរទី ៣៖ ការបែងចែកក្រុម

ពូសុខបានកត់សម្គាល់ឃើញស្ថានភាពពីរផ្សេងគ្នា៖

- **ស្ថានភាព ក៖** គាត់ឃើញដើមស្រូវចំនួន ១០០០ គុម្ព ដុះនៅក្នុងស្រែរបស់គាត់។
- **ស្ថានភាព ខ៖** គាត់ឃើញ ស្រូវ កណ្តូប កង្កែប និងពស់ រស់នៅលាយឡំគ្នាក្នុងស្រែរបស់គាត់។

1. តើស្ថានភាពមួយណាជា "**ពពួក**" ?

   A. ស្ថានភាព ក

   B. ស្ថានភាព ខ

2. សូមផ្តល់ហេតុផលមួយដើម្បីការពារចម្លើយរបស់អ្នក៖

.....................................................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគភាពខុសគ្នារវាងពពួក និងសហគមន៍ ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជម្រើសមានការបកស្រាយ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ប្រភេទស្ថានប្រព័ន្ធ

បើប្រៀបធៀប "វាលស្រែរបស់ពូសុខ" ទៅនឹង "ព្រៃធម្មជាតិ" តើវាលស្រែមានលក្ខណៈខុសប្លែកសំខាន់អ្វីខ្លះដែលធ្វើឱ្យវាក្លាយជា ស្ថានប្រព័ន្ធច្នៃប្រឌិត? សូមជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុត។

☐A. វាមានសត្វរស់នៅច្រើនប្រភេទដូចជា ពស់ និងកង្កែប។

☐B. វាត្រូវការមនុស្សជួយកំណត់លក្ខខណ្ឌ(ដូចជាការបូមទឹក និងដាក់ជី) ទើបលូតលាស់បាន។

☐C. វាមានរុក្ខជាតិពណ៌បៃតងដែលអាចផលិតអាហារបាន។

☐D. វាទទួលបានពន្លឺព្រះអាទិត្យ និងទឹកភ្លៀងពីធម្មជាតិ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ពន្យល់ពីមូលហេតុដែលចាត់ថ្នាក់ស្ថានប្រព័ន្ធមួយថាជា "ច្នៃប្រឌិត"។ |
| កម្រិតពុទ្ធិ | វាយតម្លៃ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ តុល្យភាពបរិស្ថាន

ឧបមាថា ពូសុខបានចាប់ សត្វកង្កែប ទាំងអស់ចេញពីស្រែដើម្បីយកទៅលក់។ តើនឹងមានអ្វីកើតឡើងចំពោះចំនួន សត្វកណ្តូប និង ទិន្នផលស្រូវ?

១. ចំនួនសត្វកណ្តូបនឹង៖ .................................................. (កើនឡើង / ថយចុះ)

២. ទិន្នផលស្រូវនឹង៖ ........................................................ (កើនឡើង / ថយចុះ)

៣. មូលហេតុ៖ ......................................................................................................

......................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ព្យាករណ៍ពីផលវិបាកនៃការផ្លាស់ប្តូរសមាសភាគណាមួយក្នុងខ្សែអាហារ។ |
| កម្រិតពុទ្ធិ | បង្កើតថ្មី និងវាយតម្លៃ |
| ទម្រង់សំណួរ | បំពេញចន្លោះ និងបកស្រាយ |
| កម្រិតសមត្ថភាព | កម្រិត ៤ |

# អត្រាគំណែ

**សំណួរទី ១**

- **ចម្លើយត្រូវ :**
  - ១.គ្មានជីវិត
  - ២.មានជីវិត
  - ៣.មានជីវិត
  - ៤.គ្មានជីវិត។

**សំណួរទី ២៖**

- **ចម្លើយត្រូវ៖**
  - ១. ដើមស្រូវ ⇨ A (ស្វ័យជីព)
  - ២. សត្វកណ្តូប ⇨ B (បរជីព/រុក្ខាសី)
  - ៣. សត្វកង្កែប ⇨ C (បរជីព/មំសាសី)
  - ៤. សត្វពស់ ⇨ C (បរជីព/មំសាសី)

**សំណួរទី ៣៖**

- **ចម្លើយត្រូវ :** A. ស្ថានភាព ក
- **ហេតុផល :** ដោយសារពពួកគឺជាក្រុមសារពាង្គកាយ **ប្រភេទដូចគ្នា** (ស្រូវដូចគ្នា) រស់នៅកន្លែងតែមួយ។ (ចំណែក ខ គឺជាសហគមន៍ ព្រោះមានច្រើនប្រភេទលាយគ្នា)។

**សំណួរទី ៤៖**

- **ចម្លើយត្រូវ :** B. វាត្រូវការមនុស្សជួយកំណត់លក្ខខណ្ឌ (ដូចជាការបូមទឹក និងដាក់ជី) ទើបលូតលាស់បាន។

**សំណួរទី ៥៖**

- **ពិន្ទុពេញ :**
  - ១. កណ្តូបនឹង **កើនឡើង**
  - ២. ទិន្នផលស្រូវនឹង **ថយចុះ**
  - ៣. **ហេតុផល:** ព្រោះពេលគ្មានកង្កែបស៊ីកណ្តូប កណ្តូបនឹងកើនចំនួនច្រើន ហើយស៊ីបំផ្លាញដើមស្រូវកាន់តែខ្លាំង។
- **ពិន្ទុខ្លះ :** ឆ្លើយត្រូវត្រឹមលទ្ធផល (កើន/ថយ) តែហេតុផលមិនច្បាស់លាស់។
- **គ្មានពិន្ទុ :** ឆ្លើយខុស (ឧ. ស្រូវនឹងកើនឡើង)។

# មេរៀនទី២ បរិស្ថានរូប និងបរិស្ថានជីវៈ

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ៣ : ការរៀបចំអាងចិញ្ចឹមត្រី

### អត្ថបទខ្លី: អាងចិញ្ចឹមត្រីរបស់តារា



តារា និងមិត្តភក្តិបានសម្រេចចិត្តរៀបចំអាងចិញ្ចឹមត្រីមួយនៅក្នុងថ្នាក់រៀន។ ដើម្បីឱ្យត្រីអាចរស់នៅបាន ពួកគេបានរៀបចំដូចខាងក្រោម៖

- ពួកគេដាក់ **ខ្សាច់ និងគ្រួស** នៅបាតអាង ហើយចាក់ **ទឹក** ចូល។
- ពួកគេដាំ **រុក្ខជាតិទឹក (សារាយ)** ដើម្បីឱ្យវាផលិតអាហារ និងបញ្ចេញអុកស៊ីសែន។
- ពួកគេបានលែង **កូនត្រី** ចំនួន ៤ ក្បាលចូលទៅក្នុងអាង។
- តារាវាស់សីតុណ្ហភាពទឹកឃើញថាមានកម្តៅ ២៥°C និងវាស់កម្រិត pH ឃើញស្មើ ៧ (ណឺត)។
- រៀងរាល់សប្តាហ៍ ពួកគេឃើញមាន **កាកសំណល់** នៅបាតអាងដែលកើតពីលាមកត្រី និងស្លឹកសារាយដែលរលួយ។

## សំណួរទី ១៖ ការបែងចែកប្រភេទបរិស្ថាន

នៅក្នុងអាងចិញ្ចឹមត្រីរបស់តារា មានធាតុផ្សំជាច្រើនដែលជា "បរិស្ថានរូប" និង "បរិស្ថានជីវៈ"។ ចូរគូសសញ្ញា ☑ ក្នុងប្រអប់ឱ្យបានត្រឹមត្រូវ ដើម្បីចាត់ថ្នាក់វត្ថុខាងក្រោម៖

| ឈ្មោះវត្ថុ/ធាតុផ្សំ | បរិស្ថានរូប | បរិស្ថានជីវៈ |
|---|---|---|
| ១. កូនត្រី | ☐ | ☐ |
| ២. សីតុណ្ហភាព (២៥°C) | ☐ | ☐ |
| ៣. រុក្ខជាតិទឹក (សារាយ) | ☐ | ☐ |
| ៤. ទឹក | ☐ | ☐ |

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកភាពខុសគ្នារវាងបរិស្ថានរូប និងបរិស្ថានជីវៈ។ |
| កម្រិតពុទ្ធិ | ចងចាំ និងយល់ដឹង |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

---

## សំណួរទី ២៖ តួនាទីក្នុងស្ថានប្រព័ន្ធ

ក្នុងបរិស្ថានជីវៈគេបែងចែកភាវៈរស់ជា ៣ ក្រុមគឺ៖ អ្នកផលិត អ្នកស៊ី និង អ្នកបំបែក។ តើសារពាង្គកាយក្នុងអាងត្រីនេះមានតួនាទីអ្វី? ចូរជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវ ។

**១. រុក្ខជាតិទឹក (សារាយ) គឺជា...**

☐A. អ្នកផលិត ☐B. អ្នកផលិត ☐C. អ្នកបំបែក

**២. កូនត្រី គឺជា...**

☐A. អ្នកផលិត ☐B. អ្នកផលិត ☐C. អ្នកបំបែក

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់តួនាទីរបស់សារពាង្គកាយ ដោយផ្អែកលើការផលិតអាហារ។ |
| កម្រិតពុទ្ធិ | អនុវត្តន៍ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ កត្តាសីតុណ្ហភាព

តារាចង់យក ដើមកូលាប ពីសួនច្បារមកដាំក្នុងអាងត្រីនេះជំនួសសារាយទឹកវិញ។ យោងតាមអត្ថបទមេរៀនផ្នែក "សីតុណ្ហភាព" តើការធ្វើបែបនេះត្រឹមត្រូវដែរឬទេ?

□A. ត្រឹមត្រូវ ព្រោះដើមកូលាបក៏ត្រូវការទឹកដូចគ្នា។

□B. មិនត្រឹមត្រូវ ព្រោះដើមកូលាបត្រូវការសីតុណ្ហភាព ដូចគ្នា តែវាជារុក្ខជាតិដីគោក

□C. មិនត្រឹមត្រូវ ព្រោះដើមកូលាបត្រូវការសីតុណ្ហភាពខុសពីនេះ និងបរិស្ថានដី មិនមែនទឹកទេ។

□D. ត្រឹមត្រូវ ព្រោះដើមកូលាបជាអ្នកផលិតដូចសារាយដែរ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគឥទ្ធិពលនៃសីតុណ្ហភាព និងប្រភេទបរិស្ថាន(ដី/ទឹក) មកលើភាវៈរស់។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ កម្រិត pH និងការរស់នៅ

នៅក្នុងមេរៀនបានបញ្ជាក់ថា "ឆ្លាម និងភេសមុទ្ររស់នៅក្នុងសមុទ្រដែលជាមជ្ឈដ្ឋានបាស ហើយមាន pH ប្រហែល ៨"។ ទឹកក្នុងអាងរបស់តារាមាន pH = 7។ តើតារាគួរយកត្រីឆ្លាមមកចិញ្ចឹមក្នុងអាងនេះដែរឬទេ? សូមជ្រើសរើសចម្លើយ និងផ្តល់ហេតុផល។

១. ចម្លើយ: ........................................................ (គួរ / មិនគួរ)

២. ហេតុផល: ..........................................................................................................

..........................................................................................................................

..........................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | អនុវត្តចំណេះដឹងអំពី pH ដើម្បីកំណត់ភាពសមស្របនៃលំនៅឋានសម្រាប់ភាវៈរស់។ |
| កម្រិតពុទ្ធិ | វាយតម្លៃ |
| ទម្រង់សំណួរ | ពហុជ្រើសរើស និងបកស្រាយ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ទំនាក់ទំនងរវាងពន្លឺ និងអុកស៊ីសែន

ឧបមាថា តារាបានយកក្រណាត់ខ្មៅមកគ្របអាងត្រីនេះជិតឈឹង រយៈពេល ១ សប្តាហ៍ ដោយមិនឱ្យពន្លឺចូលសោះ។

តើនឹងមានអ្វីកើតឡើងចំពោះកម្រិត អុកស៊ីសែន នៅក្នុងទឹក? សូមពន្យល់ដោយផ្សារភ្ជាប់ជាមួយពន្លឺព្រះអាទិត្យ និង រុក្ខជាតិ។

១. កម្រិតអុកស៊ីសែននឹង៖ .................................................... (កើនឡើង / ថយចុះ / នៅដដែល)

២. ការពន្យល់៖ ..........................................................................................................

..........................................................................................................................

..........................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ពន្យល់ពីទំនាក់ទំនងរវាងពន្លឺព្រះអាទិត្យ រស្មីសំយោគ និងការផលិតអុកស៊ីសែន។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៤ |

# អត្រាកំណែ

## សំណួរទី ១៖

- **ចម្លើយត្រូវ៖**
    - ១. កូនត្រី = **បរិស្ថានជីវៈ**
    - ២. សីតុណ្ហភាព = **បរិស្ថានរូប**
    - ៣. រុក្ខជាតិទឹក = **បរិស្ថានជីវៈ**
    - ៤. ទឹក = **បរិស្ថានរូប**
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

## សំណួរទី ២៖

- **ចម្លើយត្រូវ៖**
    - ១. រុក្ខជាតិទឹក ⇨ **B. អ្នកផលិត** (ព្រោះវាធ្វើរស្មីសំយោគ/ផលិតអាហារបាន)។
    - ២. កូនត្រី ⇨ **A. អ្នកស៊ី** (ព្រោះវាមិនអាចផលិតអាហារបាន)។

## សំណួរទី ៣៖

- **ចម្លើយត្រូវ៖ C. មិនត្រឹមត្រូវ ព្រោះដើមកូលាបត្រូវការសីតុណ្ហភាពខុសពីនេះ និងបរិស្ថានដី មិនមែនទឹកទេ។**
    - *(កំណត់សម្គាល់៖ ទោះបីសីតុណ្ហភាពអាចត្រូវគ្នា (២០-៣០°C) ប៉ុន្តែកត្តាបរិស្ថានរូបសំខាន់គឺ "ដី" និង "ទឹក" ដែលមិនអាចផ្លាស់ប្តូរគ្នាបាន)។*

## សំណួរទី ៤៖

- **ពិន្ទុពេញ** :
    - ចម្លើយ៖ **មិនគួរ**
    - ហេតុផល៖ យោងតាមអត្ថបទ ឆ្លាមត្រូវការរស់នៅមជ្ឈដ្ឋាន **បាស (pH ប្រហែល ៨)** ប៉ុន្តែទឹកក្នុងអាងមាន pH ៧ (ណឺត) ដែលមិនសាកសមសម្រាប់វា។
- **ពិន្ទុខ្លះ** : ឆ្លើយថា "មិនគួរ" តែហេតុផលមិនច្បាស់លាស់ (ឧ. ឆ្លាមធំពេក) -> *ចម្លើយនេះត្រឹមត្រូវតាមការពិត តែមិនបានពិន្ទុពេញទេព្រោះសំណួរតម្រូវឱ្យផ្អែកលើ pH*។
- **គ្មានពិន្ទុ** : ឆ្លើយថា "គួរ"។

## សំណួរទី ៥៖

- **ពិន្ទុពេញ** :
    - ១. កម្រិតអុកស៊ីសែននឹង **ថយចុះ**។

- ○ ២. **ការពន្យល់:** រុក្ខជាតិត្រូវការ **ពន្លឺព្រះអាទិត្យ** ដើម្បីធ្វើរស្មីសំយោគនិងផលិតអាហារ ព្រមទាំងបញ្ចេញ **អុកស៊ីសែន**។ បើគ្មានពន្លឺ រុក្ខជាតិមិនអាចផលិតអុកស៊ីសែនបានទេ ធ្វើឱ្យអុកស៊ីសែនក្នុងទឹកថយចុះ (ហើយត្រីអាចនឹងងាប់)។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថានឹង "ថយចុះ" តែការពន្យល់មិនបានភ្ជាប់ជាមួយរស្មីសំយោគ ឬពន្លឺទេ។
- **គ្មានពិន្ទុ** : ឆ្លើយខុស (កើនឡើង/នៅដដែល)។

# មេរៀនទី៣ ទំនាក់ទំនងនៅក្នុងសហគមន៍

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី៤ : ទំនាក់ទំនងរវាងភាវៈរស់

### អត្ថបទខ្លី : ការដើរកម្សាន្តក្នុងព្រៃ

និស្សិតមួយក្រុមបានទៅសិក្សាស្រាវជ្រាវនៅក្នុងព្រៃមួយ ហើយបានកត់ត្រានូវទំនាក់ទំនងរវាងភាវៈរស់ចំនួន ៣ ករណីដែលពួកគេបានឃើញ៖



- **ករណីទី ១៖** នៅលើដើមឈើធំមួយ មាន **ដើមអ័រគីដេ** មួយដុះតោងជាប់។ ដើមអ័រគីដេទទួលបានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ ប៉ុន្តែវាមិនបានស្រូបយកជំពីដើមឈើធំនោះទេ។
- **ករណីទី ២៖** នៅលើផ្ទាំងថ្ម មានដុះ **លីកែន** ដែលជាការរួមរស់រវាងសារាយបៃតង និងផ្សិត។ សារាយបៃតងផលិតអាហារចែកដល់ផ្សិត ហើយផ្សិតផ្តល់ឧស្ម័នកាបូនិចឱ្យសារាយវិញ។
- **ករណីទី ៣៖** នៅភូមិក្បែរព្រៃ សិស្សឃើញ **សត្វចៃ** កំពុងតោងខាំបឺតឈាមលើខ្លួន **សត្វឆ្កែ** ធ្វើឱ្យឆ្កែនោះរមាស់និងស្គម។

---

### សំណួរទី ១៖ ការកំណត់ប្រភេទទំនាក់ទំនង

យោងតាមកំណត់ហេតុខាងលើ ចូរកំណត់ប្រភេទទំនាក់ទំនង ("ភាពប្រជួយ", "ភាពបន្ទម", ឬ "បរាសិតភាព") សម្រាប់ករណីនីមួយៗ ដោយគូសសញ្ញា ☑ ក្នុងប្រអប់ឱ្យបានត្រឹមត្រូវ។

| ករណីទំនាក់ទំនង | ភាពប្រជួយ | ភាពបន្ទម | បរាសិតភាព |
|---|---|---|---|
| ១. ដើមអ័រគីដេ និងដើមឈើធំ | ☐ | ☐ | ☐ |
| ២. សត្វចៃ និងសត្វឆ្កែ | ☐ | ☐ | ☐ |
| ៣. លីកែន (សារាយ និងផ្សិត) | ☐ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ប្រភេទនៃសហប្រាណតាមរយៈឧទាហរណ៍ជាក់ស្តែង។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

---

### សំណួរទី ២៖ ការផ្លាស់ប្តូរផលប្រយោជន៍ (លីកែន)

នៅក្នុងករណីទី ២ (លីកែន) អត្ថបទមេរៀនបានបញ្ជាក់ថា សារាយបៃតង និងផ្សិត មានការផ្លាស់ប្តូរផលប្រយោជន៍គ្នាទៅវិញទៅមក។

ចូរជ្រើសរើសពាក្យខាងក្រោមទៅបំពេញក្នុងល្បះឱ្យបានត្រឹមត្រូវ៖ *(ពាក្យអាចជ្រើសរើស៖ ជម្រក , ឧស្ម័នកាបូនិច, ទឹក, ដើមឈើ)*

"នៅក្នុងលីកែន ផ្សិតផ្តល់ ......................................ឱ្យទៅសារាយបៃតង ដើម្បីយកទៅផលិតអាហារ។"

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ពន្យល់ពីយន្តការនៃការផ្លាស់ប្តូរសារធាតុរវាងភាវៈរស់នៅក្នុងភាពប្រជួយ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | បំពេញចន្លោះ |
| កម្រិតសមត្ថភាព | កម្រិត ១ |

---

### សំណួរទី ៣៖ ការវិភាគលើដើមអ័រគីដេ

ហេតុអ្វីបានជាទំនាក់ទំនងរវាង ដើមអ័រគីដេ និង ដើមឈើធំ ត្រូវបានចាត់ទុកជា "ភាពបន្ទម"? ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុត។

☐A. ព្រោះដើមអ័រគីដេ និងដើមឈើធំ ទទួលបានផលប្រយោជន៍ដូចគ្នា។

☐B. ព្រោះដើមអ័រគីដេ ទទួលបានផល (ជម្រក/ពន្លឺ) ឯដើមឈើធំខាតបង់ផលប្រយោជន៍។

☐C. ព្រោះដើមអ័រគីដេ ទទួលបានផល ឯដើមឈើធំមិនទទួលបានផលក៏មិនខាតបង់ផលដែរ។

☐D. ព្រោះដើមឈើធំ ទទួលបានផលពីអ័រគីដេ ឯអ័រគីដេមិនទទួលបានអ្វីទាំងអស់។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគលក្ខណៈសម្គាល់នៃភាពបន្លម (ភារៈមួយចំណេញ ភារៈមួយទៀតមិនខាត មិនចំណេញ)។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

**សំណួរទី ៤៖ ផលប៉ះពាល់នៃបរាសិត**

ចំពោះករណីទី ៣ (ចៃ និងឆ្កែ): ប្រសិនបើចំនួនសត្វចៃនៅលើខ្លួនឆ្កែកើនឡើងយ៉ាងច្រើន តើនឹងមានអ្វីកើតឡើងចំពោះ សុខភាពរបស់ឆ្កែ?

សូមពន្យល់ដោយប្រើពាក្យ "បរាសិតភាព" និង "ធ្នូល" នៅក្នុងចម្លើយរបស់អ្នក។

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ព្យាករណ៍ផលប៉ះពាល់នៃទំនាក់ទំនងបរាសិតមកលើធ្នូល។ |
| កម្រិតពុទ្ធិ | វិភាគ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៤ |

## សំណួរទី ៥៖ កូនខ្លៅសមុទ្រ និងសំបកងាវ

អត្ថបទមេរៀនបានលើកឡើងថា "កូនខ្ចៅសមុទ្រភ្ជាប់ខ្លួនទៅនឹងសំបកងាវ... វាជាភាពបន្លម"។

ឧបមាថា ថ្ងៃមួយអ្នកវិទ្យាសាស្ត្ររកឃើញថា កូនខ្ចៅសមុទ្រទាំងនោះបានជួយ កម្ចាត់សត្វល្អិត ចេញពីសំបកងាវ ដែលធ្វើឱ្យងាវមានសុខភាពល្អជាងមុន (ងាវក៏បានផលដែរ)។ ក្នុងស្ថានភាពថ្មីនេះ តើ ទំនាក់ទំនងរបស់វានៅតែជា **"ភាពបន្លម"** ដដែល ឬប្តូរទៅជា **"ភាពប្រជួយ"**?

១. ចម្លើយ៖ ........................................................ (ភាពបន្លម / ភាពប្រជួយ)

២. ហេតុផល៖ ....................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃឡើងវិញនូវប្រភេទទំនាក់ទំនង នៅពេលមានព័ត៌មាន/លក្ខខណ្ឌថ្មី។ |
| កម្រិតពុទ្ធិ | វាយតម្លៃ |
| ទម្រង់សំណួរ | ចម្លើយខ្លី និងបកស្រាយ |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

- **ពិន្ទុពេញ** : គូសត្រូវទាំង ៣ ជួរ។
  - ១. ដើមអ័រគីដេ = **ភាពបន្ថែម**
  - ២. សត្វចៃ = **បរាសិតភាព**
  - ៣. លីកែន = **ភាពប្រជួយ**
- **គ្មានពិន្ទុ** : គូសខុសមួយ ឬច្រើន។

**សំណួរទី ២៖**

- ពិន្ទុពេញ: បំពេញពាក្យ "ឧស្ម័នកាបូនិច"។
  (យោងតាមអត្ថបទមេរៀន៖ "ផ្សិតផ្តល់ឱ្យសារាយបែតងនូវឧស្ម័នកាបូនិចសម្រាប់ផលិតអាហារ")

**សំណួរទី ៣៖**

- **ពិន្ទុពេញ**: C. ព្រោះដើមអ័រគីដេទទួលបានផល ឯដើមឈើធំមិនទទួលបានផល ហើយក៏មិនខាតបង់ផលដែរ។

**សំណួរទី ៤៖**

- **ពិន្ទុពេញ**: ពន្យល់បានត្រឹមត្រូវថា ឆ្កែនឹងខូចសុខភាព/ស្គម/ឈឺ ដោយប្រើពាក្យបច្ចេកទេសត្រឹមត្រូវ។
  - *ចម្លើយគំរូ:* "សុខភាពឆ្កែនឹងចុះខ្សោយ ឬកើតជំងឺ ព្រោះក្នុងទំនាក់ទំនង **បរាសិតភាព** ចៃទទួលបានផល រីឯឆ្កែដែលជា **ជ្រុល** ត្រូវទទួលទុក្ខទោស (បាត់បង់ឈាម)។"
- **ពិន្ទុខ្លះ**: ឆ្លើយថាឆ្កែឈឺ តែមិនបានប្រើពាក្យ "ជ្រុល" ឬ "បរាសិតភាព"។

**សំណួរទី ៥៖**

- **ពិន្ទុពេញ**:
  - ចម្លើយ៖ **ភាពប្រជួយ**
  - ហេតុផល៖ ព្រោះក្នុងស្ថានភាពថ្មីនេះ ភាគីទាំងសងខាង (ទាំងខ្លៅ និងងាវ) សុទ្ធតែទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមក (មិនមែនបានតែម្ខាងដូចមុនទេ)។
- **គ្មានពិន្ទុ**: ឆ្លើយថា "ភាពបន្ថែម" ឬផ្តល់ហេតុផលមិនត្រឹមត្រូវ។

# ជំពូកទី២ រុក្ខជាតិ

## មេរៀនទី១ រុក្ខជាតិឥតផ្កា : ប៉ប្រក

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ៥ : អាថ៌កំបាំងក្រោមស្លឹកប៉ប្រក

**អត្ថបទខ្លី : ការរកឃើញរបស់សុភាព**



សុភាពបានទៅលេងនៅតំបន់ទឹកធ្លាក់មួយ ហើយឃើញមានដើមរុក្ខជាតិម្យ៉ាងដុះនៅតាមជញ្ជាំងថ្មសើមៗ និងក្រោមម្លប់ឈើ។

- ដើមរបស់វាស្ថិតនៅក្រោមដី។
- ស្លឹករបស់វាចែកៗស្អាតណាស់។
- ពេលសុភាពត្រឡប់ស្លឹកមើលផ្នែកខាងក្រោម គាត់ឃើញមាន **ដុំពកតូចៗពណ៌ត្នោត** ជាច្រើន។ គាត់ឆ្ងល់ថា "**តើវាជាស៊ុតរបស់សត្វល្អិត ឬជារបស់រុក្ខជាតិនេះ?**"
- នៅក្បែរនោះ គាត់ឃើញមានបន្ទះពណ៌បៃតងតូចមួយរាងដូចបេះដូង (ប្រូតាល់) ដុះជាប់នឹងដីសើមដែរ។

**សំណួរទី ១៖ រចនាសម្ព័ន្ធបន្តពូជ**

តើ "ដុំពកតូចៗពណ៌ត្នោត" ដែលសុភាពឃើញនៅផ្នែកខាងក្រោមនៃស្លឹកប៉ប្រកនោះ តាមពិតគឺជាអ្វី?

☐A. គ្រាប់សម្រាប់ដាំ។ ☐B. ស្ប៉័រងដែលផ្ទុកស្ប៉ រ៍។

☐C. ស៊ុតរបស់សត្វល្អិតដែលមកពងដាក់។ ☐D. ផ្កាដែលត្រៀមនឹងរីក។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់អត្តសញ្ញាណសរីរាង្គបន្តពូជ (ស្ប៉័រង់) របស់រុក្ខជាតិឥតផ្កា។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

### សំណួរទី ២៖ តួនាទីរបស់ទឹក

នៅក្នុងដំណើរការបន្តពូជរបស់ប៉ប្រេក ទឹក ឬ សំណើម មានតួនាទីយ៉ាងសំខាន់មិនអាចខ្វះបាន។ ហេតុអ្វីបានជាទឹកមានសារៈសំខាន់ខ្លាំងម្ល៉េះនៅក្នុងដំណាក់កាល បង្កកំណើត?

☐A. ដើម្បីឱ្យស្ប៉័រង់ទុំ និងរហែកចេញ។

☐B. ដើម្បីលាងសម្អាតស្លឹកឱ្យស្អាត។

☐C. ដើម្បីឱ្យអង់តេរ៉ូសូអ៊ីត (កោសិកាឈ្មោល) អាចហែលទៅជួបអូអូស្វែ (កោសិកាញី)។

☐D. ដើម្បីឱ្យប្រូតាល់អាចផលិតអាហារបាន។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ពន្យល់ពីយន្តការនៃការបង្កកំណើតរបស់រុក្ខជាតិឥតផ្កាដែលត្រូវការទឹក។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

### សំណួរទី ៣៖ វដ្តជីវិត

ប៉ប្រេកមានវដ្តជីវិតឆ្លងកាត់ ២ ដំណាក់កាលធំៗគឺ ដំណាក់កាលបង្កើតស្ប៉ រនិង ដំណាក់កាលបង្កើតកោសិកាបន្តពូជ ។

ចូរគូសសញ្ញា ☑ ក្នុងប្រអប់ដើម្បីចាត់ថ្នាក់ថាតើផ្នែកណាមួយស្ថិតក្នុងដំណាក់កាលណា?



| ផ្នែកនៃរុក្ខជាតិ | ដំណាក់កាលបង្កើតស្ប៉ | ដំណាក់កាលបង្កើតកោសិកាបន្តពូជ |
|---|---|---|
| ១. ដើមប៉ប្រកពេញវ័យ (មានស្លឹក) | ☐ | ☐ |
| ២. ប្រូតាល់ (រាងដូចបេះដូង) | ☐ | ☐ |
| ៣. ស្ប៉័រង | ☐ | ☐ |
| ៤. អង់តេរីឌី និង អាកេកូន | ☐ | ☐ |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកផ្នែកផ្សេងៗនៃរុក្ខជាតិទៅតាមដំណាក់កាលនៃវដ្តជីវិត។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

---

## សំណួរទី ៤៖ ការព្យាករណ៍ពីបរិស្ថាន

សុភាពចង់យកប៉ប្រកនេះទៅដាំលម្អនៅសួនច្បារក្រោយផ្ទះរបស់គាត់។ សួនរបស់គាត់ជាដីខ្សាច់ មានពន្លឺថ្ងៃក្តៅខ្លាំងពេញមួយថ្ងៃ និងស្ងួត។ តើប៉ប្រកនឹងអាចបន្តពូជ និងលូតលាស់បានដែរឬទេ? សូមជ្រើសរើសចម្លើយ និងផ្តល់ហេតុផល។

១. ចម្លើយ៖ ........................................................ (បាន / មិនបាន)

២. ហេតុផល (ផ្អែកលើការបន្តពូជ)៖ ....................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពសមស្របនៃបរិស្ថានសម្រាប់ការរស់រាន និងបន្តពូជរបស់ប៉ប្រក។ |
| កម្រិតពុទ្ធិ | វាយតម្លៃ |
| ទម្រង់សំណួរ | ចម្លើយខ្លី និងបកស្រាយ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ លំដាប់នៃជីវិត

ចូររៀបរាប់លំដាប់នៃដំណើរការបន្តពូជរបស់ប៉ប្រកឡើងវិញ ដោយដាក់លេខរៀង (១, ២, ៣, ៤) ចូលក្នុងប្រអប់ខាងមុខឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយ។

[ .......... ] ស្ប៉ធ្លាក់លើដីសើម ហើយដុះទៅជាប្រូតាល់។

[ .......... ] ស៊ុតលូតលាស់ក្លាយជាកូនរុក្ខជាតិ (ប៉ប្រក) ថ្មី។

[ .......... ] ស្ប៉រ៉ង់ទុំ រហែកបញ្ចេញស្ប៉។

[ .......... ] អង់តេរ៉ូសូអ៊ីត ហែលទៅជួប អូអូស្វ៊ែ ហើយបង្កកំណើតបានជាស៊ុត។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | រៀបរាប់លំដាប់លំដោយនៃវដ្តជីវិតរបស់រុក្ខជាតិឥតផ្កា។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | រៀបលំដាប់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

# អង្គភាពកំណែ

**សំណួរទី ១៖**

- **ចម្លើយត្រូវ៖** B. ស្ប៉ូរ៉ងដែលផ្ទុកស្ប៉ូ។

**សំណួរទី ២៖**

- **ចម្លើយត្រូវ៖** C. ដើម្បីឱ្យអង់តេរ៉ូសូអ៊ីត (កោសិកាឈ្មោល) អាចហែលទៅជួបអូអូស្វៃ (កោសិកាញី)។

**សំណួរទី ៣៖**

- **ចម្លើយត្រូវ៖**
  - ១. ដើមប៉ប្រកពេញវ័យ ⇨ ដំណាក់កាលបង្កើតស្ប៉ូ
  - ២. ប្រូតាល់ ⇨ ដំណាក់កាលបង្កើតកោសិកាបន្តពូជ
  - ៣. ស្ប៉ូរ៉ង ⇨ ដំណាក់កាលបង្កើតស្ប៉ូ
  - ៤. អង់តេរីឌី និង អាកេកូន ⇨ ដំណាក់កាលបង្កើតកោសិកាបន្តពូជ

**សំណួរទី ៤៖**

- **ពិន្ទុពេញ :**
  - ចម្លើយ៖ **មិនបាន**
  - ហេតុផល៖ ដោយសារប៉ប្រកត្រូវការ **សំណើម/ទឹក** ជាចាំបាច់ដើម្បីឱ្យអង់តេរ៉ូសូអ៊ីតហែលទៅបង្កកំណើត។ បើដីស្ងួត និងក្តៅខ្លាំង វាមិនអាចបន្តពូជបានទេ (ហើយស្ប៉ូក៏មិនអាចដុះជាប្រូតាល់បានដែរ)។
- **ពិន្ទុខ្លះ :** ឆ្លើយថា "មិនបាន" តែហេតុផលមិនច្បាស់លាស់ (ឧ. ព្រោះវាចូលចិត្តម្លប់) -> *មិនសូវត្រូវនឹងចំណុច "បន្តពូជ" ទេ។*
- **គ្មានពិន្ទុ :** ឆ្លើយថា "បាន"។

**សំណួរទី ៥៖**

- **ចម្លើយត្រូវ (លំដាប់ត្រឹមត្រូវ):**
  - [ ២ ] ស្ប៉ូធ្លាក់លើដីសើម ហើយដុះទៅជាប្រូតាល់។
  - [ ៤ ] ស៊ុតលូតលាស់ក្លាយជាកូនរុក្ខជាតិ (ប៉ប្រក) ថ្មី។
  - [ ១ ] ស្ប៉ូរ៉ងទុំ រហែកបញ្ចេញស្ប៉ូ។
  - [ ៣ ] អង់តេរ៉ូសូអ៊ីត ហែលទៅជួប អូអូស្វៃ ហើយបង្កកំណើតបានជាស៊ុត។

# មេរៀនទី២ រុក្ខជាតិមានផ្កា

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ៦ : ការសិក្សានៅសួនដំណាំ

### អត្ថបទខ្លី : ការសង្កេតរបស់នារី



នារីបានទៅលេងសួនដំណាំរបស់ជីតានាង។ នាងបានសង្កេតឃើញរុក្ខជាតិជាច្រើនប្រភេទ និងបានកត់ត្រាលក្ខណៈពិសេសរបស់វា៖

1. **ដើមខ្ញី៖** ជីតាកំពុងជីកមើមខ្ញីពីក្នុងដី ដែលវាមានថ្នាំង និងមានឫសតូចៗចេញពីថ្នាំងនោះ។
2. **ដើមស្វាយ៖** ជាដើមឈើធំ មានមែករឹង និងខ្ពស់។ ជីតាប្រាប់ថាវាមាន "ឫសកែវ" ចាក់ជ្រៅទៅក្នុងដី។
3. **ដើមខ្ទឹមបារាំង៖** នាងឃើញគេដកខ្ទឹមបារាំងដែលមានស្រទាប់ជាច្រើន។
4. **ដើមដំបងយក្ស៖** ដាំក្នុងផើងមុខផ្ទះ ដែលមានបន្លាស្រួចៗ។
5. **ផ្កា៖** នាងឃើញផ្កាជាច្រើនកំពុងរីក និងមានសត្វឃ្មុំមកក្រេបលំអង។

---

### សំណួរទី ១៖ ប្រភេទនៃឫស

យោងតាមការកត់ត្រារបស់នារី ចូរប្រៀបធៀបប្រព័ន្ធឫសរបស់ ដើមស្វាយ និង ដើមស្មៅ ។ តើដើមរុក្ខជាតិទាំងពីរមានប្រភេទឫសដូចម្តេច?

| ឈ្មោះរុក្ខជាតិ | ឫសស្នឹង | ឫសស្នៃ |
|---|---|---|
| ១. ដើមស្វាយ | ☐ | ☐ |
| ២. ដើមស្មៅ | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកប្រភេទប្រព័ន្ធឫស (ឫសស្នឹង និងឫសស្ពៃ) របស់រុក្ខជាតិ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ អាថ៌កំបាំងក្រោមដី

នារីឆ្ងល់ថា "ខ្ញី" និង "ខ្ទឹមបារាំង" ដុះនៅក្នុងដីដូចឫសដែរ ប៉ុន្តែក្នុងមេរៀនចាត់ទុកពួកវាជា ដើមក្រោមដី។ តើពួកវាជាដើមក្រោមដីប្រភេទអ្វី? ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

**១. ខ្ញី គឺជា...**

☐A. មើម ☐B. មើមស្រកា ☐C. មើមក្លៀង

**២. ខ្ទឹមបារាំង គឺជា...**

☐A. មើម ☐B. មើមស្រកា ☐C. មើមក្លៀង

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ប្រភេទដើមក្រោមដី (មើម, មើមស្រកា, មើមក្លៀង) ផ្អែកលើលក្ខណៈរូប |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការបន្សាំខ្លួនរបស់ស្លឹក

នារីបានសង្កេតឃើញ ដើមដំបងយក្ស មានបន្លាស្រួចៗ។ យោងតាមអត្ថបទមេរៀនផ្នែក "ស្លឹក" បន្លាទាំងនោះគឺជាស្លឹកដែលបំប្លែងខ្លួន។

តើហេតុអ្វីបានជាដើមដំបងយក្សចាំបាច់ត្រូវមាន ស្លឹកបន្លា (ឬស្លឹកម្ជុល)?

☐A. ដើម្បីឱ្យមើលទៅស្អាត និងទាក់ទាញសត្វល្អិត។

☐B. ដើម្បីឱ្យវាអាចតោងជញ្ជាំងបានល្អ។

☐C. ដើម្បីកាត់បន្ថយការបាត់បង់ទឹក និងការពារខ្លួន។

☐D. ដើម្បីចាប់សត្វល្អិតជាអាហារ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ពន្យល់ពីការបំប្លែងខ្លួនរបស់ស្លឹក (ស្លឹកបន្លា) ក្នុងការសម្របខ្លួននឹងបរិស្ថាន។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

### សំណួរទី ៤៖ មុខងាររបស់ផ្កា

នៅពេលនារីមើលទៅផ្កាដែលកំពុងរីក នាងឃើញមានផ្នែកពណ៌បៃតងនៅខាងក្រោម និងផ្នែកពណ៌ឆើតឆាតនៅខាងលើ។

ចូរបំពេញមុខងារសំខាន់របស់ផ្នែកនីមួយៗក្នុងតារាងខាងក្រោម៖

| ផ្នែកនៃផ្កា | មុខងារសំខាន់ (យោងតាមអត្ថបទ) |
|---|---|
| ១. កញ្ចុំត្របក | ........................................................................................ |
| ២. កញ្ចុំស្រទាប់ | ........................................................................................ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | រៀបរាប់មុខងាររបស់ផ្នែកសំខាន់ៗនៃផ្កា (ត្របក និងស្រទាប់)។ |
| កម្រិតពុទ្ធិ | អនុវត្ត |
| ទម្រង់សំណួរ | បំពេញចន្លោះ |
| កម្រិតសមត្ថភាព | កម្រិត ២ |

### សំណួរទី ៥៖ ពីផ្កាទៅផ្លែ

ក្រោយមក នារីបានញ៉ាំផ្លែស្វាយទុំយ៉ាងឆ្ងាញ់។ ជីតាប្រាប់ថា "ផ្លែស្វាយនេះ កាលពីមុនគឺជាផ្កាទេ"។ តើផ្នែកណាមួយនៃផ្កាស្វាយ ដែលលូតលាស់ក្លាយទៅជា សាច់ផ្លែ និងផ្នែកណាដែលក្លាយទៅជាគ្រាប់?

**១. អូវែ** ក្លាយទៅជា៖ ..........................................................

**២. អូវុល** ក្លាយទៅជា៖ ..........................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ការវិវត្តរបស់អូវ៉ែ និងអូវុល ទៅជាផ្លែ និងគ្រាប់។ |
| កម្រិតពុទ្ធិ | ចង់ចាំ |
| ទម្រង់សំណួរ | បំពេញចន្លោះ |
| កម្រិតសមត្ថភាព | កម្រិត ១ |

# អត្រាកំណែ

**សំណួរទី ១៖**

- **ចម្លើយត្រូវ៖**
    - ១. ដើមស្វាយ ⇨ **ឫសស្នឹង** (មានឫសកែវ)
    - ២. ដើមស្មៅ ⇨ **ឫសស្ញៃ** (គ្មានឫសកែវ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ២៖**

- **ចម្លើយត្រូវ៖**
    - ១. ខ្ញី ⇨ **C. មើមក្តៀង** (មានថ្នាំង ចន្លោះថ្នាំង និងឫសស្ញៃដុះពីក្រោម)។
    - ២. ខ្ទឹមបារាំង ⇨ **B. មើមស្រកា** (ផ្សំឡើងដោយស្រទាប់/ស្រកាស្លឹកច្រើន)។

**សំណួរទី ៣៖**

- **ចម្លើយត្រូវ៖ C. ដើម្បីកាត់បន្ថយការបាត់បង់ទឹក និងការពារខ្លួន។**
    - *(សម្គាល់៖ ទោះបីអត្ថបទមិនបានសរសេរពាក្យ "កាត់បន្ថយទឹក" ចំៗ ប៉ុន្តែវាជាចំណេះដឹងដែលបង្កប់ក្នុងគោលគំនិត "ស្លឹកបន្លា" របស់ដំបងយក្ស ហើយជម្រើសផ្សេងទៀតមិនសមហេតុផលតាមបែបវិទ្យាសាស្ត្រសម្រាប់ដំបងយក្សទេ)។*

**សំណួរទី ៤៖**

- **ពិន្ទុពេញ** : សរសេរមុខងារបានត្រឹមត្រូវតាមអត្ថបទ។
    - ១. កញ្ចុំត្របក៖ **ការពារត្របកផ្កា / ការពារផ្កានៅពេលខ្ចី** (ឬគ្រាន់តែសរសេរថាស្ថិតនៅវង់ក្រៅការពារផ្កា)។
    - ២. កញ្ចុំស្រទាប់៖ **សម្រាប់ទាក់ទាញសត្វល្អិត** (ដោយសារពណ៌ឆើតឆាត)។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬសរសេរមិនច្បាស់លាស់។

**សំណួរទី ៥៖**

- **ចម្លើយត្រូវ៖**
    - អូវែ (Ovary) ⇨ **ផ្លែ**
    - អូវុល (Ovule) ⇨ **គ្រាប់**
- *(ត្រូវឆ្លើយត្រូវទាំងពីរទើបបានពិន្ទុ)*

# ប្រធានបទទី ៧ : ពិសោធន៍លើការបង្កកំណើតរបស់ផ្កា

## អត្ថបទ និង ស្ថានភាព : អាថ៌កំបាំងនៃផ្លែប៉េងប៉ោះ




វិបុលចង់ដឹងថា តើការបង្កើតផ្លែរបស់រុក្ខជាតិពិតជាត្រូវការសត្វល្អិតជួយឬអត់? គាត់បានធ្វើពិសោធន៍លើ **ដើមប៉េងប៉ោះ** នៅក្នុងសួនរបស់គាត់ដោយបែងចែកជា ២ ក្រុម៖

- **ក្រុមទី ១:** វិបុលយកថង់ក្រដាសស្ដើងមកគ្របចងពីលើផ្កាប៉េងប៉ោះដែលជិតរីក ចំនួន ១០ ផ្កា យ៉ាងជិតមិនឱ្យសត្វចូលបាន។
- **ក្រុមទី ២:** គាត់ទុកផ្កាចំនួន ១០ ផ្សេងទៀតឱ្យរីកតាមធម្មជាតិ ដោយមានសត្វឃ្មុំហើរមកក្រេប។

**លទ្ធផលរយៈពេល ២ សប្ដាហ៍ក្រោយមក៖**

1. **ក្រុមទី ១** : ផ្កាទាំង ១០ បានក្រៀមស្វិត ហើយជ្រុះអស់ ដោយ **មិនបង្កើតបានជាផ្លែទេ**។
2. **ក្រុមទី ២** : ផ្កាទាំង ១០ បានជ្រុះស្រទាប់ពណ៌លឿងអស់ ហើយក្ដិប ខាងក្រោមចាប់ផ្ដើមរីកធំឡើងក្លាយជា **ផ្លែប៉េងប៉ោះតូចៗ**។

---

### សំណួរទី ១៖ មុខងាររបស់ផ្នែកផ្កា

"កញ្ចុំស្រទាប់ របស់ផ្កាមាពណ៌ឆើតឆាត និងមាននាទីទាក់ទាញសត្វល្អិត"។ ហេតុអ្វីបានជាការទាក់ទាញសត្វល្អិត មានសារៈសំខាន់ខ្លាំងម្ល៉េះចំពោះការបង្កើតផ្លែរបស់ដើមប៉េងប៉ោះ?

□A. ដើម្បីឱ្យសត្វល្អិតស៊ីស្រទាប់ផ្កាជាអាហារ។

□B. ដើម្បីឱ្យសត្វល្អិតជួយដឹកនាំគ្រាប់លំអងឈ្មោលទៅដាក់លើស្ទិចម៉ាត (លំអងញី)។

□C. ដើម្បីការពារកុំឱ្យផ្កាត្រូវកម្ដៅថ្ងៃខ្លាំងពេក។

□D. ដើម្បីឱ្យសត្វល្អិតជួយកំចាត់សត្រូវរុក្ខជាតិ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ពន្យល់ពីសារៈសំខាន់នៃការផ្ទេរលំអង ដោយសត្វល្អិត។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការវិភាគលទ្ធផលពិសោធន៍

ផ្អែកលើលទ្ធផលពិសោធន៍របស់វិបុល ចំពោះ ក្រុមទី ១ (ផ្កាគ្រប)៖ **ហេតុអ្វីបានជាផ្កាទាំងនោះជ្រុះចោលមិនបង្កើតជាផ្លែ?** សូមជ្រើសរើសការពន្យល់ដែលត្រឹមត្រូវបំផុតតាមបែបវិទ្យាសាស្ត្រ។

☐A. ព្រោះថង់ក្រដាសធ្វើឱ្យផ្កាថប់ដង្ហើម ខ្វះអុកស៊ីសែន។

☐B. ព្រោះថង់ក្រដាសបានបាំងពន្លឺព្រះអាទិត្យ ធ្វើឱ្យផ្កាមិនអាចធ្វើរស្មីសំយោគបាន។

☐C. ព្រោះថង់ក្រដាសបានរារាំងមិនឱ្យមាន ការបង្កកំណើត (លំអងឈ្មោលមិនអាចជួបអូវុល)

☐D. ព្រោះថង់ក្រដាសធ្វើឱ្យសីតុណ្ហភាពក្នុងផ្កាក្តៅខ្លាំងពេក។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគមូលហេតុនៃការបរាជ័យក្នុងការបង្កើតផ្លែ ដោយផ្អែកលើដំណើរការបន្តពូជ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៤ |

## សំណួរទី ៣៖ ការវាយតម្លៃសម្មតិកម្ម (កម្រិតខ្ពស់)

មិត្តរបស់វិបុលម្នាក់បាននិយាយថា៖ *"ប្រសិនបើវិបុលធ្វើពិសោធន៍ដូចគ្នានេះ ទៅលើ **ដើមពោត** (ដែលប្រើខ្យល់ដើម្បីបន្តពូជ មិនមែនសត្វល្អិត) នោះលទ្ធផលនឹងនៅតែដដែល គឺផ្កាដែលគ្របថង់នឹងមិនមានផ្លែដូចគ្នា។"* តើការសន្និដ្ឋានរបស់មិត្តគាត់ **ត្រឹមត្រូវ** ឬ **មិនត្រឹមត្រូវ**? សូមផ្តល់ហេតុផលដោយផ្អែកលើតួនាទីរបស់ "ថង់" និង "ភ្នាក់ងារបន្តពូជ (ខ្យល់)"។

- ចម្លើយ៖ ........................................................... (ត្រឹមត្រូវ / មិនត្រឹមត្រូវ)
- ហេតុផល៖ .......................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ផ្ទេរចំណេះដឹងទៅកាន់បរិបទថ្មី (សត្វល្អិត ខ្យល់) និងវាយតម្លៃផលប៉ះពាល់។ |
| កម្រិតពុទ្ធិ | វាយតម្លៃ |
| ទម្រង់សំណួរ | ចម្លើយខ្លី និងបកស្រាយ |
| កម្រិតសមត្ថភាព | កម្រិត ៥ |

**សំណួរទី ៤៖ អាថ៌កំបាំងនៃ "ផ្ការាត្រី" (កម្រិតខ្ពស់បំផុត)**

"កញ្ចុំស្រទាប់ មានពណ៌ឆើតឆាត សម្រាប់ទាក់ទាញសត្វល្អិត"។ ប៉ុន្តែ អ្នកវិទ្យាសាស្ត្របានរកឃើញរុក្ខជាតិមួយប្រភេទឈ្មោះថា "ផ្ការាត្រី" ដែលមានលក្ខណៈពិសេស៖

- វារីកតែនៅពេលយប់។
- ផ្ការបស់វាមាន **ពណ៌ស** (មិនឆើតឆាតទេ)។
- វាមាន **ក្លិនក្រអូប** ខ្លាំង។

**សំណួរ៖** ហេតុអ្វីបានជា "ផ្ការាត្រី" មិនចាំបាច់មានពណ៌ឆើតឆាត ប៉ុន្តែនៅតែអាចបន្តពូជបង្កើតផ្លែបាន? សូមពន្យល់ដោយផ្សារភ្ជាប់នឹង **ពេលវេលា** និង **របៀបទាក់ទាញសត្វ**។

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| | |
|---|---|
| លក្ខណៈ | ការពិពណ៌នា |
| លទ្ធផលសិក្សា | វិភាគពីការសម្របខ្លួនដែលផ្ទុយពីទ្រឹស្តីទូទៅក្នុងមេរៀន។ |
| កម្រិតពុទ្ធិ | វិភាគ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៦ |

# អត្រាកំណែ

**សំណួរទី ១៖**

- **ចម្លើយត្រូវ៖** B. ដើម្បីឱ្យសត្វល្អិតជួយដឹកនាំគ្រាប់លំអងឈ្មោលទៅដាក់លើស្ទិចម៉ាត។

**សំណួរទី១ ៖**

- **ចម្លើយត្រូវ៖** C. ព្រោះថង់ក្រដាសបានរារាំងមិនឱ្យមានការបង្កកំណើត (គ្រាប់លំអងមិនអាចជួបអូវុល)។

**សំណួរទី ៣៖**

- **ពិន្ទុពេញ :**
  - ចម្លើយ៖ ***ត្រឹមត្រូវ*** (ថង់នឹងនៅតែរារាំងការបន្តពូជ)។
  - ហេតុផល៖ ទោះបីជាដើមពោតមិនប្រើសត្វល្អិត (ប្រើខ្យល់) ក៏ដោយ ប៉ុន្តែ **ថង់** នឹងបិទជិតមិនឱ្យ ***ខ្យល់*** បក់យកលំអងចូលទៅក្នុងផ្កាបានទេ។ ដូច្នេះ ការបង្កកំណើតនៅតែមិនអាចកើតឡើងបានដដែល។
- **គ្មានពិន្ទុ :** ឆ្លើយខុស ឬឆ្លើយត្រូវតែហេតុផលមិនសមស្រប (ឧ. ព្រោះពោតក៏ត្រូវការឃ្មុំដែរ)។

**សំណួរទី ៤៖**

- **ពិន្ទុពេញ :** សិស្សត្រូវពន្យល់បាន ២ ចំណុចសំខាន់ៗ៖
  1. **ហេតុអ្វីមិនត្រូវការពណ៌៖** ដោយសារវារីកនៅ **ពេលយប់** ភាពងងឹតធ្វើឱ្យពណ៌ឆើតឆាតមិនមានប្រយោជន៍ (សត្វមើលមិនឃើញ)។ ពណ៌ស គឺគ្រប់គ្រាន់ដើម្បីផ្លាតពន្លឺព្រះចន្ទ ឬផ្កាយតិចៗ។
  2. **របៀបទាក់ទាញជំនួស៖** វាប្រើ ***ក្លិនក្រអូប*** ខ្លាំងដើម្បីទាក់ទាញសត្វល្អិតពេលយប់ (ដូចជាមេអំបៅយប់ ឬប្រចៀវ) ជំនួសឱ្យការប្រើពណ៌។
- **ពិន្ទុខ្លះ :** ឆ្លើយបានត្រឹមត្រូវតែមួយផ្នែក (ឧ. និយាយតែក្លិន តែមិននិយាយពីហេតុផលដែលមិនត្រូវការពណ៌)។
- **គ្មានពិន្ទុ :** ឆ្លើយថាមិនមានសត្វជួយ ឬឆ្លើយមិនសមហេតុផល។

# ជំពូកទី៣ កោសិកា

## មេរៀនទី១ រូបផ្តុំកោសិកា

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

តំណភ្ជាប់វីដេអូមេរៀន

## ប្រធានបទទី ៨ : បច្ចេកវិទ្យាវិទ្យាសាស្ត្រ និងការលូតលាស់នៃភាវៈរស់

### អត្ថបទ និង ស្ថានភាព ៖ ការស្វែងយល់ពីឯកតាគ្រឹះនៃជីវិត



នៅក្នុងមន្ទីរពិសោធន៍ សិស្សថ្នាក់ទី ៧ ពីររូបគឺ សុភី និង រតនា កំពុងប្រើប្រាស់ឧបករណ៍ពង្រីកដើម្បីសង្កេតមើលកោសិកា។ សុភីប្រើប្រាស់ កែវពង្រីក ដើម្បីពិនិត្យសន្លឹកឈើ ប៉ុន្តែនាងមើលមិនឃើញរូបផ្តុំខាងក្នុងឡើយ។ រតនាបានសម្រេចចិត្តប្រើប្រាស់ មីក្រូទស្សន៍អុបទិច ដើម្បីសង្កេតកោសិកាស្បែកខ្ទឹមបារាំង ដែលត្រូវបានគេជ្រលក់ពណ៌។ ពួកគេសង្កេតឃើញថា រុក្ខជាតិ និងសត្វសុទ្ធតែបង្កឡើងដោយកោសិកា ប៉ុន្តែមានលក្ខណៈខុសគ្នាខ្លះៗ ជាពិសេសលើផ្នែកដែលផ្តល់ភាពរឹងមាំ និងការគ្រប់គ្រងសកម្មភាពកោសិកា។

## សំណួរទី ១៖ រូបផ្គុំនៃកោសិកា

ចូរផ្គូផ្គងឈ្មោះរូបផ្គុំកោសិកានៅជួរ(A) ទៅនឹងនាទី/លក្ខណៈរបស់វានៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| រូបផ្គុំ | នាទី/លក្ខណៈ | ចម្លើយ |
|---|---|---|
| ១. ភ្នាសសៃលុយឡូស | ក. ត្រួតពិនិត្យរាល់សកម្មភាពរបស់កោសិកា | ១. ⇨ ............. |
| ២. វ៉ាគុយអូល | ខ. សារធាតុខាប់អន្ទិលដែលមានចលនាជានិច្ច | ២. ⇨ ............. |
| ៣. ស៊ីតូប្លាស | គ. ភ្នាសរឹងមាំដែលទ្រទ្រង់រុក្ខជាតិឱ្យលូតលាស់ខ្ពស់ | ៣. ⇨ ............. |
| ៤. ណ្វៃយ៉ូ | ឃ. ថង់សម្រាប់ស្តុកកាកសំណល់ ទឹក និងអាហារ | ៤. ⇨ ............. |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ឈ្មោះ និងនាទីនៃរូបផ្គុំនីមួយៗរបស់កោសិកា។ |
| កម្រិតពុទ្ធិ | ចងចាំ និងយល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការប្រើប្រាស់ឧបករណ៍ពង្រីក

យោងតាមអត្ថបទស្ថានភាព តើហេតុអ្វីបានជាសុភីមិនអាចមើលឃើញរូបផ្គុំខាងក្នុងនៃកោសិកាសន្លឹកឈើដោយប្រើកែវពង្រីក?

☐A. ព្រោះកែវពង្រីកមានអានុភាពពង្រីកទាបដែលមិនគ្រប់គ្រាន់សម្រាប់មើលកោសិកាបានឡើយ

☐B. ព្រោះកែវពង្រីកប្រើសម្រាប់តែសង្កេតសត្វល្អិតប៉ុណ្ណោះ។

☐C. ព្រោះកែវពង្រីកអាចមើលឃើញតែវត្ថុដែលមានពណ៌ស។

☐D. ព្រោះកែវពង្រីកគ្មានដងសម្រាប់កាន់ឱ្យបានត្រឹមត្រូវ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ប្រាប់ពីសមត្ថភាព និងដែនកំណត់នៃឧបករណ៍ពង្រីក ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ភាពខុសគ្នារវាងកោសិការុក្ខជាតិ និងកោសិកាសត្វ

ចូរគូសសញ្ញា ☑ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ទាំងកោសិការុក្ខជាតិ និងសត្វ សុទ្ធតែមានភ្នាសសែលុយឡូស។ | ☐ | ☐ |
| ២. ភ្នាសស៊ីតូប្លាសជាភ្នាសជ្រាបជ្រើស ដែលអនុញ្ញាតឱ្យសារធាតុមួយចំនួនចូលបាន។ | ☐ | ☐ |
| ៣. កោសិការុក្ខជាតិភាគច្រើនមានវ៉ាគុយអូលធំៗជាងកោសិកាសត្វ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកលក្ខណៈរួម និងលក្ខណៈខុសគ្នារវាងកោសិការុក្ខជាតិ និងសត្វ ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ អាថ៌កំបាំងនៃសំណើម និងភាពរឹងមាំរបស់រុក្ខជាតិ

នៅពេលយើងភ្លេចស្រោចទឹក រុក្ខជាតិចាប់ផ្តើមស្រពោន និងទន់ជ្រាយ។ ប៉ុន្តែនៅពេលយើងស្រោចទឹកបានគ្រប់គ្រាន់ រុក្ខជាតិឡើងរឹងមាំ និងស្រស់បំព្រងឡើងវិញ។

សំណួរ៖ តើរូបធាតុមួយណាដែលមានតួនាទីចម្បងក្នុងបាតុភូតនេះ? ចូរពន្យល់ពីយន្តការដែលកើតឡើងនៅក្នុងកោសិការុក្ខជាតិនោះ។

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស៖

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បកស្រាយទំនាក់ទំនងរវាងរូបធាតុកោសិកា និងស្ថានភាពរូបវិទ្យារបស់រុក្ខជាតិ ។ |
| កម្រិតពុទ្ធិ | វិភាគ និងអនុវត្តន៍ |
| ទម្រង់សំណួរ | ចម្លើយខ្លី |
| កម្រិតសមត្ថភាព | កម្រិត ៤ |

## សំណួរទី ៥៖ វិទ្យាសាស្ត្រនៃការបន្តពូជ និងការជំនួសកោសិកា

មនុស្សពេញវ័យមានកោសិការាប់កោដិ ប៉ុន្តែជារៀងរាល់ថ្ងៃ កោសិកាជាច្រើនត្រូវងាប់ទៅវិញ។

1. ឧបមាថា កោសិការបស់មនុស្សម្នាក់ឈប់ធ្វើ "ចំណែកកោសិកាលូតលាស់"។

..................................................................................................................................

..................................................................................................................................

..................................................................................................................................

2. **តើនឹងមានផលវិបាកអ្វីកើតឡើងចំពោះបុគ្គលនោះក្នុងរយៈពេលវែង?** ចូរផ្តល់ហេតុផលចំនួន ២ ដើម្បីគាំទ្រចម្លើយរបស់អ្នក ដោយផ្អែកលើអត្ថបទមេរៀន។

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ព្យាករណ៍ និងវាយតម្លៃពីសារៈសំខាន់នៃចំណែកកោសិកាចំពោះជីវិត ។ |
| កម្រិតពុទ្ធិ | បង្កើតថ្មី និងវាយតម្លៃ |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

- **ពិន្ទុពេញ៖**
  - ១ ⇨ គ. ភ្នាសរឹងមាំដែលទ្រទ្រង់រុក្ខជាតិឱ្យលូតលាស់ខ្ពស់
  - ២ ⇨ ឃ. ថង់សម្រាប់ស្តុកកាកសំណល់ ទឹក និងអាហារ
  - ៣ ⇨ ខ. សារធាតុខាប់អន្ទិលដែលមានចលនាជានិច្ច
  - ៤ ⇨ ក. ត្រួតពិនិត្យរាល់សកម្មភាពរបស់កោសិកា
- ត្រូវតែផ្គូផ្គងត្រូវទាំងអស់ទើបបានពិន្ទុ។

**សំណួរទី ២៖**

- **ចម្លើយត្រូវ៖** A. ព្រោះកែវពង្រីកមានអានុភាពពង្រីកទាបដែលមិនគ្រប់គ្រាន់សម្រាប់មើលកោសិកាបានឡើយ។

**សំណួរទី ៣៖**

- **ចម្លើយត្រូវ៖**
  - ១ ⇨ មិនពិត
  - ២ ⇨ ពិត
  - ៣ ⇨ ពិត

**សំណួរទី ៤៖**

- **ពិន្ទុពេញ៖** កំណត់បានថាជា **វ៉ាគុយអូល** ។
  - **ការពន្យល់៖** កាលណាវ៉ាគុយអូលពេញដោយទឹក វារីកប៉ោង ហើយធ្វើឱ្យកោសិការឹងមាំ (រុក្ខជាតិឡើងស្រស់វិញ)។ ប្រសិនបើខ្វះទឹក វ៉ាគុយអូលស្វិត ធ្វើឱ្យរុក្ខជាតិស្រពោន។
- **ពិន្ទុខ្លះ៖** ប្រាប់ឈ្មោះរូបធាតុត្រូវ តែការពន្យល់មិនច្បាស់លាស់។

**សំណួរទី ៥៖**

- **ពិន្ទុពេញ៖** បុគ្គលនោះនឹងមានបញ្ហាសុខភាពធ្ងន់ធ្ងរ ឬឈានដល់មរណភាព។
  - **ហេតុផល ១៖** មិនអាចជំនួសកោសិកាដែលងាប់ជារៀងរាល់ថ្ងៃបាន (ដូចជាកោសិកាស្បែក ឬឈាម)។
  - **ហេតុផល ២៖** សរីរាង្គកាយឈប់លូតលាស់ និងមិនអាចជួសជុលរបួសផ្សេងៗបាន (ព្រោះគ្មានកោសិកាថ្មីបង្កើតឡើង)។
- **ពិន្ទុខ្លះ៖** ឆ្លើយត្រូវតែមួយហេតុផល ឬចម្លើយមិនទាន់គ្រប់ជ្រុងជ្រោយ។

# ប្រធានបទទី ៩ : កោសិកា - ឯកតាគ្រឹះនៃជីវិត

## អត្ថបទខ្លី៖ ពិភពតូចល្អិតក្រោមមីក្រូទស្សន៍

នៅក្នុងម៉ោងពិសោធន៍វិទ្យាសាស្ត្រ សិស្សថ្នាក់ទី ៧ បានសង្កេតមើលកោសិកាពីរប្រភេទខុសគ្នា។ កោសិកាទី ១ យកចេញពី ស្រទាប់ខ្ទឹមបារាំង និងកោសិកាទី ២ យកចេញពី ភ្នាសថ្ពាល់មនុស្ស។ ដើម្បីមើលឃើញឱ្យច្បាស់ ពួកគេបានប្រើប្រាស់ មីក្រូទស្សន៍អុបទិច ដែលមានអានុភាពពង្រីកខ្ពស់។




សិស្សសង្កេតឃើញថា កោសិកាខ្ទឹមបារាំងមានរាងជាចតុកោណកែងរៀបរយ និងមានភ្នាសក្រាស់ការពារពីខាងក្រៅ ចំណែកកោសិកាថ្ពាល់មនុស្សមានរាងមិនទៀងទាត់ និងមានភ្នាសស្តើងទន់។ នៅចំកណ្តាលកោសិកាទាំងពីរ មានចំណុចដិតមួយដែលគ្រប់គ្រងរាល់សកម្មភាពរបស់កោសិកា។ ពួកគេក៏បានដឹងថា មនុស្សយើងធំធាត់ទៅបាន ក៏ដោយសារតែកោសិកាមេបន្តពូជបង្កើតកោសិកាកូនថ្មីៗជាច្រើន។

## សំណួរទី ១៖ រូបផ្តុំកោសិកា

នៅក្នុងកោសិកាដែលសិស្សបានសង្កេត មានរូបផ្តុំមួយចំនួនដែលមានវត្តមានតែនៅក្នុងកោសិការុក្ខជាតិប៉ុណ្ណោះ។

ចូរគូសសញ្ញា ☑ ក្នុងប្រអប់ខាងក្រោមឱ្យបានត្រឹមត្រូវ ប្រសិនបើរូបផ្តុំនោះមាននៅក្នុងកោសិកា ៖

| ឈ្មោះរូបផ្តុំកោសិកា | មាននៅក្នុងកោសិការុក្ខជាតិ | មាននៅក្នុងកោសិកាសត្វ |
|---|---|---|
| ១. ភ្នាសសែលុយឡូស | ☐ | ☐ |
| ២. ណៃយ៉ូ | ☐ | ☐ |
| ៣. វ៉ាគុយអូលធំ | ☐ | ☐ |
| ៤. ភ្នាសស៊ីតូប្លាស | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ និងបែងចែករូបផ្តុំរួម និងរូបផ្តុំដោយឡែករវាងកោសិការុក្ខជាតិ និងសត្វ។ |
| កម្រិតពុទ្ធិ | ចងចាំ និងយល់ដឹង |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ នាទីរបស់រូបផ្តុំកោសិកា

តើសមាសភាគមួយណាដែលមាននាទី «ត្រួតពិនិត្យរាល់សកម្មភាពរបស់កោសិកា និងផ្ទុកព័ត៌មានសេនេទិច (ក្រូម៉ូសូម)»?

☐A. ស៊ីតូប្លាស ☐B. ភ្នាសសែលុយឡូស ☐C. វ៉ាគុយអូល ☐D. ណ្វៃយ៉ូ

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់នាទីសំខាន់របស់ណ្វៃយ៉ូក្នុងកោសិកា។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការបន្តពូជរបស់កោសិកា

សិស្សម្នាក់បានសួរថា៖ «ចុះបើកោសិកាងាប់ តើសារពាង្គកាយនឹងបាត់បង់កោសិកានោះជារៀងរហូតមែនទេ?»។ គ្រូបានពន្យល់អំពី «ចំណែកកោសិកាលូតលាស់»។

តើការពន្យល់ខាងក្រោមមួយណាដែលពិពណ៌នាត្រឹមត្រូវបំផុតអំពី កោសិកាកូន ដែលកើតចេញពីចំណែកកោសិកាលូតលាស់?

☐A. កោសិកាកូនមានរូបរាងខុសគ្នាស្រឡះពីកោសិកាមេ។

☐B. កោសិកាកូនមានលក្ខណៈដូចគ្នាបេះបិទទៅនឹងកោសិកាមេ។

☐C. កោសិកាកូនមានទំហំធំជាងកោសិកាមេជានិច្ច។

☐D. កោសិកាកូនមិនមានណ្វៃយ៉ូដូចកោសិកាមេឡើយ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ពីលទ្ធផលនៃចំណែកកោសិកាលូតលាស់។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

---

## សំណួរទី ៤៖ បច្ចេកវិទ្យា និងការសង្កេត

កាលពីជំនាន់ដើម គេប្រើ មីក្រូទស្សន៍អុបទិច ដែលមើលឃើញរូបផ្ដុំបានខ្លះៗ។ បច្ចុប្បន្ន គេមាន មីក្រូទស្សន៍អេឡិចត្រូនិច។

តើចំណុចមួយណាជាហេតុផលសំខាន់ដែលអ្នកវិទ្យាសាស្ត្រប្រើមីក្រូទស្សន៍អេឡិចត្រូនិចដើម្បី សិក្សាពីកោសិកា?

□A. ព្រោះវាអាចពង្រីករូបភាពបានពី ៣ ទៅ ២០ ដង។

□B. ព្រោះវាមានតម្លៃថោក និងងាយស្រួលប្រើប្រាស់ជាងកែវពង្រីក។

□C. ព្រោះវាមានអានុភាពពង្រីកខ្ពស់ដែលអាចមើលឃើញរូបផ្ដុំលម្អិតបំផុត។

□D. ព្រោះវាមានកម្រិតភាពច្បាស់ខ្ពស់ដែលអាចមើលឃើញកោសិកានៅមានជីវិត។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ប្រៀបធៀបសមត្ថភាពឧបករណ៍ពង្រីកផ្សេងៗក្នុងវិទ្យាសាស្ត្រ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

---

## សំណួរទី ៥៖ ការប្រែប្រួល និងផលប៉ះពាល់

វ៉ាគុយអូល នៅក្នុងកោសិការុក្ខជាតិមាននាទីស្តុកទឹក។ កាលណាវ៉ាគុយអូលពេញដោយទឹក វារីក ប៉ោងធ្វើឱ្យរុក្ខជាតិរឹងមាំ។

ឧបមាថាគេដាក់កោសិការុក្ខជាតិក្នុងមជ្ឈដ្ឋានមួយដែលធ្វើឱ្យទឹកងាយចាកចេញពីវ៉ាគុយអូល (រុក្ខជាតិខ្វះទឹក)។ **តើនឹងមានផលប៉ះពាល់អ្វីកើតឡើងចំពោះ រូបរាងកោសិកា និង សភាពខាងក្រៅនៃរុក្ខជាតិ? សូមពន្យល់។**

.....................................................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគ និងព្យាករណ៍ពីទំនាក់ទំនងរវាងបរិមាណទឹកក្នុងរ៉ាគុយអូល និងលក្ខណៈរូបវិទ្យារបស់រុក្ខជាតិ។ |
| កម្រិតពុទ្ធិ | បង្កើតថ្មី និងវាយតម្លៃ |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៤ |

# អត្រាកំណែ

**សំណួរទី ១៖**

- **ចម្លើយត្រូវ៖**
  - **១. ភ្នាសសែលុយឡូស** ⇨ កោសិការុក្ខជាតិ៖ មាន, កោសិកាសត្វ៖ គ្មាន
  - **២. ណ្វៃយ៉ូ** ⇨ កោសិការុក្ខជាតិ៖ មាន, កោសិកាសត្វ៖ មាន
  - **៣. វ៉ាគុយអូលធំ** ⇨ កោសិការុក្ខជាតិ៖ មាន, កោសិកាសត្វ៖ គ្មាន (ឬមានតូចៗ)
  - **៤. ភ្នាសស៊ីតូប្លាស** ⇨ កោសិការុក្ខជាតិ៖ មាន, កោសិកាសត្វ៖ មាន
- ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ

**សំណួរទី ២៖**

- **ចម្លើយត្រូវ៖** D. ណ្វៃយ៉ូ

**សំណួរទី ៣៖**

- **ចម្លើយត្រូវ៖** B. កោសិកាកូនមានលក្ខណៈដូចគ្នាបេះបិទទៅនឹងកោសិកាមេ

**សំណួរទី ៤៖**

- **ចម្លើយត្រូវ៖** C. ព្រោះវាមានអានុភាពពង្រីកខ្ពស់ដែលអាចមើលឃើញរូបផ្ដុំលម្អិតបំផុត។ (មិនមែន **D.** ព្រោះលក្ខខណ្ឌនៃមីក្រូទស្សន៍អេឡិចត្រូនិច តម្រូវឱ្យសម្លាប់កោសិកាជាមុនសិន ទើបអាចមើលឃើញ។)

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវទាំងពីរផ្នែក៖
  - **រូបរាងកោសិកា៖** វ៉ាគុយអូលនឹងរួមស្វិត បណ្ដាលឱ្យកោសិកាបាត់បង់ភាពប៉ោង (បាត់បង់សម្ពាធទ្រទ្រង់)។
  - **សភាពរុក្ខជាតិ៖** រុក្ខជាតិនឹងស្រពោន ឬទន់ជ្រាយ (បាត់បង់ភាពរឹងមាំ)។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែផ្នែកណាមួយ (ឧ. ត្រូវតែរឿងរុក្ខជាតិស្រពោន តែមិនបានពន្យល់ពីកោសិកា)។
- **គ្មានពិន្ទុ** : ឆ្លើយខុសទាំងស្រុង ឬមិនឆ្លើយ។

## មេរៀនទី២ កោសិការុក្ខជាតិ

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ១០ : ថាមពលពណ៌បៃតង និងរូបធាតុកោសិកា

### អត្ថបទខ្លី៖ ការអង្កេតកោសិការុក្ខជាតិ




នៅក្នុងមន្ទីរពិសោធន៍ សិស្សពីរក្រុមបានសង្កេតមើលកោសិការុក្ខជាតិខុសគ្នា៖

- **ក្រុមទី ១:** សង្កេតមើល **អេពីឌែមមើមខ្ទឹមបារាំង**។ ពួកគេឃើញកោសិកាមានរាងពហុកោណតម្រៀបជាប់គ្នា ប៉ុន្តែគ្មានពណ៌បៃតងឡើយ។
- **ក្រុមទី ២:** សង្កេតមើល **ស្លឹកអេឡូដេ (Elodea)**។ ពួកគេឃើញកោសិកាមានរាងប្រហាក់ប្រហែលគ្នា ប៉ុន្តែមានគ្រាប់តូចៗពណ៌បៃតងជាច្រើនដែលធ្វើចលនាជុំវិញវ៉ាគុយអូល។

គ្រូបានពន្យល់ថា ទោះបីជាកោសិកាទាំងពីរមានលក្ខណៈរួមជាច្រើន ប៉ុន្តែវត្តមាននៃធាតុកោសិកាពណ៌បៃតងអាស្រ័យលើនាទីរបស់វានៅក្នុងរុក្ខជាតិ។

### សំណួរទី ១៖ លក្ខណៈសម្គាល់កោសិការុក្ខជាតិ

តើភ្នាសមួយណាដែលផ្តល់ភាពរឹងមាំដល់រុក្ខជាតិ និងការពារភ្នាសស៊ីតូប្លាសពីខាងក្រៅ?

| | |
|---|---|
| ☐A. ភ្នាសកោសិកា | ☐B. ភ្នាសសែលុយឡូស |
| ☐C. ភ្នាសណ្វៃយ៉ូ | ☐D. ភ្នាសវ៉ាគុយអូល |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់នាទីរបស់ភ្នាសសែលុយឡូសក្នុងកោសិការុក្ខជាតិ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការវិភាគភាពខុសគ្នា

ហេតុអ្វីបានជាក្រុមទី ១ មិនឃើញ មានក្លរ៉ូប្លាស (ជាតុកោសិកាពណ៌បៃតង) នៅក្នុងមើមខ្ទឹមបារាំង? **ចូរជ្រើសរើសមូលហេតុដែលសមហេតុផលបំផុត។**

☐A. ព្រោះមើមខ្ទឹមបារាំងស្ថិតនៅក្រោមដី មិនត្រូវការធ្វើរស្មីសំយោគ។

☐B. ព្រោះមើមខ្ទឹមបារាំងជាប្រភេទកោសិកាសត្វ។

☐C. ព្រោះមើមខ្ទឹមបារាំងមានភ្នាសសែលុយឡូសស្តើងពេក។

☐D. ព្រោះមើមខ្ទឹមបារាំងមិនមានវ៉ាគុយអូលសម្រាប់ក្លរ៉ូប្លាសធ្វើចលនា។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បកស្រាយទំនាក់ទំនងរវាងទីកន្លែងរស់នៅ និងវត្តមានជាតុកោសិកា។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៣៖ ការបកស្រាយបាតុភូត

នៅក្នុងកោសិកាស្លឹកអេឡូដេ គេសង្កេតឃើញ ក្លរ៉ូប្លាស ធ្វើចលនាជុំវិញវ៉ាគុយអូល។

**ចូរគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖**

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ក្លរ៉ូប្លាសមាននាទីផលិតអាហារតាមរយៈរស្មីសំយោគ។ | ☐ | ☐ |
| ២. វ៉ាគុយអូលជាកន្លែងផ្ទុក DNA របស់កោសិកា។ | ☐ | ☐ |
| ៣. ក្លរ៉ូហ្វីល គឺជាសារធាតុពណ៌បៃតងដែលមាននៅក្នុងក្លរ៉ូប្លាស។ | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកនាទីរវាង ក្លរ៉ូប្លាស រ៉ាគុយអូល និងណ្វៃយ៉ូ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ៤៖ ការវិភាគលើនាទីបញ្ជា

ប្រសិនបើអ្នកវិទ្យាសាស្ត្រកែប្រែ DNA ដែលស្ថិតនៅក្នុង ណ្វៃយ៉ូ របស់រុក្ខជាតិ **តើវាអាចប៉ះពាល់ដល់ការលូតលាស់របស់រុក្ខជាតិនោះដែរឬទេ?**

□A. មិនប៉ះពាល់ទេ ព្រោះ DNA គ្រាន់តែជាពណ៌របស់កោសិកា។

□B. មិនប៉ះពាល់ទេ ព្រោះរុក្ខជាតិប្រើប្រាស់តែក្លរ៉ូប្លាសដើម្បីទ្រទ្រង់លូតលាស់។

□C. ប៉ះពាល់ ព្រោះណ្វៃយ៉ូគ្រប់គ្រងរាល់សកម្មភាព និងការលូតលាស់របស់កោសិកា។

□D. ប៉ះពាល់ ព្រោះវាធ្វើឱ្យភ្នាសសែលុយឡូសខូចទ្រង់ទ្រាយ ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃពីសារៈសំខាន់នៃព័ត៌មានសេនេទិចក្នុងណ្វៃយ៉ូ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការព្យាករណ៍ និងការដោះស្រាយបញ្ហា

គេដាក់ស្លឹកអេឡូដេទៅក្នុងទីងងឹតដែលគ្មានពន្លឺព្រះអាទិត្យទាល់តែសោះក្នុងរយៈពេល ១ ខែ។

1. តើអ្នកព្យាករណ៍ថានឹងមានការប្រែប្រួលអ្វីកើតឡើងចំពោះ ក្លរ៉ូប្លាស?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

2. តើវាប៉ះពាល់ដល់រុក្ខជាតិទាំងមូលយ៉ាងដូចម្ដេច? សូមពន្យល់ដោយផ្អែកលើនាទីរបស់ក្លរ៉ូប្លាស។

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគផលប៉ះពាល់នៃកត្តាខាងក្រៅលើមុខងារជាតុកោសិកា។ |
| កម្រិតពុទ្ធិ | បង្កើតថ្មី និងវាយតម្លៃ |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

- ចម្លើយត្រូវ៖ **B. ភ្នាសសែលុយឡូស**

**សំណួរទី ២៖**

- ចម្លើយត្រូវ៖ **A. ព្រោះមើមខ្ទឹមបារាំងស្ថិតនៅក្រោមដី មិនត្រូវការធ្វើរស្មីសំយោគ** (វាមាននាទីស្តុកអាហារ មិនមែនផលិតអាហារដោយពន្លឺព្រះអាទិត្យទេ)។

**សំណួរទី ៣៖**

- ១. ពិត (ក្លរ៉ូប្លាសធ្វើរស្មីសំយោគ)
- ២. មិនពិត (ណៃ្វយ៉ូជាអ្នកផ្ទុក DNA មិនមែនវ៉ាគុយអូលទេ)
- ៣. ពិត (ក្លរ៉ូហ្វីលជាសារធាតុពណ៌ក្នុងក្លរ៉ូប្លាស)
- (ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)

**សំណួរទី ៤៖**

- ចម្លើយត្រូវ៖ **C. ប៉ះពាល់ ព្រោះណៃ្វយ៉ូគ្រប់គ្រងរាល់សកម្មភាព និងការលូតលាស់របស់កោសិកា។**

**សំណួរទី ៥៖**

- **ពិន្ទុពេញ:** ឆ្លើយត្រូវទាំងពីរផ្នែក៖
    1. **ក្លរ៉ូប្លាស៖** នឹងបាត់បង់នាទី ឬចុះខ្សោយ (ដោយសារគ្មានពន្លឺសម្រាប់ធ្វើរស្មីសំយោគ)។
    2. **ផលប៉ះពាល់៖** រុក្ខជាតិនឹងគ្មានអាហារចិញ្ចឹម ធ្វើឱ្យស្លឹកប្រែជាពណ៌ស្លេក លែងលូតលាស់ និងអាចងាប់បាន។
- **ពិន្ទុខ្លះ :** ឆ្លើយត្រូវតែម្ខាង (ឧ. ឆ្លើយថាវានឹងងាប់ តែមិនបានពន្យល់ពីទំនាក់ទំនងជាមួយរស្មីសំយោគ)។
- **គ្មានពិន្ទុ :** ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ១១ : ភាពខុសប្លែកនៃពណ៌ និងរូបផ្តុំកោសិការុក្ខជាតិ

## អត្ថបទខ្លី៖ ពណ៌នៃរុក្ខជាតិ និងការរស់រាន



សិស្សមួយក្រុមបានធ្វើការពិសោធន៍សង្កេតមើលផ្នែកផ្សេងៗនៃរុក្ខជាតិក្រោមមីក្រូទស្សន៍។ ពួកគេបានកត់សម្គាល់ឃើញថា កោសិកាពីផ្នែកខុសៗគ្នានៃរុក្ខជាតិ បង្ហាញលក្ខណៈរូបផ្តុំ និងពណ៌មិនដូចគ្នាឡើយ៖

- **ផ្នែកទី ១៖** នៅក្នុងកោសិកាស្លឹក ពួកគេឃើញមានគ្រាប់ពណ៌បៃតងជាច្រើន។
- **ផ្នែកទី ២៖** នៅក្នុងកោសិកាមើមដំឡូងបារាំង ពួកគេឃើញមានគ្រាប់គ្មានពណ៌ ដែលផ្ទុកទៅដោយអាមីដុង។
- **ផ្នែកទី ៣៖** នៅក្នុងកោសិកាស្រទាប់ផ្កាពណ៌ក្រហម ពួកគេឃើញមានធាតុកោសិកាម្យ៉ាងផ្ទុកសារធាតុពណ៌ការ៉ូតែន។

គ្រូបានពន្យល់ថា លក្ខណៈពិសេសទាំងនេះ រួមទាំងភ្នាសគ្រោងដ៏រឹងមាំ គឺជាអ្វីដែលធ្វើឱ្យរុក្ខជាតិខុសប្លែកពីសត្វ។

## សំណួរទី ១៖ ភ្នាសការពារ និងទម្រង់កោសិកា

តើភ្នាសម្យ៉ាងដែលបង្កឡើងពីជាតិសែលុយឡូស ហើយផ្តល់ទម្រង់ជាក់លាក់ដល់កោសិការុក្ខជាតិហៅថាអ្វី?

| | |
|---|---|
| ☐A. ភ្នាសកោសិកា | ☐B. ភ្នាសគ្រោង ឬភ្នាសសែលុយឡូស |
| ☐C. ភ្នាសស៊ីតូប្លាស | ☐D. ភ្នាសវ៉ាគុយអូល |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ឈ្មោះ និងសមាសធាតុបង្កនៃភ្នាសគ្រោងរុក្ខជាតិ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការបែងចែកប្រភេទប្លាស

តើសារពាង្គកាយ ឬផ្នែកនៃរុក្ខជាតិខាងក្រោម ផ្ទុកនូវប្លាសប្រភេទអ្វីខ្លះ? ចូរផ្គូផ្គងផ្នែក(A) ទៅនឹងផ្នែក (B) ឱ្យបានត្រឹមត្រូវ៖

| ផ្នែកនៃរុក្ខជាតិ (A) | ប្រភេទប្លាស (B) | ចម្លើយ |
|---|---|---|
| ១. ស្លឹកឈើពណ៌បៃតង | ក. ក្រូម៉ូប្លាស (ផ្ទុកពណ៌ក្រហម/លឿង) | ១ ⇨ ...... |
| ២. មើមដំឡូងជ្វា (ផ្ទុកអាមីដុង) | ខ. ក្លរ៉ូប្លាស (ផ្ទុកពណ៌បៃតង) | ២ ⇨ ...... |
| ៣. ផ្លែម្ទេសទុំ ឬផ្កាពណ៌លឿង | គ. អាមីឡូប្លាស (គ្មានពណ៌) | ៣ ⇨ ...... |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកប្រភេទប្លាសតាមរយៈមុខងារ និងពណ៌។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ នាទីរបស់វ៉ាគុយអូល

នៅក្នុងកោសិការុក្ខជាតិ វ៉ាគុយអូលដើរតួនាទីយ៉ាងសំខាន់។ តើការពណ៌នាណាខ្លះដែលត្រឹមត្រូវអំពី វ៉ាគុយអូល? **(អាចជ្រើសរើសបានលើសពីមួយ)**

☐A. វាជាថង់មួយស្ថិតនៅក្នុងស៊ីតូប្លាស។

☐B. វាផ្ទុកអាហារ និងកាកសំណល់ដែលកោសិកាត្រូវការ ឬចោល។

☐C. វាមាននាទីផ្តល់ព័ត៌មានសេនេទិចដល់កោសិកា។

☐D. វាបំពេញទៅដោយវត្ថុរាវម្យ៉ាងហៅថា រសវ៉ាគុយអូល។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់លក្ខណៈ និងនាទីរបស់វាគុយអូលក្នុងកោសិការុក្ខជាតិ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស (ជម្រើសច្រើន) |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវិភាគប្រៀបធៀប

ហេតុអ្វីបានជាគេចាត់ទុក "ភ្នាសសែលុយឡូស" ជាលក្ខណៈពិសេសមួយសម្រាប់សម្គាល់កោសិការុក្ខជាតិ?

□A. ព្រោះវាមានសភាពទន់ ដែលធ្វើឱ្យកោសិកាងាយប្តូររូបរាង។

□B. ព្រោះវាមានវត្តមានទាំងនៅក្នុងកោសិកាសត្វ និងកោសិការុក្ខជាតិ។

□C. ព្រោះវាផ្តល់ភាពរឹងមាំ និងមិនមានចំពោះកោសិកាសត្វឡើយ។

□D. ព្រោះវាជាកន្លែងធ្វើរស្មីសំយោគដ៏សំខាន់របស់រុក្ខជាតិ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកភាពខុសគ្នារវាងកោសិការុក្ខជាតិ និងសត្វតាមរយៈភ្នាសគ្រោង។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគ និងការព្យាករណ៍

ប្រសិនបើគេធ្វើការពិសោធន៍ដោយដកយក ក្លរ៉ូប្លាស ទាំងអស់ចេញពីកោសិកាស្លឹករបស់រុក្ខជាតិម្យ៉ាង ប៉ុន្តែរក្សាទុក អាមីឡូប្លាស ឱ្យនៅដដែល។

1. តើរុក្ខជាតិនោះនៅតែអាចផលិតអាហារថ្មីៗដោយខ្លួនឯងបានទៀតដែរឬទេ?

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

2. តើវាអាចរស់រានបានយូរប៉ុណ្ណា ប្រសិនបើវាមានអាមីឡូប្លាសច្រើន? សូមពន្យល់ដោយផ្អែកលើនាទីប្លាសនីមួយៗ។

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគ និងវាយតម្លៃនាទីរបស់ប្លាសចំពោះការរស់រានរបស់រុក្ខជាតិ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

- ចម្លើយត្រូវ៖ **D. ភ្នាសគ្រោង ឬភ្នាសសែលុយឡូស**

**សំណួរទី ២៖**

- ចម្លើយត្រូវ៖
    - ១ ⇨ ខ. ក្លរ៉ូប្លាស (ផ្ទុកពណ៌បៃតង)
    - ២ ⇨ គ. អាមីឡូប្លាស (គ្មានពណ៌)
    - ៣ ⇨ ក. ក្រូម៉ូប្លាស (ផ្ទុកពណ៌ក្រហម/លឿង)

**សំណួរទី ៣៖**

- ចម្លើយត្រូវ៖
    - A. វាជាថង់មួយស្ថិតនៅក្នុងស៊ីតូប្លាស។
    - B. វាបំពេញទៅដោយវត្ថុរាវម្យ៉ាងហៅថា រសវ៉ាគុយអូល។
    - D. វាផ្ទុកអាហារ និងកាកសំណល់ដែលកោសិកាត្រូវការ ឬចោល។
- ត្រូវគូសឱ្យគ្រប់ទើបបានពិន្ទុពេញ

**សំណួរទី ៤៖**

- ចម្លើយត្រូវ៖ **C. ព្រោះវាផ្តល់ភាពរឹងមាំ និងមិនមានចំពោះកោសិកាសត្វឡើយ**

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវទាំងពីរផ្នែក៖
    1. **ការផលិតអាហារ៖** មិនអាចផលិតអាហារថ្មីបានទេ ព្រោះកោសិកាគ្មានក្លរ៉ូប្លាសសម្រាប់ធ្វើរស្មីសំយោគ។
    2. **ការរស់រាន៖** រុក្ខជាតិអាចរស់នៅបានមួយរយៈពេលខ្លី ដោយសារវាប្រើប្រាស់អាហារបម្រុង (អាមីដុង) ដែលមានស្រាប់នៅក្នុង **អាមីឡូប្លាស**។ ប៉ុន្តែនៅពេលអាមីដុងអស់ វានឹងងាប់។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. ឆ្លើយថារស់បានមួយរយៈ តែមិនបានបញ្ជាក់ពីការផលិតអាហារថ្មី)។
- **គ្មានពិន្ទុ** : ឆ្លើយខុសទាំងស្រុង ឬមិនឆ្លើយ។

# ប្រធានបទ ទី១២ : រុក្ខជាតិ និងតុល្យភាពនៃជីវិត

## អត្ថបទខ្លី៖ គុណតម្លៃនៃពណ៌បៃតង




រុក្ខជាតិត្រូវបានចាត់ទុកជាសម្បត្តិដ៏មហាសាលរបស់មនុស្សជាតិ។ មិនត្រឹមតែផ្តល់នូវអាហារ និងឱសថសម្រាប់ព្យាបាលរោគប៉ុណ្ណោះទេ ប៉ុន្តែព្រៃឈើ និងរុក្ខជាតិដើរតួនាទីជា "របាំងការពារ" ដ៏រឹងមាំសម្រាប់ភពផែនដី។ នៅក្នុងតំបន់មួយដែលតែងតែរងគ្រោះដោយទឹកជំនន់ និងខ្យល់ព្យុះ អ្នកវិទ្យាសាស្ត្របានណែនាំឱ្យសហគមន៍ដាំដើមឈើឱ្យបានច្រើននៅតាមតំបន់មាត់ទន្លេ និងតំបន់ភ្នំ ដើម្បីទប់ស្កាត់ការហូរច្រោះដី និងរក្សាតុល្យភាពធាតុអាកាស។

---

### សំណួរទី ១៖ ការបែងចែកប្រភេទរុក្ខជាតិ

ប្រសិនបើយើងដាំរុក្ខជាតិដើម្បីយកទៅកែច្នៃក្នុងរោងចក្រធ្វើជាសម្លៀកបំពាក់ ឬក្រដាស តើរុក្ខជាតិទាំងនោះស្ថិតក្នុងក្រុមអ្វី?

□A. រុក្ខជាតិលំអ □B. រុក្ខជាតិឱសថ

□C. រុក្ខជាតិឧស្សាហកម្ម □D. រុក្ខជាតិពុល

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ប្រភេទរុក្ខជាតិតាមរយៈការប្រើប្រាស់របស់មនុស្ស។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ សារប្រយោជន៍ចំពោះបរិស្ថាន

តើចំណុចខាងក្រោមមួយណាដែលបញ្ជាក់ពីប្រយោជន៍របស់រុក្ខជាតិក្នុងការ "ទប់ស្កាត់បម្រែបម្រួលអាកាសធាតុ"?

□A. រុក្ខជាតិផ្តល់អុស និងធ្យូងសម្រាប់ធ្វើជាថាមពល។

□B. រុក្ខជាតិអាចថែរក្សាធាតុអាកាសមិនឱ្យមានបម្រែបម្រួលខ្លាំង និងទាក់ទាញទឹកភ្លៀង។

□C. រុក្ខជាតិអាចយកទៅធ្វើជាគ្រឿងសង្ហារិមលម្អផ្ទះ។

□D. រុក្ខជាតិផ្តល់ទីជម្រកដល់សត្វស្រុក។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីតួនាទីរបស់រុក្ខជាតិចំពោះអាកាសធាតុ និងបរិស្ថាន។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគលើសុខភាព និងសេដ្ឋកិច្ច

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. មនុស្សអាចរស់នៅបានយ៉ាងសុខស្រួលទោះបីគ្មានរុក្ខជាតិ និងសត្វក៏ដោយ។ | ☐ | ☐ |
| ២. រុក្ខជាតិមួយចំនួនអាចយកទៅធ្វើជាឱសថសម្រាប់ព្យាបាលរោគមនុស្ស និងសត្វ។ | ☐ | ☐ |
| ៣. ការដាំរុក្ខជាតិលម្អអាចជួយទាក់ទាញភ្ញៀវទេសចរឱ្យមកកម្សាន្ត។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើសារៈសំខាន់ចម្រុះរបស់រុក្ខជាតិចំពោះជីវិតមនុស្ស។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការបកស្រាយហេតុផលវិទ្យាសាស្ត្រ

ហេតុអ្វីបានជាការដាំដើមឈើនៅតាមតំបន់ភ្នំ ឬមាត់ទន្លេ អាចជួយ "ទប់ស្កាត់ការហូរច្រោះដី" និង "ទប់ទឹកជំនន់" បាន?

□A. ព្រោះស្លឹកឈើជួយបាំងពន្លឺព្រះអាទិត្យមិនឱ្យដីស្ងួត។

□B. ព្រោះឫសរុក្ខជាតិជួយតោងដីឱ្យជាប់ និងជួយស្រូបយកទឹកភ្លៀងចូលក្នុងដី។

□C. ព្រោះដើមឈើធ្វើឱ្យទឹកភ្លៀងធ្លាក់មកកាន់តែច្រើនជាងមុន។

□D. ព្រោះរុក្ខជាតិបញ្ចេញឧស្ម័នអុកស៊ីសែនដែលធ្វើឱ្យទឹកហូរយឺត។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បកស្រាយពីតួនាទីរបស់រុក្ខជាតិក្នុងការការពារដី និងទឹក។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគផលប៉ះពាល់ និងការដោះស្រាយបញ្ហា

នៅក្នុងភូមិមួយ គេបានកាប់ឆ្ការព្រៃឈើទាំងអស់ដើម្បីយកដីធ្វើការសាងសង់រោងចក្រ និងផ្ទះសម្បែង។ មួយឆ្នាំក្រោយមក នៅពេលមានភ្លៀងធ្លាក់ខ្លាំង ភូមិនោះរងគ្រោះដោយការបាក់ដី និងទឹកជំនន់យ៉ាងធ្ងន់ធ្ងរ។

1. តើការកាប់ព្រៃឈើមានទំនាក់ទំនងយ៉ាងដូចម្តេចទៅនឹងគ្រោះមហន្តរាយខាងលើ?

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

2. ប្រសិនបើអ្នកជាមេភូមិ តើអ្នកនឹងដាក់ចេញនូវវិធានការអ្វីខ្លះដើម្បីការពារភូមិពីគ្រោះធម្មជាតិនៅឆ្នាំក្រោយៗទៀត? សូមផ្តល់ហេតុផល។

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគផលវិបាកនៃការបាត់បង់រុក្ខជាតិ និងស្នើដំណោះស្រាយប្រកបដោយចីរភាព។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាគំណៃ

**សំណួរទី ១៖**

- ចម្លើយត្រូវ៖ **C. រុក្ខជាតិឧស្សាហកម្ម**

**សំណួរទី ២៖**

- ចម្លើយត្រូវ៖ **B. រុក្ខជាតិអាចថែរក្សាធាតុអាកាសមិនឱ្យមានបម្រែបម្រួលខ្លាំង និងទាក់ទាញទឹកភ្លៀង**

**សំណួរទី ៣៖**

- ១. មិនពិត (មនុស្សមិនអាចរស់បានដោយគ្មានរុក្ខជាតិ និងសត្វឡើយ)
- ២. ពិត (រុក្ខជាតិអាចធ្វើជាឱសថ)
- ៣. ពិត (រុក្ខជាតិលម្អទាក់ទាញទេសចរ)
- ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ

**សំណួរទី ៤៖**

- ចម្លើយត្រូវ៖ **B. ព្រោះឫសរុក្ខជាតិជួយតោងដីឱ្យជាប់ និងជួយស្រូបយកទឹកភ្លៀងចូលក្នុងដី**

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ទំនាក់ទំនង៖** ការកាប់ព្រៃឈើធ្វើឱ្យដីបាត់បង់ឫសឈើសម្រាប់តោងជញ្ជាប់ និងបាត់បង់សមត្ថភាពស្រូបទឹក នាំឱ្យទឹកភ្លៀងហូរនាំដី (បាក់ដី) និងបង្កជាទឹកជំនន់។
    2. **វិធានការ៖** ស្នើឱ្យមានការដាំដើមឈើឡើងវិញ (Re-forestation) ជាពិសេសនៅតាមតំបន់ជម្រាលភ្នំ និងមាត់ទឹក ដើម្បីបង្កើតរបាំងការពារធម្មជាតិឡើងវិញ។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. ប្រាប់តែវិធានការ តែមិនបានពន្យល់ពីទំនាក់ទំនងនៃបញ្ហា)។
- **គ្មានពិន្ទុ** : ឆ្លើយខុសទាំងស្រុង ឬមិនឆ្លើយ។

# មេរៀនទី៣ រូបផ្គុំសារពាង្គកាយមនុស្ស

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ១៣ : ឋានានុក្រមនៃរូបផ្គុំសារពាង្គកាយមនុស្ស

### អត្ថបទខ្លី៖ ពីកោសិកាទៅជាប្រព័ន្ធសរីរាង្គ




សារពាង្គកាយមនុស្សគឺជាម៉ាស៊ីនដ៏ស្មុគស្មាញមួយដែលបង្កឡើងពីកោសិការាប់កោដិ។ ប៉ុន្តែកោសិកាទាំងនេះមិនរស់នៅដាច់ដោយឡែកពីគ្នានោះទេ ពួកវាធ្វើការរួមគ្នាជាក្រុមតាមលំដាប់លំដោយ។ កោសិកាប្រភេទដូចគ្នាផ្គុំគ្នាបង្កើតបានជា ជាលិកា ហើយជាលិកាផ្សេងៗរួមគ្នាបង្កើតបានជា សរីរាង្គ ដូចជា បេះដូង សួត និងក្រពះ។ នៅពេលសរីរាង្គច្រើនធ្វើការងាររួមគ្នាដើម្បីគោលដៅតែមួយ វានឹងបង្កើតបានជា ប្រព័ន្ធសរីរាង្គ។ ភាពខុសប្លែកគ្នានៃរូបរាង និងទំហំកោសិកា គឺជាកត្តាដែលអនុញ្ញាតឱ្យមនុស្សអាចធ្វើចលនា គិត និងការពារខ្លួនពីមជ្ឈដ្ឋានខាងក្រៅបាន។

### សំណួរទី ១៖ លំដាប់លំដោយនៃរូបផ្គុំ

តើលំដាប់លំដោយនៃកម្រិតរូបផ្គុំសារពាង្គកាយពី តូចទៅធំ មួយណាដែលត្រឹមត្រូវ?

☐A. ជាលិកា ⇨ កោសិកា ⇨ សរីរាង្គ ⇨ ប្រព័ន្ធសរីរាង្គ

☐B. កោសិកា ⇨ សរីរាង្គ ⇨ ជាលិកា ⇨ ប្រព័ន្ធសរីរាង្គ

☐C. កោសិកា ⇨ ជាលិកា ⇨ សរីរាង្គ ⇨ ប្រព័ន្ធសរីរាង្គ

☐D. ប្រព័ន្ធសរីរាង្គ ⇨ សរីរាង្គ ⇨ ជាលិកា ⇨ កោសិកា

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់លំដាប់លំដោយនៃកម្រិតរូបផ្គុំសារពាង្គកាយពហុកោសិកា។ |
| កម្រិតពុទ្ធិ | ចងចាំ និងយល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ លក្ខណៈពិសេសនៃកោសិកា

នៅក្នុងសារពាង្គកាយមនុស្ស កោសិកានីមួយៗមានរូបរាងខុសៗគ្នាទៅតាមនាទីរបស់វា។

**ចូរផ្គូផ្គងប្រភេទកោសិកានៅជួរ (A) ទៅនឹងរូបរាងរបស់វា នៅជួរ (B) ឱ្យបានត្រឹមត្រូវ៖**

| ប្រភេទកោសិកា (A) | រូបរាង (B) | ចម្លើយ |
|---|---|---|
| ១. កោសិកាឈាមក្រហម | ក. រាងដូចផ្កាយមានជ្រុងច្រើន | ១ ⇨ ...... |
| ២. កោសិកាប្រសាទ | ខ. រាងសរសៃៗ | ២ ⇨ ...... |
| ៣. កោសិកាសាច់ដុំ | គ. រាងដូចថាស ផតសងខាង | ៣ ⇨ ...... |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែករូបរាងកោសិកាផ្សេងៗនៅក្នុងសារពាង្គកាយមនុស្ស។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ នាទីរបស់កោសិកា

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាអំពីនាទីកោសិកាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. កោសិកាប្រសាទមាននាទីបញ្ជាទៅគ្រប់សរីរាង្គទាំងអស់។ | ☐ | ☐ |
| ២. កោសិកាសាច់ដុំមាននាទីគ្របដណ្តប់ និងការពារសារពាង្គកាយ។ | ☐ | ☐ |
| ៣. កោសិកាសណ្ឋានជួយភ្ជាប់ និងទ្រទ្រង់ផ្នែកផ្សេងៗនៃរាងកាយ។ | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់នាទីជាក់លាក់នៃកោសិកាប្រភេទនីមួយៗ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ចម្លើយផ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវិភាគទំហំកោសិកា

ប្រសិនបើគេធ្វើការប្រៀបធៀបរវាង "កោសិកាស៊ុតបង្កកំណើត" និង "កោសិកាបន្តពូជឈ្មោល" តើសេចក្តីសន្និដ្ឋានមួយណាដែលត្រឹមត្រូវបំផុត?

□A. កោសិកាបន្តពូជឈ្មោលមានទំហំធំជាងគេបំផុតក្នុងរាងកាយ។

□B. កោសិកាស៊ុតបង្កកំណើតជាកោសិកាដែលមានប្រវែងវែងជាងគេ។

□C. កោសិកាស៊ុតបង្កកំណើតធំជាងគេបំផុត ចំណែកកោសិកាបន្តពូជឈ្មោលតូចជាងគេបំផុត។

□D. កោសិកាទាំងពីរមានទំហំស្មើគ្នា ប៉ុន្តែរូបរាងខុសគ្នា។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ប្រៀបធៀបទំហំកោសិកាផ្សេងៗក្នុងសារពាង្គកាយ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ៥៖ ការវិភាគ និងការដោះស្រាយបញ្ហា

នៅក្នុងគ្រោះថ្នាក់មួយ បុរសម្នាក់បានរងរបួសខូចខាតដល់ កោសិកាប្រសាទ នៅត្រង់ជើងរបស់គាត់យ៉ាងធ្ងន់ធ្ងរ។ ទោះបីជាកោសិកាសាច់ដុំ និងឆ្អឹងរបស់គាត់មិនមានបញ្ហាក៏ដោយ ក៏គាត់មិនអាចកម្រើកជើងបានឡើយ។

1. ផ្អែកលើអត្ថបទមេរៀនស្តីពី "នាទីកោសិកា" ចូរពន្យល់ពីមូលហេតុដែលបុរសនោះមិនអាចបញ្ជាជើងឱ្យមានចលនាបាន?

..........................................................................................................

..........................................................................................................

..........................................................................................................

2. តើកម្រិត "ប្រព័ន្ធសរីរាង្គ" របស់គាត់នៅតែដំណើរការជាធម្មតាដែរឬទេ?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគទំនាក់ទំនងរវាងនាទីកោសិកា និងដំណើរការនៃប្រព័ន្ធសរីរាង្គ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

- ចម្លើយត្រូវ៖ C. កោសិកា ⇨ ជាលិកា ⇨ សរីរាង្គ ⇨ ប្រព័ន្ធសរីរាង្គ

**សំណួរទី ២៖**

- ចម្លើយត្រូវ៖ ១-គ, ២-ក, ៣-ខ

**សំណួរទី ៣៖**

- ១. ពិត (កោសិកាប្រសាទមាននាទីបញ្ជា)
- ២. មិនពិត (កោសិកាអេពីតេស្យូមជាអ្នកការពារ ចំណែកសាច់ដុំសម្រាប់ចលនា)
- ៣. ពិត (កោសិកាសណ្ឋានមាននាទីភ្ជាប់ និងទ្រទ្រង់)
- ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ

**សំណួរទី ៤៖**

- ចម្លើយត្រូវ៖ C. **កោសិកាស៊ុតបង្កកំណើតធំជាងគេបំផុត ចំណែកកោសិកាបន្តពូជឈ្មោលតូចជាងគេបំផុត**

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **មូលហេតុ៖** ព្រោះកោសិកាប្រសាទមាននាទី "បញ្ជា"។ បើកោសិកាប្រសាទខូច ទោះបីសាច់ដុំ (ដែលធ្វើឱ្យមានចលនា) នៅល្អ ក៏គ្មានសញ្ញាបញ្ជាទៅដល់ ទើបមិនអាចកម្រើកបាន។
  2. **ប្រព័ន្ធសរីរាង្គ៖** ប្រព័ន្ធសរីរាង្គរបស់គាត់ (ប្រព័ន្ធប្រសាទ ឬប្រព័ន្ធចលនា) មិនដំណើរការជាធម្មតាទេ ព្រោះជាតុផ្សំគ្រឹះ (កោសិកា) មានបញ្ហា ដែលធ្វើឱ្យប៉ះពាល់ដល់នាទីរួមរបស់ប្រព័ន្ធទាំងមូល។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. និយាយត្រូវតែរឿងកោសិកាប្រសាទមាននាទីបញ្ជា តែមិនបានបញ្ជាក់ពីប្រព័ន្ធសរីរាង្គ)។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ១៤ : បណ្ដាញជាលិកា និងដំណើរការនៃជីវិត

## អត្ថបទខ្លី៖ មុខងារចម្រុះនៃជាលិកា




ក្នុងសារពាង្គកាយ កោសិកាប្រភេទដូចគ្នាផ្តុំគ្នាដើម្បីបំពេញនាទីជាក់លាក់មួយហៅថា **ជាលិកា**។ ជាលិកានីមួយៗប្រៀបដូចជាកម្មករជំនាញក្នុងរោងចក្រ៖ ជាលិកាខ្លះមាននាទីបញ្ជា (ប្រសាទ) ខ្លះមាននាទីធ្វើចលនា (សាច់ដុំ) ខ្លះមាននាទីការពារ (អេពីតេល្យូម) និងខ្លះទៀតមាននាទីចងភ្ជាប់ (សន្ទាន)។ ការរងរបួស ឬការចុះខ្សោយនៃជាលិកាប្រភេទណាមួយ នឹងធ្វើឱ្យប៉ះពាល់ដល់សរីរាង្គ និងប្រព័ន្ធសរីរាង្គទាំងមូល។

---

## សំណួរទី ១៖ ការសម្គាល់នាទីជាលិកា

ចូរជ្រើសរើសពាក្យក្នុងប្រអប់មកបំពេញក្នុងចន្លោះនៃការពណ៌នាខាងក្រោមឱ្យបានត្រឹមត្រូវ៖

| ពាក្យសម្រាប់បំពេញ៖ | ជាលិកាសន្ទាន | ជាលិកាអេពីតេល្យូម | ជាលិកាសាច់ដុំ |
|---|---|---|---|

ក. ជាលិកាដែលពាសផ្ទៃខាងក្នុងនៃសរីរាង្គដូចជាក្រពះ ដើម្បីគ្របដណ្តប់ និងការពារហៅថា៖ ............................................ ។

ខ. ជាលិកាដែលដើរតួជាអ្នកភ្ជាប់ និងទ្រទ្រង់ផ្នែកផ្សេងៗនៃរាងកាយដូចជាឆ្អឹងហៅថា៖ ............................................ ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ឈ្មោះ និងនាទីគ្រឹះរបស់ជាលិកាអេពីតេល្យូម និងជាលិកាសន្ទាន។ |
| កម្រិតពុទ្ធិ | ចងចាំ និងយល់ដឹង |
| ទម្រង់សំណួរ | បំពេញចន្លោះ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការផ្គូផ្គងប្រភេទជាលិកាឯកទេស

ចូរផ្គូផ្គងប្រភេទជាលិកានៅផ្នែក(A) ទៅនឹងតួនាទីជាក់លាក់របស់វា នៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| ប្រភេទជាលិកា (A) | តួនាទីជាក់លាក់ (B) | ចម្លើយ |
|---|---|---|
| ១. ជាលិកាឆ្អឹង | ក. បញ្ជា និងចម្លងព័ត៌មានទៅគ្រប់សរីរាង្គ | ១ ⇨ ...... |
| ២. ជាលិកាប្រសាទ | ខ. គ្របដណ្ដប់ និងការពារផ្ទៃសរីរាង្គ | ២ ⇨ ...... |
| ៣. ជាលិកាអេពីតេល្យូម | គ. ទ្រទ្រង់រាងកាយឱ្យមានទម្រង់រឹងមាំ | ៣ ⇨ ...... |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកនាទីឯកទេសនៃជាលិកាប្រភេទខុសៗគ្នា។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគរចនាសម្ព័ន្ធក្រពះ

នៅក្នុងសរីរាង្គក្រពះ មានការរួមផ្សំគ្នានៃជាលិកាខុសៗគ្នា។ តើការពណ៌នាណាដែល "ត្រឹមត្រូវ" ចំពោះទំនាក់ទំនងរវាងជាលិកា និងសរីរាង្គក្រពះ?

□A. ក្រពះមានតែជាលិកាអេពីតេល្យូមម្យ៉ាងគត់ដើម្បីរំលាយអាហារ។

□B. ជាលិកាសន្ធានមិនមានវត្តមាននៅក្នុងក្រពះឡើយ។

□C. ជាលិកាប្រសាទក្នុងក្រពះជួយទ្រទ្រង់ទម្ងន់អាហារ។

□D. ជាលិកាសាច់ដុំក្នុងក្រពះជួយក្នុងការកន្ត្រាក់កិនអាហារ ចំណែកអេពីតេល្យូមជួយការពារស្រទាប់ខាងក្នុង។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគពីរបៀបដែលជាលិកាច្រើនប្រភេទផ្គុំគ្នាបង្កើតបានជាសរីរាង្គមួយ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ការវាយតម្លៃលើភាពមិនប្រក្រតីនៃជាលិកា

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ប្រសិនបើជាលិកាអេពីតេលីយ៉ូមក្នុងក្រពះខូចខាត ក្រពះនឹងបាត់បង់របាំងការពាររបស់វា។ | ☐ | ☐ |
| ២. ជាលិកាសន្ទានមាននាទីគ្របដណ្តប់ផ្ទៃខាងក្រៅនៃរាងកាយតែម្យ៉ាងប៉ុណ្ណោះ។ | ☐ | ☐ |
| ៣. ការផ្តុំគ្នានៃជាលិកាខុសៗគ្នា បង្កើតបានជាកម្រិតរូបផ្គុំខ្ពស់ជាងនេះ ហៅថា សរីរាង្គ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃពីផលប៉ះពាល់នៃការខូចខាតជាលិកា និងយល់ដឹងពីឋានានុក្រមរូបផ្គុំ។ |
| កម្រិតពុទ្ធិ | វិភាគ និងវាយតម្លៃ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

---

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងព្យាករណ៍ (កម្រិតខ្ពស់)

ជំងឺម្យ៉ាងបានធ្វើឱ្យ "ជាលិកាសន្ទាន" របស់មនុស្សម្នាក់បាត់បង់សមត្ថភាពក្នុងការ "ភ្ជាប់ និងទ្រទ្រង់"។

1. តើនឹងមានផលវិបាកអ្វីកើតឡើងចំពោះ "ជាលិកាសាច់ដុំ" និង "ជាលិកាឆ្អឹង" របស់គាត់?

.......................................................................................................................

.......................................................................................................................

2. ចូរពន្យល់ពីផលប៉ះពាល់នេះទៅលើសមត្ថភាពនៃការធ្វើចលនារបស់រាងកាយទាំងមូល។

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ព្យាករណ៍ពីផលប៉ះពាល់នៃការចុះខ្សោយនៃជាលិកាសន្ទានលើប្រព័ន្ធចលនា។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

- ក. ជាលិកាអេពីតេល្យូម
- ខ. ជាលិកាសន្ទាន

**សំណួរទី ២៖**

- ១-គ (ឆ្អឹង ⇨ ទ្រទ្រង់)
- ២-ក (ប្រសាទ ⇨ បញ្ជា)
- ៣-ខ (អេពីតេល្យូម ⇨ គ្របដណ្តប់)

**សំណួរទី ៣៖**

- ចម្លើយត្រូវ៖ **D. ជាលិកាសាច់ដុំក្នុងក្រពះជួយក្នុងការកន្ត្រាក់កិនអាហារ ចំណែកអេពីតេស្យូមជួយការពារស្រទាប់ខាងក្នុង។**

**សំណួរទី ៤៖**

- ១. ពិត (អេពីតេស្យូមជាអ្នកការពារ បើខូចនឹងបាត់របាំង)
- ២. មិនពិត (វាមាននាទីភ្ជាប់ និងទ្រទ្រង់ផ្នែកខាងក្នុងផងដែរ ដូចជាឆ្អឹង)
- ៣. ពិត (ជាលិកាផ្គុំគ្នាជាសរីរាង្គ)
- ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ផលប៉ះពាល់លើជាលិកា៖** ជាលិកាសាច់ដុំនឹងបាត់បង់ចំណុចភ្ជាប់ទៅនឹងឆ្អឹង ហើយជាលិកាឆ្អឹងនឹងលែងមានភាពរឹងមាំសម្រាប់ទ្រទ្រង់រាងកាយ។
    2. **ការធ្វើចលនា៖** រាងកាយនឹងមិនអាចធ្វើចលនាបាន ឬបាត់បង់ទម្រង់ (រូបរាង) ជាក់លាក់ ព្រោះគ្មានអ្វីសម្រាប់ចងភ្ជាប់សាច់ដុំឱ្យទាញឆ្អឹងឱ្យកម្រើកបាន។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. និយាយតែរឿងឆ្អឹងមិនអាចទ្រទ្រង់បាន តែមិនបានបញ្ជាក់ពីការបាត់បង់ការចងភ្ជាប់របស់សាច់ដុំ)។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ១៥ : តុល្យភាពនៃប្រព័ន្ធសរីរាង្គក្នុងរាងកាយមនុស្ស

## អត្ថបទខ្លី៖ ម៉ាស៊ីនដ៏អស្ចារ្យ




សារពាង្គកាយមនុស្សគឺជាការរួមផ្សំគ្នានៃប្រព័ន្ធសរីរាង្គជាច្រើនដែលធ្វើការសហការគ្នាយ៉ាងស្អិតរមួត។ ប្រព័ន្ធនីមួយៗមាន "ភារកិច្ចឯកទេស" រៀងៗខ្លួន៖ ប្រព័ន្ធខ្លះដឹកជញ្ជូនសារធាតុចិញ្ចឹម ខ្លះបញ្ជាសកម្មភាព ខ្លះផ្តល់ចលនា និងខ្លះទៀតសម្អាតកាកសំណល់។ ប្រសិនបើប្រព័ន្ធណាមួយដំណើរការមិនប្រក្រតី វានឹងជះឥទ្ធិពលដល់ប្រព័ន្ធផ្សេងទៀត និងសុខភាពទូទៅនៃសារពាង្គកាយទាំងមូល។

## សំណួរទី ១៖ ការសម្គាល់សមាសភាគនៃប្រព័ន្ធ

តើសរីរាង្គមួយណាខាងក្រោមនេះ ដែលជាផ្នែកនៃ «**ប្រដាប់បញ្ចេញចោល**» របស់មនុស្ស?

☐A. បេះដូង និងសរសៃឈាម ☐B. ខួរក្បាល និងសរសៃប្រសាទ

☐C. តម្រងនោម និងប្លោកនោម ☐D. មាត់ និងបំពង់អាហារ

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់សរីរាង្គដែលបង្កជាប្រព័ន្ធសរីរាង្គជាក់លាក់។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការផ្គូផ្គងមុខងារប្រព័ន្ធសរីរាង្គ

ចូរផ្គូផ្គងឈ្មោះប្រព័ន្ធសរីរាង្គនៅផ្នែក(A) ទៅនឹងនាទីសំខាន់របស់វា នៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| ប្រព័ន្ធសរីរាង្គ (A) | នាទីសំខាន់ (B) | ចម្លើយ |
|---|---|---|
| ១. ប្រដាប់របត់ឈាម | ក. បណ្តូរឧស្ម័នរវាងសារពាង្គកាយ និងបរិយាកាស | ១ ⇨ ...... |
| ២. ប្រដាប់ដង្ហើម | ខ. បញ្ជារាល់សកម្មភាពឱ្យសម្របនឹងមជ្ឈដ្ឋាន | ២ ⇨ ...... |
| ៣. ប្រព័ន្ធប្រសាទ | គ. ដឹកនាំសារធាតុចិញ្ចឹម អុកស៊ីសែន និងកាកសំណល់ | ៣ ⇨ ...... |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកនាទីខុសៗគ្នានៃប្រព័ន្ធសរីរាង្គក្នុងរាងកាយ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគទំនាក់ទំនងរវាងប្រព័ន្ធ

នៅពេលអ្នករត់ប្រណាំង សាច់ដុំជើងរបស់អ្នកត្រូវការថាមពល និងអុកស៊ីសែនយ៉ាងច្រើន។ តើប្រព័ន្ធពីរណាខ្លះដែលត្រូវធ្វើការងារខ្លាំងជាងធម្មតា ដើម្បីជួយដល់ "**ប្រព័ន្ធសាច់ដុំ**" ក្នុងការរត់នេះ?

☐A. ប្រដាប់របត់ឈាម និងប្រដាប់ដង្ហើម

☐B. ប្រដាប់បន្តពូជ និងប្រដាប់បញ្ចេញចោល

☐C. ប្រដាប់រំលាយអាហារ និងប្រដាប់បន្តពូជ

☐D. តែប្រព័ន្ធសាច់ដុំម្យ៉ាងគត់ដែលធ្វើការ

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគពីទំនាក់ទំនងរវាងប្រព័ន្ធសរីរាង្គខុសៗគ្នា។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ការវាយតម្លៃលើមុខងារបញ្ហា

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ប្រព័ន្ធប្រសាទរួមមាន ខួរក្បាល ខួរឆ្អឹងខ្នង និងសរសៃប្រសាទ។ | ☐ | ☐ |
| ២. ប្រដាប់រំលាយអាហារមាននាទីផលិតអុកស៊ីសែនសម្រាប់ឈាម។ | ☐ | ☐ |
| ៣. ប្រដាប់បន្តពូជមាននាទីរក្សាពូជពង្សឱ្យគង់វង្សទៅថ្ងៃក្រោយ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃសមាសភាគ និងមុខងារប្រព័ន្ធសរីរាង្គ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

---

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការព្យាករណ៍ (កម្រិតខ្ពស់)

មនុស្សម្នាក់មានជំងឺដែលធ្វើឱ្យ «**ប្រដាប់របត់ឈាម**» របស់គាត់ចុះខ្សោយខ្លាំង (បេះដូងលោតខ្សោយ និងសរសៃឈាមស្ទះ)។

1. តើបញ្ហានៃប្រដាប់របត់ឈាមនេះ នឹងប៉ះពាល់ដល់ «**ប្រដាប់រំលាយអាហារ**» យ៉ាងដូចម្តេច? (គន្លឹះ៖ គិតអំពីរបៀបដែលសារធាតុចិញ្ចឹមត្រូវបានដឹកជញ្ជូន)។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

2. ចូរពន្យល់ពីផលវិបាកចំពោះសារពាង្គកាយទាំងមូល ប្រសិនបើកោសិកានានាមិនទទួលបានសារធាតុចិញ្ចឹមពីការរំលាយអាហារ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ព្យាករណ៍ផលប៉ះពាល់នៃខ្សែសង្វាក់មុខងាររវាងប្រព័ន្ធសរីរាង្គផ្សេងៗ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. តម្រងនោម និងប្លោកនោម**

**សំណួរទី ២៖**

ចម្លើយត្រូវ៖

- ១ ⇨ គ. ដឹកនាំសារធាតុចិញ្ចឹម អុកស៊ីសែន និងកាកសំណល់
- ២ ⇨ ក. បណ្តូរឧស្ម័នរវាងសារពាង្គកាយ និងបរិយាកាស
- ៣ ⇨ ខ. បញ្ចារាល់សកម្មភាពឱ្យសម្របនឹងមជ្ឈដ្ឋាន

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **A. ប្រដាប់របត់ឈាម និងប្រដាប់ដង្ហើម** (របត់ឈាមដឹកនាំសារធាតុ និងអុកស៊ីសែន ចំណែកដង្ហើមនាំអុកស៊ីសែនចូល)។

**សំណួរទី ៤៖**

- ១. **ពិត** (សមាសភាគប្រព័ន្ធប្រសាទត្រឹមត្រូវ)
- ២. **មិនពិត** (រំលាយអាហារផ្តល់សារធាតុចិញ្ចឹម មិនមែនអុកស៊ីសែនទេ)
- ៣. **ពិត** (នាទីបន្តពូជត្រឹមត្រូវ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ**: ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ផលប៉ះពាល់លើប្រដាប់រំលាយអាហារ៖** ទោះបីប្រដាប់រំលាយអាហារធ្វើការបានល្អក៏ដោយ ប៉ុន្តែបើរបត់ឈាមខ្សោយ វានឹងមិនអាចដឹកនាំសារធាតុចិញ្ចឹមដែលរំលាយរួចទៅកាន់ផ្នែកផ្សេងៗនៃរាងកាយបានឡើយ។
  2. **ផលវិបាកចំពោះសារពាង្គកាយ៖** កោសិកានឹងខ្វះថាមពល សារពាង្គកាយចុះខ្សោយ មិនអាចធ្វើចលនា ឬលូតលាស់បាន ហើយអាចឈានដល់ការបាត់បង់ជីវិត ព្រោះគ្រប់ប្រព័ន្ធទាំងអស់ត្រូវការសារធាតុចិញ្ចឹមដើម្បីរស់។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. និយាយថាឈាមមិនអាចដឹកសារធាតុចិញ្ចឹមបាន តែមិនបានបញ្ជាក់ពីផលវិបាកដល់សារពាង្គកាយទាំងមូល)។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ១៦ : ទំនាក់ទំនង និងការសហការនៃសរីរាង្គមនុស្ស

## អត្ថបទខ្លី៖ ម៉ាស៊ីនជីវសាស្ត្រដែលស៊ីសង្វាក់គ្នា




ដងខ្លួនរបស់មនុស្សយើងត្រូវបានបែងចែកជាពីរចំណែកធំៗគឺ **ទ្រូង** និង **ពោះ** ដែលខណ្ឌគ្នាដោយ **សន្ទះទ្រូង**។ នៅក្នុងចន្លោះនីមួយៗមានផ្ទុកសរីរាង្គសំខាន់ៗដែលបំពេញនាទីខុសៗគ្នា។ ទោះជាយ៉ាងណា សរីរាង្គទាំងនេះមិនបំពេញការងារដាច់ដោយឡែកពីគ្នានោះទេ។ នៅពេលរាងកាយធ្វើសកម្មភាពខ្លាំង ដូចជាការលេងកីឡា គ្រប់ប្រព័ន្ធសរីរាង្គទាំងអស់ចាប់ផ្តើមធ្វើការងារសហការគ្នាយ៉ាងស្អិតរមួត ដើម្បីរក្សាតុល្យភាព និងផ្តល់ថាមពលឱ្យរាងកាយ។

---

## សំណួរទី ១៖ ទីតាំងនៃសរីរាង្គក្នុងដងខ្លួន

ផ្អែកលើអត្ថបទមេរៀន តើសរីរាង្គខាងក្រោមណាខ្លះ ដែលស្ថិតនៅក្នុង «**ពោះ**» របស់មនុស្ស?

☐A. សួត និងបេះដូង ☐B. ថ្លើម និងក្រពះ

☐C. សន្ទះទ្រូង និងខួរក្បាល ☐D. បំពង់ខ្យល់ និងបេះដូង

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ទីតាំងសរីរាង្គក្នុងចន្លោះទ្រូង និងចន្លោះពោះ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ របាំងខណ្ឌផ្នែកនៃដងខ្លួន

តើផ្នែក "ទ្រូង" និង "ពោះ" របស់មនុស្សត្រូវបានខណ្ឌដាច់ពីគ្នាដោយសាររូបធាតុមួយណា?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ប្រាប់ឈ្មោះសន្ទះទ្រូងដែលជាអ្នកខណ្ឌចែកដងខ្លួន។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ចម្លើយខ្លី |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគបាតុភូតពេលហាត់ប្រាណ

នៅពេលយើងហាត់ប្រាណ បេះដូងរបស់យើងលោតញាប់ជាងធម្មតា។ តើការធ្វើការងារខ្លាំងរបស់បេះដូងក្នុងពេលនោះមានគោលបំណងអ្វី?

□A. ដើម្បីផលិតថាមពលឱ្យប្រព័ន្ធប្រសាទគិតបានលឿន។

□B. ដើម្បីទប់ស្កាត់មិនឱ្យសន្ទះទ្រូងធ្វើចលនា។

□C. ដើម្បីផ្តល់អុកស៊ីសែនឱ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការថាមពលរបស់ប្រព័ន្ធសាច់ដុំ។

□D. ដើម្បីកាត់បន្ថយការស្រូបយកអុកស៊ីសែនពីបរិយាកាស។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគតួនាទីរបស់បេះដូងចំពោះតម្រូវការថាមពលរបស់សាច់ដុំ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ការវាយតម្លៃលើភាពស៊ីសង្វាក់គ្នានៃប្រព័ន្ធ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. នៅពេលលេងកីឡា ប្រព័ន្ធសាច់ដុំបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីតច្រើនជាងពេលសម្រាក។ | ☐ | ☐ |
| ២. ប្រព័ន្ធប្រសាទគ្មាននាទីអ្វីឡើយ ក្នុងពេលរាងកាយធ្វើសកម្មភាពហាត់ប្រាណ។ | ☐ | ☐ |
| ៣. រាល់សរីរាង្គក្នុងសារពាង្គកាយតែងតែបំពេញមុខងារស៊ីសង្វាក់គ្នាជានិច្ច។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើមុខងារស៊ីសង្វាក់គ្នារវាងប្រព័ន្ធប្រសាទ សាច់ដុំ និងរបត់ឈាម។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការសន្និដ្ឋាន (កម្រិតខ្ពស់)

នៅក្នុងការរត់ប្រណាំង បុរសម្នាក់ស្រាប់តែមានអារម្មណ៍ថា «ថប់ដង្ហើម និងចុកទ្រូង» ដោយសារបេះដូងរបស់គាត់មិនអាចលោតផ្តល់ឈាមបានគ្រប់គ្រាន់តាមតម្រូវការ។



1. ផ្អែកលើមេរៀនស្តីពី "នាទីស៊ីសង្វាក់គ្នា" តើការចុះខ្សោយរបស់បេះដូងនឹងជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះដល់ "ប្រព័ន្ធសាច់ដុំ" និង "ប្រព័ន្ធប្រសាទ" របស់គាត់ក្នុងពេលនោះ?

.............................................................................................................

.............................................................................................................

.............................................................................................................

.............................................................................................................

2. ចូរពន្យល់ពីផលវិបាកដែលនឹងកើតឡើងចំពោះការបន្តរត់របស់គាត់។

.............................................................................................................

.............................................................................................................

.............................................................................................................

.............................................................................................................

.............................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃផលប៉ះពាល់នៃការបាត់បង់តុល្យភាពមុខងាររវាងសរីរាង្គក្នុងពេលធ្វើសកម្មភាព។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **B. ថ្លើម និងក្រពះ**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **សន្ទះទ្វេង**

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **C. ដើម្បីផ្តល់អុកស៊ីសែនឱ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការថាមពលរបស់ប្រព័ន្ធសាច់ដុំ**

**សំណួរទី ៤៖**

- ១. **ពិត** (សកម្មភាពខ្លាំងបញ្ចេញកាបូនឌីអុកស៊ីតច្រើន)
- ២. **មិនពិត** (ប្រព័ន្ធប្រសាទមាននាទីបញ្ជាឱ្យមានភាពស៊ីសង្វាក់គ្នា)
- ៣. **ពិត** (សរីរាង្គទាំងអស់ធ្វើការងារស៊ីសង្វាក់គ្នា)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ផលប៉ះពាល់៖** ប្រព័ន្ធសាច់ដុំនឹងខ្វះអុកស៊ីសែន និងថាមពលសម្រាប់កន្ត្រាក់ (ធ្វើឱ្យចុះខ្សោយ ឬរមួលក្រពើ) ចំណែកប្រព័ន្ធប្រសាទនឹងបាត់បង់ការបញ្ជាឱ្យស៊ីសង្វាក់គ្នា (ធ្វើឱ្យវិលមុខ ឬបាត់បង់តុល្យភាព)។
  2. **ផលវិបាក៖** គាត់មិនអាចបន្តការរត់បានឡើយ ព្រោះសារពាង្គកាយបាត់បង់ភាពស៊ីសង្វាក់គ្នានៃមុខងារ ដែលទាមទារឱ្យគាត់ត្រូវឈប់សម្រាកដើម្បីយកអុកស៊ីសែនមកវិញ។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. និយាយថាគាត់ហត់រត់មិនរួច តែមិនបានបញ្ជាក់ពីការខ្វះអុកស៊ីសែនក្នុងសាច់ដុំ ឬការបញ្ជារបស់ប្រព័ន្ធប្រសាទ)។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ជំពូកទី៤ ការរំលាយអាហារ

## មេរៀនទី១ រូបផ្តុំប្រដាប់រំលាយអាហារ

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

តំណភ្ជាប់វីដេអូមេរៀន

## ប្រធានបទទី ១៧ : ដំណើរផ្លាស់ប្តូរនៃអាហារក្នុងរាងកាយ

### អត្ថបទខ្លី៖ ដំណើរផ្សងព្រេងនៃអាហារ




រាល់ថ្ងៃយើងបរិភោគអាហារដើម្បីទទួលបានថាមពលសម្រាប់ការលូតលាស់ និងជួសជុលផ្នែកខូចខាតនៃរាងកាយ។ ប៉ុន្តែ ប៊ឺហ្គឺ (Burger) ឬបាយដែលយើងញ៉ាំ មិនអាចរត់ចូលទៅចិញ្ចឹមកោសិកាដោយផ្ទាល់ក្នុងទម្រង់ដុំៗបានទេ។ វាត្រូវឆ្លងកាត់ការបំបែកជាម៉ូលេគុលតូចល្អិតបំផុតតាមរយៈ **«ការរំលាយអាហារ»**។ ដំណើរការនេះប្រៀបដូចជារោងចក្រកែច្នៃមួយ ដែលចាប់ផ្តើមពីមាត់ រហូតដល់ការបញ្ចេញកាកសំណល់ចោល ដោយមានការចូលរួមពីសរីរាង្គ និងក្រពេញសំខាន់ៗជាច្រើន។

---

### សំណួរទី ១៖ គោលបំណងនៃការរំលាយអាហារ

យោងតាមអត្ថបទមេរៀន តើអ្វីទៅជាគោលបំណងចម្បងនៃ "ការរំលាយអាហារ"?

□A. ដើម្បីធ្វើឱ្យអាហារមានរសជាតិឆ្ងាញ់ជាងមុន។

□B. ដើម្បីបំបែកអាហារឱ្យទៅជាម៉ូលេគុលតូចៗ ដែលអាចស្រូបចូលក្នុងឈាមបាន។

□C. ដើម្បីផ្លាស់ប្តូរអាហារឱ្យទៅជាអុកស៊ីសែនសម្រាប់សួត។

□D. ដើម្បីកាត់បន្ថយបរិមាណទឹកនៅក្នុងសារពាង្គកាយ។

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ពីនិយមន័យ និងសារៈសំខាន់នៃលំនាំរំលាយអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការសម្គាល់នាទីសរីរាង្គ

នៅក្នុងប្រព័ន្ធរំលាយអាហារ សរីរាង្គនីមួយៗមាននាទីខុសគ្នា។

ចូរផ្គូផ្គងសរីរាង្គនៅផ្នែក (A) ទៅនឹងនាទីរបស់វា នៅផ្នែក (B) ឱ្យបានត្រឹមត្រូវ៖




| សរីរាង្គ (A) | នាទី (B) | ចម្លើយ |
|---|---|---|
| ១. មាត់ | ក. ស្រូបយកទឹក និងបង្កើតកាកសំណល់ | ១ ⇨ ...... |
| ២. ពោះវៀនតូច | ខ. កិនបំបែកអាហារដំបូងដោយមានទឹកមាត់ | ២ ⇨ ...... |
| ៣. ពោះវៀនធំ | គ. ស្រូបយកសារធាតុចិញ្ចឹមភាគច្រើនចូលក្នុងរាងកាយ | ៣ ⇨ ...... |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់នាទីជាក់លាក់នៃសរីរាង្គនីមួយៗក្នុងបំពង់រំលាយអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ តួនាទីនៃក្រពេញជំនួយ

ក្រៅពីបំពង់រំលាយអាហារ ក៏មានក្រពេញមួយចំនួនដែលជួយដល់ការរំលាយអាហារផងដែរ។ តើក្រុមសរីរាង្គមួយណាខាងក្រោមដែលសុទ្ធតែជា «**ក្រពេញរំលាយអាហារ**»?

☐A. ក្រពះ បំពង់ក និងពោះវៀនតូច

☐B. ថ្លើម លំពែង និងថង់ទឹកប្រមាត់

☐C. មាត់ ក្រពះ និងពោះវៀនធំ

☐D. តម្រងនោម ប្លោកនោម និងបេះដូង

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកបំពង់រំលាយអាហារ និងក្រពេញរំលាយអាហារ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើដំណើរការរំលាយអាហារ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ការរំលាយអាហារចាប់ផ្ដើមដំបូងគេបង្អស់នៅក្នុងក្រពះ។ | ☐ | ☐ |
| ២. អាហារត្រូវតែបំបែកជាម៉ូលេគុលតូចៗ ទើបឈាមអាចដឹកនាំទៅចិញ្ចឹមកោសិកាបាន។ | ☐ | ☐ |
| ៣. អាស៊ីតក្រពះជួយក្នុងការកិនបំបែកអាហារបន្ថែមនៅក្នុងសរីរាង្គក្រពះ។ | ☐ | ☐ |

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃលំដាប់លំដោយ និងយន្តការរំលាយអាហារ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងផលប៉ះពាល់ (កម្រិតខ្ពស់)

បុរសម្នាក់បរិភោគអាហារដែលមានជីវជាតិច្រើន ប៉ុន្តែគាត់នៅតែមានបញ្ហា «**ពោះវៀនតូច**» របស់គាត់ មិនអាចស្រូបយកសារធាតុចិញ្ចឹមបាន ។

1. ផ្អែកលើមេរៀន តើនឹងមានអ្វីកើតឡើងចំពោះការលូតលាស់ និងថាមពលរបស់បុរសនោះ?

..............................................................................................................

..............................................................................................................

..............................................................................................................

2. ចូរពន្យល់ពីមូលហេតុដោយផ្សារភ្ជាប់ទៅនឹងនាទីរបស់ពោះវៀនតូច និងតម្រូវការរបស់កោសិកា។

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគផលប៉ះពាល់នៃការបាត់បង់មុខងារស្រូបសារធាតុចិញ្ចឹមចំពោះសុខភាពទូទៅ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **B. ដើម្បីបំបែកអាហារឱ្យទៅជាម៉ូលេគុលតូចៗ ដែលអាចស្រូបចូលក្នុងឈាមបាន**

**សំណួរទី ២៖**

ចម្លើយត្រូវ៖

- ១ ⇨ ខ. កិនបំបែកអាហារដំបូងដោយមានទឹកមាត់
- ២ ⇨ គ. ស្រូបយកសារជាតុចិញ្ចឹមភាគច្រើនចូលក្នុងរាងកាយ
- ៣ ⇨ ក. ស្រូបយកទឹក និងបង្កើតកាកសំណល់

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **B. ថ្លើម លំពែង និងថង់ទឹកប្រមាត់**

**សំណួរទី ៤៖**

- ១. **មិនពិត** (ការរំលាយអាហារចាប់ផ្ដើមដំបូងនៅក្នុងមាត់)
- ២. **ពិត** (សារពាង្គកាយមិនអាចប្រើម៉ូលេគុលធំដោយផ្ទាល់បានទេ)
- ៣. **ពិត** (ក្រពះប្រើអាស៊ីត និងការកិនដើម្បីបំបែកអាហារ)
- *(ត្រូវតែគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ផលប៉ះពាល់៖** គាត់នឹងចុះខ្សោយ បាត់បង់ថាមពល និងលែងលូតលាស់ (ឬស្រកទម្ងន់ខ្លាំង)។
  2. **មូលហេតុ៖** ព្រោះពោះវៀនតូចមាននាទីចម្បងក្នុងការស្រូបយកសារជាតុចិញ្ចឹម។ បើវាខូច ទោះញ៉ាំច្រើនក៏សារជាតុចិញ្ចឹមមិនអាចចូលទៅក្នុងឈាមដើម្បីដឹកនាំទៅចិញ្ចឹមកោសិកាបានដែរ កោសិកានឹងខ្វះរូបធាតុសម្រាប់បង្កើតកោសិកាថ្មី និងខ្វះថាមពល។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. និយាយថាគាត់គ្មានកម្លាំង តែមិនបានបញ្ជាក់ពីការមិនអាចស្រូបសារជាតុចូលទៅដល់កោសិកា)។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# មេរៀនទី២ ផ្នែកផ្សេងៗនៃប្រដាប់រំលាយអាហារ

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ១៨ : ធ្មេញ និងយន្តការកិនបំបែកអាហារ

### អត្ថបទខ្លី៖ ឧបករណ៍កិនកែច្នៃអាហារដំបូង




សិស្សមួយក្រុមកំពុងធ្វើបទបង្ហាញមួយអំពីដំណើការបំបែកអាហារក្នុងមាត់ ដែលមានខ្លឹមសារដូចខាងក្រោម៖

"មុនពេលអាហារធ្វើដំណើរទៅដល់ក្រពះ វាត្រូវឆ្លងកាត់ការកិនបំបែកជាបំណែកតូចៗនៅក្នុងមាត់ដោយប្រើ **ធ្មេញ**។ ធ្មេញមិនត្រឹមតែជារចនាសម្ព័ន្ធដែលរឹងមាំបំផុតនៅក្នុងរាងកាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាសរីរាង្គដែលមានជីវិត ព្រោះវាមានសរសៃឈាម និងសរសៃប្រសាទចិញ្ចឹម។ មនុស្សយើងម្នាក់ៗមានប្រភេទធ្មេញខុសៗគ្នា ដែលបំពេញនាទីខុសគ្នា ចាប់ពីការខាំកកេរ រហូតដល់ការទំពាទម្លុះ។ ការថែរក្សាកាចធ្មេញឱ្យបានល្អ គឺជាគន្លឹះដ៏សំខាន់ដើម្បីការពារធ្មេញពីការបំផ្លាញ។"

### សំណួរទី ១៖ រចនាសម្ព័ន្ធផ្ទៃក្នុងនៃធ្មេញ

ផ្អែកលើអត្ថបទមេរៀន តើសារធាតុមួយណាដែលរុំស្រោបភ្លុកនៃដើមធ្មេញ និងមានលក្ខណៈរឹងខ្លាំងបំផុត ប៉ុន្តែស្រួយ?

☐A. កាចាធ្មេញ ☐B. ភ្លុកធ្មេញ ☐C. សំបកធ្មេញ ☐D. បណ្តូលធ្មេញ

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់សមាសធាតុបង្ក និងលក្ខណៈរូបនៃផ្នែកផ្សេងៗរបស់ធ្មេញ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ២៖ ការវិភាគនាទីតាមប្រភេទធ្មេញ




មនុស្សពេញវ័យមានធ្មេញ ៤ ប្រភេទ។ ចូរផ្គូផ្គងប្រភេទធ្មេញនៅជួរ (A) ទៅនឹងនាទីចម្បងរបស់វា នៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| ប្រភេទធ្មេញ (A) | នាទីចម្បង (B) | ចម្លើយ |
|---|---|---|
| ១. ធ្មេញមុខ | ក. ហែកអាហារ | ១ ⇨ ...... |
| ២. ចង្កូម | ខ. ទំពា និងកិនអាហារឱ្យម៉ដ្ឋ | ២ ⇨ ...... |
| ៣. ថ្គាមធំ | គ. ខាំ និងកកេរអាហារ | ៣ ⇨ ...... |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកនាទីតាមរូបរាង និងប្រភេទនៃធ្មេញនីមួយៗ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការគណនាចំនួនធ្មេញ (រូបមន្តធ្មេញ)

យោងតាមរូបមន្តធ្មេញរបស់មនុស្សពេញវ័យ៖ **(ធ.ម.២ + ច.១ + ថ្គ.ត.២ + ថ្គ.៣)** សម្រាប់ពាក់កណ្តាលឆ្អឹងថ្គាមនីមួយៗ។

តើនៅក្នុងមាត់របស់មនុស្សពេញវ័យម្នាក់ មាន **"ធ្មេញថ្គាមធំ"** សរុបចំនួនប៉ុន្មានគ្រាប់ (ទាំងលើ ទាំងក្រោម ទាំងឆ្វេង ទាំងស្តាំ)?

☐A. ៣ គ្រាប់ ☐B. ៦ គ្រាប់ ☐C. ៨ គ្រាប់ ☐D. ១២ គ្រាប់

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | អនុវត្តរូបមន្តធ្មេញដើម្បីគណនាចំនួនធ្មេញសរុបតាមប្រភេទ។ |
| កម្រិតពុទ្ធិ | អនុវត្តន៍ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ការវាយតម្លៃលើការលូតលាស់ធ្មេញ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ធ្មេញទឹកដោះចាប់ដុះនៅចន្លោះអាយុពី ៦ ខែ ទៅ ៣០ ខែ។ | ☐ | ☐ |
| ២. ធ្មេញគឺជាសរីរាង្គគ្មានជីវិត ព្រោះវាគ្មានសរសៃឈាម និងសរសៃប្រសាទ។ | ☐ | ☐ |
| ៣. ថ្គាមទាល់ គឺជាធ្មេញថ្គាមធំទី ៣ ដែលដុះនៅចន្លោះអាយុ ២៥ ទៅ ៣០ ឆ្នាំ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើដំណាក់កាលលូតលាស់ និងលក្ខណៈជីវសាស្ត្រនៃធ្មេញ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការថែទាំ (កម្រិតខ្ពស់)




កុមារម្នាក់ចូលចិត្តទទួលទានបង្អែមផ្អែមៗ និងមិនសូវដុសសម្អាតធ្មេញឡើយ។ យូរៗទៅ អាស៊ីតដែលបង្កដោយបាក់តេរីបានរលាយកាត់ «**កាចធ្មេញ**» របស់គេរហូតធ្លុះទៅដល់ «**បណ្តូលធ្មេញ**»។

1. ផ្អែកលើមេរៀន តើហេតុអ្វីបានជាកុមារនោះមានអារម្មណ៍ «**ឈឺចាប់ខ្លាំង**» នៅពេលប្រហោងធ្មេញធ្លុះដល់បណ្តូលធ្មេញ?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

2. តើនឹងមានផលប៉ះពាល់អ្វីកើតឡើងចំពោះធ្មេញនោះ ប្រសិនបើសរសៃឈាមនៅក្នុងបណ្តូលធ្មេញត្រូវបានបំផ្លាញអស់?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគទំនាក់ទំនងរវាងរូបផ្គុំធ្មេញ និងអារម្មណ៍ឈឺចាប់ ព្រមទាំងផលវិបាកទៅលើសុខភាព។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **A. កាថាផ្ទេញ**

**សំណួរទី ២៖**

ចម្លើយត្រូវ៖

- ១ ⇨ គ. ខាំ និងកកេរអាហារ
- ២ ⇨ ក. ហែកអាហារ
- ៣ ⇨ ខ. ទំពា និងកិនអាហារឱ្យម៉ដ្ឋ

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **D. ១២ គ្រាប់** (ក្នុងមាត់មាន ៤ ចំហៀង ក្នុង ១ ចំហៀងមានថ្គាមធំ ៣ គ្រាប់ ដូចនេះ 3 x 4 = 12)។

**សំណួរទី ៤៖**

- ១. **ពិត** (អាយុដុះធ្មេញទឹកដោះត្រឹមត្រូវ)
- ២. **មិនពិត** (ធ្មេញមានជីវិត ព្រោះមានសរសៃឈាម និងសរសៃប្រសាទក្នុងបណ្ដូល)
- ៣. **ពិត** (និយមន័យថ្គាមទាល់ត្រឹមត្រូវ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **មូលហេតុឈឺចាប់៖** ព្រោះនៅក្នុងបណ្ដូលធ្មេញមានផ្ទុក **សរសៃប្រសាទ**។ កាលណាប្រហោងធ្មេញធ្លុះដល់ទីនោះ វានឹងធ្វើឱ្យប៉ះពាល់ផ្ទាល់ដល់សរសៃប្រសាទដែលធ្វើឱ្យធ្មេញរួស ទើបបង្កជាការឈឺចាប់ខ្លាំង។
  2. **ផលប៉ះពាល់៖** ប្រសិនបើសរសៃឈាមត្រូវបំផ្លាញ ធ្មេញនឹងបាត់បង់ប្រភពចិញ្ចឹម ធ្វើឱ្យធ្មេញនោះងាប់ (បាត់បង់ជីវិត) និងអាចប្រែជាពណ៌ខ្មៅ ឬងាយនឹងបាក់បែក។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. និយាយថាឈឺព្រោះដល់សរសៃប្រសាទ តែមិនបានបញ្ជាក់ពីការបាត់បង់ជីវិតរបស់ធ្មេញ)។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ១៩ : បំពង់រំលាយអាហារ - ខ្សែច្រវាក់ផលិតកម្មនៃជីវិត

## អត្ថបទខ្លី៖ ដំណើរដ៏វែងឆ្ងាយនៃអាហារ




គ្រូពេទ្យជំនាញម្នាក់បានចុះទៅអប់រំអំពីសុខភាពប្រដាប់រំលាយអាហារនៅអនុវិទ្យាល័យមួយកន្លែង ដែលគាត់បានពន្យល់អំពីដំណើរការរំលាយអាហារ ។

អាហារដែលយើងលេបចូល ត្រូវឆ្លងកាត់បំពង់មួយដ៏វែង និងបត់បែនដែលមានប្រវែងសរុបជិត ៩ ម៉ែត្រ។ ចាប់ពីប្រហោងមាត់ដែលជាច្រកទ្វារដំបូង រហូតដល់ពោះវៀនធំដែលជាកន្លែងបញ្ចេញកាកសំណល់ សរីរាង្គនីមួយៗមានរចនាសម្ព័ន្ធពិសេសដើម្បីធានាថា អាហារត្រូវបានបញ្ជូន បំបែក និងស្រូបយកបានយ៉ាងមានប្រសិទ្ធភាព។ ការយល់ដឹងពីដំណើរការនេះ មិនត្រឹមតែជួយឱ្យយើងដឹងពីសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយការពារយើងពីគ្រោះថ្នាក់ផ្សេងៗក្នុងពេលបរិភោគផងដែរ។

---

### សំណួរទី ១៖ យន្តការសុវត្ថិភាពក្នុងពេលលេបអាហារ

នៅពេលយើងលេបអាហារ ហេតុអ្វីបានជាអាហារមិនធ្លាក់ចូលទៅក្នុងផ្លូវដង្ហើម (បំពង់ខ្យល់) ដែលបណ្តាលឱ្យយើងឈ្លក់?

☐A. ព្រោះអណ្តាតជួយរុញអាហារឱ្យរំលងបំពង់ខ្យល់។

☐B. ព្រោះសន្ទះខ្យល់នៅផ្នែកខាងក្រោមនៃដើមក បិទបំពង់សំឡេងឱ្យជិត។

☐C. ព្រោះបំពង់អាហារមានប្រវែងវែងជាងបំពង់ខ្យល់។

☐D. ព្រោះអាហារមានទម្ងន់ធ្ងន់ជាងខ្យល់។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ប្រាប់ពីការការពារផ្លូវដង្ហើមក្នុងពេលលេបអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការសម្គាល់ទីតាំង និងទំហំសរីរាង្គ

ចូរជ្រើសរើសពាក្យត្រឹមត្រូវពីមេរៀនមកបំពេញក្នុងចន្លោះនៃសេចក្ដីថ្លែងការណ៍ខាងក្រោម៖

ក. បំពង់ដែលស្ថិតនៅចន្លោះឆ្អឹងខ្នង និងទងសួត មានប្រវែង ២៥cm ហៅថា៖ ..........................។

ខ. ថង់ដែលមានចំណុះប្រហែល ២ លីត្រ និងមានភ្នាសសម្បូរដោយក្រពេញហៅថា៖ .................។

គ. បំពង់ដែលបត់បែនច្រើនផ្នត់ និងមានប្រវែងដល់ទៅ ៧ ម៉ែត្រហៅថា៖ .................................។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ឈ្មោះសរីរាង្គតាមរយៈលក្ខណៈរូប និងទំហំ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | បំពេញចន្លោះ |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគការស្រូបសារធាតុចិញ្ចឹម

នៅក្នុង **ពោះវៀនតូច** មាន "ជ្រាំងពោះវៀន" ជាច្រើន។ តើវត្តមាននៃជ្រាំងពោះវៀនទាំងនេះមានសារៈសំខាន់អ្វីបំផុតសម្រាប់រាងកាយ?

☐A. ដើម្បីការពារមិនឱ្យលាមកត្រឡប់ថយក្រោយ។

☐B. ដើម្បីជួយកិនអាហារឱ្យកាន់តែម៉ដ្ដដូចធ្មេញ។

☐C. ដើម្បីបង្កើនផ្ទៃសម្រាប់ស្រូបយកអាហារដែលរលាយចូលទៅក្នុងឈាម។

☐D. ដើម្បីបញ្ចេញទឹកមាត់ជួយដល់ការរំលាយអាហារ។

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគតួនាទីរបស់ជញ្ជាំងពោះវៀនក្នុងការស្រូបសារជាតុចិញ្ចឹម។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

---

## សំណួរទី ៤៖ ការវាយតម្លៃលើមុខងារបំពង់រំលាយអាហារ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ការរំលាយអាហារត្រូវបានបញ្ចប់ទាំងស្រុងនៅក្នុងពោះវៀនធំ។ | ☐ | ☐ |
| ២. ពោះវៀនធំគ្មានក្រពេញរំលាយអាហារទេ ប៉ុន្តែវាស្រូបយកទឹក និងអំបិលខនិជ។ | ☐ | ☐ |
| ៣. ទ្វារលើក្រពះ គឺជាកន្លែងភ្ជាប់រវាងបំពង់អាហារ និងក្រពះ។ | ☐ | ☐ |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃមុខងារ និងរចនាសម្ព័ន្ធសរីរាង្គរំលាយអាហារ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

---

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការដោះស្រាយបញ្ហា (កម្រិតខ្ពស់)



មនុស្សម្នាក់មានអាការៈឈឺពោះយ៉ាងខ្លាំងនៅផ្នែកខាងស្តាំផ្នែកខាងក្រោម។ គ្រូពេទ្យសន្និដ្ឋានថា គេមានការរលាកនៅត្រង់ «**ខ្នែងពោះវៀន**» ដែលមានប្រវែង ២-៤cm នៅដើមពោះវៀនធំ។

1. ផ្អែកលើមេរៀន តើជំងឺរលាកខ្នែងពោះវៀននេះប៉ះពាល់ដល់ "ការរលាយអាហារ" និង "ការស្រូបសារជាតុចិញ្ចឹម" ដែរឬទេ?

..............................................................................................................................................

..............................................................................................................................................

2. ចូរពន្យល់ពីមូលហេតុ ដោយផ្អែកលើទីតាំងដែលការរំលាយអាហារត្រូវបានបញ្ចប់។

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| | |
|---|---|
| **លក្ខណៈ** | ការពិពណ៌នា |
| **លទ្ធផលសិក្សា** | វិភាគផលប៉ះពាល់នៃជំងឺសរីរាង្គជាក់លាក់ទៅលើដំណើរការរំលាយអាហារសរុប។ |
| **កម្រិតពុទ្ធិ** | វាយតម្លៃ និងបង្កើតថ្មី |
| **ទម្រង់សំណួរ** | សំណួរចម្លើយវែង |
| **កម្រិតសមត្ថភាព** | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **B. ព្រោះសន្ទះខ្យល់នៅផ្នែកខាងក្រោមនៃដើមក បិទបំពង់សំឡេងឱ្យជិត**

**សំណួរទី ២៖**

- ក. បំពង់អាហារ
- ខ. ក្រពះ
- គ. ពោះវៀនតូច

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **C. ដើម្បីបង្កើនផ្ទៃសម្រាប់ស្រូបយកអាហារដែលរលាយចូលទៅក្នុងឈាម**

**សំណួរទី ៤៖**

- ១. **មិនពិត** (ការរលាយអាហារបញ្ចប់ត្រឹមពោះវៀនតូច)
- ២. **ពិត** (មុខងារស្រូបទឹករបស់ពោះវៀនធំត្រឹមត្រូវ)
- ៣. **ពិត** (ទ្វារលើក្រពះជាចំណុចភ្ជាប់បំពង់អាហារ និងក្រពះ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ផលប៉ះពាល់៖** ជំងឺនេះ "មិនប៉ះពាល់" ដល់ការរលាយអាហារ និងការស្រូបសារជាតុចិញ្ចឹមដោយផ្ទាល់ឡើយ។
  2. **មូលហេតុ៖** ព្រោះការរលាយអាហារត្រូវបានបញ្ចប់ និងការស្រូបសារជាតុចិញ្ចឹមបានប្រព្រឹត្តទៅរួចរាល់តាំងពីនៅក្នុង **ពោះវៀនតូច** មកម្ល៉េះ។ ខ្នែងពោះវៀនស្ថិតនៅដើមពោះវៀនធំ ដែលជាកន្លែងសម្រាប់តែស្រូបយកទឹក និងអំបិលខនិជប៉ុណ្ណោះ។ (ទោះជាយ៉ាងណា វាជាគ្រោះថ្នាក់ដែលត្រូវវះកាត់)។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថា "មិនប៉ះពាល់" តែពន្យល់មិនច្បាស់ពីទីតាំងបញ្ចប់ការរំលាយអាហារ។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទ ទី២0 : ក្រពេញរំលាយអាហារ - រោងចក្រផលិតសារធាតុរាវជីវសាស្ត្រ

## អត្ថបទខ្លី៖ កម្លាំងជំនួយនៃការរំលាយអាហារ




សុខកំពុងតែអង្គុយនៅអានសៀវភៅនៅក្នុងបន្ទប់របស់គេ ស្រាប់តែធុំក្លិនឈ្ងុយពីអាហារដែលម្តាយរបស់គេកំពុងចំអិនធ្វើឱ្យគេមានអារម្មណ៍ មានទឹកដក់នៅក្នុងមាត់របស់គេ ។

សុខក៏បានយករឿងនេះទៅសួរប៉ារបស់គេ ហើយលោកប៉ាក៏បានឆ្លើយថា "នោះគឺជាសញ្ញាដែលបង្ហាញថា ក្រពេញទឹកមាត់ របស់យើងកំពុងចាប់ផ្តើមធ្វើការ! នៅក្នុងខ្លួនរបស់អ្នក មាន 'រោងចក្រគីមី' តូចៗជាច្រើនដែលគេហៅថា ក្រពេញរំលាយអាហារ។ ពួកវាផលិតទឹករសពិសេសៗដើម្បីបំបែកអាហារដែលអ្នកលេបចូល ឱ្យទៅជាថាមពលសម្រាប់អ្នករត់លេង និងរៀនសូត្រ។ បើគ្មាន 'ជំនួយការ' ទាំងនេះទេ ទោះបីជាអ្នកញ៉ាំអាហារច្រើនប៉ុណ្ណាក៏ដោយ ក៏រាងកាយរបស់អ្នកមិនអាចទទួលបានជីវជាតិពីវាបានដែរ។"

---

## សំណួរទី ១៖ ក្រពេញធំជាងគេក្នុងរាងកាយ

ផ្អែកលើអត្ថបទមេរៀន តើសរីរាង្គមួយណាជាក្រពេញធំជាងគេដែលមានពណ៌ត្នោត ទម្ងន់ប្រហែល 2kg និងស្ថិតនៅក្រោមសន្ទះទ្រូងផ្នែកខាងស្តាំ?

☐A. លំពែង ☐B. ក្រពេញទឹកមាត់ ☐C. ថ្លើម ☐D. ក្រពេញក្រពះ

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ឈ្មោះ និងលក្ខណៈរូបនៃថ្លើម។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការផ្គូផ្គងក្រពេញ និងទីតាំងបញ្ចេញរស

ចូរផ្គូផ្គងឈ្មោះក្រពេញនៅជួរ (A) ទៅនឹងទីតាំងដែលវាបញ្ចេញរសទៅឱ្យនៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| ក្រពេញ (A) | ទីតាំងដែលវាបញ្ចេញរសឱ្យ (B) | ចម្លើយ |
|---|---|---|
| ១. ក្រពេញទឹកមាត់ | ក. ក្នុងផ្ទៃក្រពះ | ១ ⇨ ...... |
| ២. ក្រពេញក្រពះ | ខ. ក្នុងប្រហោងមាត់ | ២ ⇨ ...... |
| ៣. លំពែង និងថ្លើម | គ. ក្នុងពោះវៀនតូច | ៣ ⇨ ...... |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ទំនាក់ទំនងរវាងក្រពេញ និងបំពង់រំលាយអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគជំងឺទាក់ទងនឹងក្រពេញ



សិស្សម្នាក់មានអាការៈហើមនៅក្រោមថ្គាល់ក្បែរត្រចៀក និងមានការឈឺចាប់។ គ្រូពេទ្យប្រាប់ថាគេកើតជំងឺ «**សាលាទែន**»។ តើជំងឺនេះបណ្តាលមកពីការរលាកក្រពេញមួយណា?

☐A. ក្រពេញក្រោមអណ្តាត ☐B. ក្រពេញគុម្ពត្រចៀក

☐C. ក្រពេញក្រោមថ្គាល់ ☐D. ក្រពេញលំពែង

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់អត្តសញ្ញាណជំងឺដែលទាក់ទងនឹងក្រពេញទឹកមាត់។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើមុខងារលំពែង និងថ្លើម

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. លំពែងបញ្ចេញរសលំពែងទៅក្នុងក្រពះដើម្បីរំលាយសាច់។ | ☐ | ☐ |
| ២. ទឹកប្រមាត់ដែលផលិតដោយថ្លើម ត្រូវបានរក្សាទុកក្នុងថង់ទឹកប្រមាត់មុននឹងចូលទៅក្នុងពោះវៀនតូច។ | ☐ | ☐ |
| ៣. បំពង់ទឹកប្រមាត់ និងបំពង់ទឹកលំពែង ចូលទៅក្នុងពោះវៀនតូចនៅកន្លែងខុសគ្នាស្រឡះ។ | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃទីតាំង និងដំណើរការបញ្ចេញរសរំលាយអាហារ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការសន្និដ្ឋាន

ប្រសិនបើមនុស្សម្នាក់មានបញ្ហាស្ទះ «**បំពង់ទឹកប្រមាត់**» (ដែលចេញពីថ្លើម) ប៉ុន្តែ «**ក្រពេញក្រពះ**» និង «**ក្រពេញទឹកមាត់**» របស់គាត់នៅដំណើរការជាធម្មតា។




1. តើការរំលាយអាហាររបស់គាត់នៅតែអាចប្រព្រឹត្តទៅបានពេញលេញដែរឬទេ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

2. ចូរពន្យល់ពីផលប៉ះពាល់ដែលកើតមានឡើងនៅក្នុង **ពោះវៀនតូច** ដោយផ្អែកលើខ្លឹមសារមេរៀនដែលថា ថ្លើមបញ្ចេញទឹកប្រមាត់ទៅក្នុងទីនោះក្នុងពេលរំលាយអាហារ។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគផលប៉ះពាល់នៃការបាត់បង់រសរំលាយអាហារជាក់លាក់ចំពោះដំណើរការរំលាយអាហារសរុប។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. ថ្លើម**

**សំណួរទី ២៖**

- ១-ខ ( ទឹកមាត់ ⇨ មាត់ )
- ២-ក ( រសក្រពះ ⇨ ក្រពះ )
- ៣-គ ( លំពែង/ថ្លើម ⇨ ពោះវៀនតូច )

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **B. ក្រពេញគុម្ពត្រចៀក**

**សំណួរទី ៤៖**

- ១. **មិនពិត** (លំពែងបញ្ចេញរសទៅក្នុងពោះវៀនតូច មិនមែនក្រពះទេ )
- ២. **ពិត** (ទឹកប្រមាត់រក្សាទុកក្នុងថង់ទឹកប្រមាត់ត្រឹមត្រូវ )
- ៣. **មិនពិត** (មេរៀនបញ្ជាក់ថាវាចូលទៅក្នុងពោះវៀនតូចនៅកន្លែងតែមួយ )
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ )*

**សំណួរទី ៥៖**

- **ពិន្ទុពេញ :** ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ការរំលាយអាហារ៖** មិនអាចប្រព្រឹត្តទៅបានពេញលេញ ឬល្អប្រសើរឡើយ។
    2. **ផលប៉ះពាល់៖** ព្រោះពោះវៀនតូចជាកន្លែងបញ្ចប់ការរំលាយអាហារ។ បើបំពង់ទឹកប្រមាត់ស្ទះ ទឹកប្រមាត់មិនអាចចូលទៅជួយបំបែកអាហារ ( ជាពិសេសសារជាតុខ្លាញ់ ) នៅក្នុងពោះវៀនតូចបានទេ ទោះបីជាមាត់ និងក្រពះបានធ្វើការងាររបស់វាហើយក៏ដោយ។
- **ពិន្ទុខ្លះ :** ឆ្លើយត្រូវថា "មិនពេញលេញ" តែមិនបានបញ្ជាក់ពីការរំខានដល់ការងាររបស់ពោះវៀនតូច។
- **គ្មានពិន្ទុ:** ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទ ទី២១ : យន្តការទ្វេដងនៃការរំលាយអាហារ

## អត្ថបទខ្លី៖ ម៉ាស៊ីនកិន និងប្រតិកម្មគីមីក្នុងរាងកាយ




ដើម្បីឱ្យរាងកាយទទួលបានសារជាតុចិញ្ចឹម អាហារត្រូវឆ្លងកាត់ការបំបែកតាមពីររបៀបដែលធ្វើការងារស៊ីសង្វាក់គ្នា។ របៀបទី១ គឺការប្រើកម្លាំងសាច់ដុំដើម្បីហែក និងកិនអាហារឱ្យទៅជាដុំតូចៗ។ របៀបទី២ គឺការប្រើប្រាស់ «កន្ត្រៃជីវសាស្ត្រ» ហៅថា **អង់ស៊ីម** ដើម្បីកាត់ម៉ូលេគុលអាហារធំៗឱ្យទៅជាម៉ូលេគុលតូចល្អិតបំផុត។ បើគ្មានការរួមគ្នានៃលំនាំទាំងពីរនេះទេ សារពាង្គកាយមិនអាចទាញយកថាមពលពីអាហារដែលយើងបរិភោគបានឡើយ។

## សំណួរទី ១៖ ការសម្គាល់ប្រភេទនៃការរំលាយអាហារ

ផ្អែកលើអត្ថបទមេរៀន តើលំនាំនៃការបំបែកអាហារទៅជាដុំតូចៗដោយប្រើចលនានៃសាច់ដុំ ដូចជាការទំពារដោយធ្មេញ ហៅថាអ្វី?

☐A. ការរំលាយអាហារបែបគីមី ☐B. ការរំលាយអាហារបែបមេកានិច

☐C. ការស្រូបសារជាតុចិញ្ចឹម ☐D. ប្រតិកម្មអង់ស៊ីម

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់និយមន័យនៃការរំលាយអាហារបែបមេកានិច។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ តួនាទីរបស់អង់ស៊ីម

នៅក្នុងការរំលាយអាហារបែបគីមី តើ «**អង់ស៊ីម**» មាននាទីសំខាន់អ្វីខ្លះ?

☐A. ជួយទាញសាច់ដុំក្រពះឱ្យកន្ត្រាក់កិនអាហារ។

☐B. ជាភ្នាសការពារស្រទាប់ខាងក្នុងនៃក្រពះ និងពោះវៀន។

☐C. ជួយដឹកនាំអុកស៊ីសែនទៅកាន់កោសិកាក្នុងបំពង់រំលាយអាហារ។

☐D. ជាប្រូតេអ៊ីនដែលជួយបង្កើនល្បឿននៃប្រតិកម្មគីមីក្នុងការបំបែកម៉ូលេគុលអាហារ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីនាទី និងលក្ខណៈរបស់អង់ស៊ីមក្នុងលំនាំគីមី។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការបែងចែកសកម្មភាពមេកានិច និងគីមី

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "មេកានិច" ឬ "គីមី" ចំពោះសកម្មភាពនៃការរំលាយអាហារខាងក្រោម៖

| សកម្មភាពរំលាយអាហារ | មេកានិច | គីមី |
|---|---|---|
| ១. ការកិនច្របល់អាហារដោយសាច់ដុំក្រពះ | ☐ | ☐ |
| ២. ការបំបែកម៉ូលេគុលអាហារដោយមានអង់ស៊ីមជួយ | ☐ | ☐ |
| ៣. ការប្រើធ្មេញទំពារបំបែកអាហារក្នុងមាត់ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកភាពខុសគ្នារវាងសកម្មភាពមេកានិច និងគីមី។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ២ |

### សំណួរទី ៤៖ ការវិភាគទំនាក់ទំនងមុខងារ

ហេតុអ្វីបានជាការរំលាយអាហារទាំងពីររបៀប (មេកានិច និងគីមី) ត្រូវធ្វើការរួមគ្នា?

□A. ដើម្បីឱ្យរាងកាយអាចស្រូបយកសារជាតុចិញ្ចឹមបានយ៉ាងមានប្រសិទ្ធភាព។

□B. ដើម្បីឱ្យអាហារមានពណ៌ស្អាតមុននឹងស្រូបចូលក្នុងឈាម។

□C. ដើម្បីឱ្យសាច់ដុំក្រពះលែងធ្វើការងារធ្ងន់ពេក។

□D. ដើម្បីការពារកុំឱ្យបាក់តេរីរស់នៅក្នុងពោះវៀនបាន។

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគពីភាពចាំបាច់នៃការរួមគ្នារវាងលំនាំទាំងពីរចំពោះការរស់រាន។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៤ |

---

### សំណួរទី ៥៖ ការវិភាគស្ថានភាព និងការព្យាករណ៍ (កម្រិតខ្ពស់)

មនុស្សម្នាក់មានបញ្ហាសុខភាពដែលធ្វើឱ្យរាងកាយរបស់គាត់ «**មិនអាចផលិតអង់ស៊ីម**» បានគ្រប់គ្រាន់ ប៉ុន្តែសាច់ដុំក្រពះ និងធ្មេញរបស់គាត់នៅដំណើរការយ៉ាងល្អ។

1. តើការរំលាយអាហាររបស់គាត់នឹងជួបបញ្ហាអ្វីខ្លះ?

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

2. ទោះបីជាគាត់ទំពាអាហារឱ្យម៉ដ្ឋ (មេកានិច) យ៉ាងណាក៏ដោយ តើកោសិការបស់គាត់អាចទទួលបានសារជាតុចិញ្ចឹមពេញលេញដែរឬទេ? ចូរពន្យល់ដោយផ្អែកលើនិយមន័យនៃ "អង់ស៊ីម" និង "ម៉ូលេគុលតូចល្អិត"។

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃផលប៉ះពាល់នៃការបាត់បង់មុខងារតេីមី (អង់ស៊ីម) ចំពោះការស្រូបសារជាតុចិញ្ចឹម។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **D. ការរំលាយអាហារបែបមេកានិច**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **A. ជាប្រូតេអ៊ីនដែលជួយបង្កើនល្បឿននៃប្រតិកម្មគីមី...**

**សំណួរទី ៣៖**

- ១. **មេកានិច** (ចលនាសាច់ដុំ)
- ២. **គីមី** (ប្រតិកម្មអង់ស៊ីម)
- ៣. **មេកានិច** (ចលនាធ្មេញ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៤៖**

- ចម្លើយត្រូវ៖ **B. ដើម្បីឱ្យរាងកាយអាចស្រូបយកសារជាតុចិញ្ចឹមបានយ៉ាងមានប្រសិទ្ធភាព**

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខណៈពីរ៖
  1. **បញ្ហា៖** ការរំលាយអាហាររបស់គាត់នឹងមិនពេញលេញទេ (មានតែមេកានិច គ្មានគីមី)។
  2. **ការពន្យល់៖** ទោះបីអាហារក្លាយជាដុំតូចៗដោយសារការទំពា ប៉ុន្តែបើគ្មានអង់ស៊ីមដើម្បីបំបែក «ម៉ូលេគុលធំ» ឱ្យទៅជា «ម៉ូលេគុលតូចល្អិតបំផុត» ទេ នោះសារជាតុចិញ្ចឹមមិនអាចជ្រាបចូលតាមភ្នាសពោះវៀនទៅក្នុងឈាមដើម្បីចិញ្ចឹមកោសិកាបានឡើយ។ ដូច្នេះកោសិកានៅតែខ្វះជីវជាតិដដែល។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថា "មិនបានពេញលេញ" តែមិនបានបញ្ជាក់ពីតួនាទីអង់ស៊ីមក្នុងការបំបែកម៉ូលេគុលឱ្យតូចសម្រាប់ស្រូបចូលឈាម។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ២២ : សារធាតុចិញ្ចឹម និងកន្ត្រែជីវសាស្ត្រអង់ស៊ីម

## អត្ថបទខ្លី៖ ថាមពល និងការកែច្នៃអាហារ

រាងកាយរបស់យើងត្រូវការអាហារខុសៗគ្នាដើម្បីដំណើរការ។ អាហារដែលយើងបរិភោគត្រូវបានបែងចែកជា ៣ ក្រុមធំៗ គឺប្រូតេអ៊ីនសម្រាប់ស្ថាបនា កាបូអ៊ីដ្រាតសម្រាប់ថាមពល និងខ្លាញ់សម្រាប់ស្តុកថាមពល។ ដើម្បីបំបែកអាហារទាំងនេះឱ្យទៅជាសារជាតុចិញ្ចឹមតូចៗដែលរាងកាយអាចស្រូបយកបាន ប្រដាប់រំលាយអាហារប្រើប្រាស់សារធាតុគីមីពិសេសហៅថា **អង់ស៊ីម**។ អង់ស៊ីមនីមួយៗប្រៀបដូចជា "សោ និងកូនសោ" ដែលមាននាទីជាក់លាក់សម្រាប់តែប្រភេទអាហារមួយមុខប៉ុណ្ណោះ។




---

## សំណួរទី ១៖ ការបែងចែកក្រុមអាហារ

ប្រសិនបើសិស្សម្នាក់ចង់ជ្រើសរើសអាហារដែលផ្តល់ «**ប្រភពថាមពលចម្បង**» ដល់រាងកាយ តើគាត់គួរជ្រើសរើសយកអាហារប្រភេទណា?

☐A. សាច់សត្វ និងត្រី ☐B. ស៊ុត និងសណ្តែកសៀង

☐C. ប្រេងឆា និងខ្លាញ់សត្វ ☐D. បាយ ដំឡូង និងនំប៉័ង

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ប្រភេទអាហារដែលជាប្រភពថាមពលចម្បង (កាបូអ៊ីដ្រាត)។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ លក្ខណៈជាក់លាក់នៃអង់ស៊ីម

ផ្អែកលើអត្ថបទមេរៀន តើឃ្លាមួយណាដែលពណ៌នាពី «**លក្ខណៈជាក់លាក់**» របស់អង់ស៊ីមបានត្រឹមត្រូវបំផុត?

□A. អង់ស៊ីមមួយប្រភេទអាចបំបែកអាហារបានគ្រប់ប្រភេទក្នុងពេលតែមួយ។

□B. អង់ស៊ីមដែលបំបែកខ្លាញ់ ក៏អាចបំបែកប្រូតេអ៊ីនបានផងដែរ។

□C. អង់ស៊ីមនីមួយៗមាននាទីបំបែកតែប្រភេទអាហារណាមួយជាក់លាក់ប៉ុណ្ណោះ។

□D. អង់ស៊ីមមាននាទីពន្យឺតប្រតិកម្មគីមីដើម្បីកុំឱ្យរាងកាយក្តៅពេក។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីលក្ខណៈជាក់លាក់របស់អង់ស៊ីម។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគនាទីនៃសារធាតុចិញ្ចឹម

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ប្រូតេអ៊ីនមានសារៈសំខាន់សម្រាប់ការលូតលាស់ និងជួសជុលកោសិកា។ | ☐ | ☐ |
| ២. ខ្លាញ់ជួយដល់ការស្រូបយកវីតាមីននៅក្នុងរាងកាយ។ | ☐ | ☐ |
| ៣. អង់ស៊ីមគឺជាម៉ូលេគុលអាហារធំៗដែលមិនអាចជ្រាបចូលតាមភ្នាសពោះវៀន។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើនាទីនៃសារធាតុចិញ្ចឹម និងធម្មជាតិរបស់អង់ស៊ីម។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ការផ្គូផ្គងអាហារ និងក្រុមសារជាតុ

ចូរផ្គូផ្គងប្រភេទអាហារនៅជួរ (A) ទៅនឹងក្រុមសារជាតុចិញ្ចឹមរបស់វានៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| អាហារ (A) | ក្រុមសារជាតុចិញ្ចឹម (B) | ចម្លើយ |
|---|---|---|
| ១. សណ្ដែកដី និងប្រេងដូង | ក. ប្រូតេអ៊ីន | ១ ⇨ ...... |
| ២. គ្រាប់ធញ្ញជាតិ និងបាយ | ខ. កាបូអ៊ីដ្រាត (គ្លុយស៊ីត) | ២ ⇨ ...... |
| ៣. សាច់ត្រី និងស៊ុត | គ. ខ្លាញ់ (លីពីត) | ៣ ⇨ ...... |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកអាហារតាមក្រុមសារជាតុចិញ្ចឹមឱ្យបានត្រឹមត្រូវ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការសន្និដ្ឋាន (កម្រិតខ្ពស់)

អ្នកវិទ្យាសាស្ត្របានធ្វើពិសោធន៍មួយដោយដាក់ **«អង់ស៊ីមដែលបំបែកប្រូតេអ៊ីន»** ទៅក្នុងកែវពិសោធន៍ដែលមានផ្ទុក **«បាយ និងដំឡូង»**។ ជាលទ្ធផល គេសង្កេតឃើញថា បាយ និងដំឡូងទាំងនោះមិនមានការផ្លាស់ប្ដូរទៅជាម៉ូលេគុលតូចៗឡើយ។

1. ផ្អែកលើអត្ថបទមេរៀន ចូរពន្យល់ពីមូលហេតុដែលការបំបែកអាហារមិនកើតឡើងក្នុងពិសោធន៍នេះ?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

2. តើគេត្រូវបន្ថែមអង់ស៊ីមប្រភេទណា ទើបអាចបំបែកបាយ និងដំឡូងបាន?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគលក្ខណៈជាក់លាក់នៃអង់ស៊ីមតាមរយៈលទ្ធផលពិសោធន៍។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៤ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **D. បាយ ដំឡូង និងនំប៉ុង**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **C. អង់ស៊ីមនីមួយៗមាននាទីបំបែកតែប្រភេទអាហារណាមួយជាក់លាក់ប៉ុណ្ណោះ**

**សំណួរទី ៣៖**

- ១. **ពិត** (នាទីប្រូតេអ៊ីនត្រឹមត្រូវ)
- ២. **ពិត** (នាទីខ្លាញ់ក្នុងការស្រូបវីតាមីនត្រឹមត្រូវ)
- ៣. **មិនពិត** (អង់ស៊ីមជាអ្នកជួយបំបែកអាហារ មិនមែនជាម៉ូលេគុលអាហារដែលត្រូវស្រូបទេ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៤៖**

- ចម្លើយត្រូវ៖
    - **១** ⇨ **គ.** ខ្លាញ់ (លីពីត)
    - **២** ⇨ **ខ.** កាបូអ៊ីដ្រាត (គ្លុយស៊ីត)
    - **៣** ⇨ **ក.** ប្រូតេអ៊ីន

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **មូលហេតុ៖** ព្រោះអង់ស៊ីមមានលក្ខណៈជាក់លាក់។ អង់ស៊ីមបំបែកប្រូតេអ៊ីនមិនអាចបំបែកកាបូអ៊ីដ្រាត (បាយ និងដំឡូង) បានឡើយ។
    2. **ដំណោះស្រាយ៖** គេត្រូវបន្ថែម «**អង់ស៊ីមដែលបំបែកកាបូអ៊ីដ្រាត**» (ឬអង់ស៊ីមដែលជាក់លាក់សម្រាប់បាយ/ដំឡូង) ទើបអាចបំបែកវាបាន។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែមួយផ្នែក (ឧ. និយាយថាអង់ស៊ីមខុសប្រភេទ តែមិនបានបញ្ជាក់ពីប្រភេទអង់ស៊ីមដែលត្រូវបន្ថែម)។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# មេរៀនទី៣ ការរំលាយអាហារ

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ២៣ : ខ្សែសង្វាក់គីមី និងមេកានិចនៃដំណើរការរំលាយអាហារ

### អត្ថបទខ្លី៖ ដំណើរផ្សងព្រេងនៃអាហារក្នុងខ្លួនរបស់ "សុខ"




ថ្ងៃនេះ សុខ បានញ៉ាំបាយសាច់ជ្រូកយ៉ាងឆ្ងាញ់សម្រាប់អាហារពេលព្រឹក។ តោះ! ទៅតាមដានដំណើរផ្សងព្រេងនៃបាយសាច់ជ្រូកនោះក្នុងខ្លួនរបស់ សុខ ទាំងអស់គ្នា៖

ដំណើរចាប់ផ្តើមនៅ មាត់ ដែលធ្មេញរបស់សុខ កិនបំបែកបាយ និងសាច់ឱ្យទៅជាដុំតូចៗ (មេកានិច) ហើយទឹកមាត់ចាប់ផ្តើមរំលាយជាតិម្សៅក្នុងបាយ (គីមី)។ បន្ទាប់មក អាហារក៏ធ្លាក់ទៅដល់ ក្រពះ ដែលនៅទីនោះមានអាស៊ីត និងអង់ស៊ីមខ្លាំងៗរង់ចាំ 'វាយប្រហារ' ទៅលើជាតិសាច់ (ប្រូតេអ៊ីន)។

បន្តិចក្រោយមក អាហារដែលម៉ត់ដូចបបរ ក៏ហូរចូលទៅដល់ ពោះវៀនតូច ដែលជាកន្លែងសំខាន់បំផុត ព្រោះវាមានទាំងភ្នាក់ងាររំលាយជាតិខ្លាញ់ពីថ្លើម និងលំពែង។ នៅទីនេះហើយដែលរាងកាយរបស់ សុខ ចាប់ផ្តើមបឺតស្រូបយកជីវជាតិទៅចិញ្ចឹមសាច់ដុំឱ្យគាត់មានកម្លាំង។ ចំណែកឯកាកសំណល់ដែលនៅសល់ នឹងត្រូវបញ្ជូនទៅ ពោះវៀនធំ ដើម្បីបញ្ចេញមកក្រៅវិញ។

## សំណួរទី ១៖ ការរំលាយអាហារដំបូងនៅក្នុងមាត់

ផ្អែកលើអត្ថបទមេរៀន តើសារធាតុចិញ្ចឹមមួយណាដែលចាប់ផ្ដើមរំលាយ «**បែបគីមី**» ដំបូងគេបង្អស់នៅក្នុងមាត់?

□A. ប្រូតេអ៊ីន □B. ខ្លាញ់ □C. អាមីដុង □D. វីតាមីន

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ប្រភេទសារធាតុដែលរំលាយដំបូងគេដោយអង់ស៊ីមអាមីឡាស។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ យន្តការការពារ និងការរំលាយក្នុងក្រពះ

នៅក្នុងក្រពះមានផលិត **អាស៊ីតក្លរីឌ្រិច (HCl)**។ តើមុខងារមួយណាខាងក្រោមដែល «**មិនមែន**» ជាតួនាទីរបស់អាស៊ីត HCl ទេ?

□A. សម្លាប់បាក់តេរីដែលចូលមកជាមួយអាហារ។

□B. បំបែកខ្លាញ់ឱ្យទៅជាអាស៊ីតខ្លាញ់ និងគ្លីសេរ៉ុល។

□C. ផ្ដល់ pH សមស្របសម្រាប់អង់ស៊ីមប៉ិបស៊ីនធ្វើការ។

□D. ធ្វើឱ្យប្រូតេអ៊ីនប្រែប្រួលទ្រង់ទ្រាយដើម្បីងាយស្រួលរំលាយ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់តួនាទីពិតប្រាកដនៃអាស៊ីតក្រពះក្នុងដំណើរការរំលាយអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគការបំបែកសារជាតុចិញ្ចឹមចុងក្រោយ

នៅក្នុង **ពោះវៀនតូច** ម៉ូលេគុលអាហារធំៗត្រូវបានបំបែកទៅជាទម្រង់តូចបំផុត។ ចូរផ្គូផ្គងសារជាតុនៅជួរ (A) ទៅនឹងលទ្ធផលនៃការបំបែកចុងក្រោយនៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| សារជាតុដើម (A) | លទ្ធផលបំបែកចុងក្រោយ (B) | ចម្លើយ |
|---|---|---|
| ១. អាមីដុង | ក. អាស៊ីតអាមីនេ | ១ ⇨ ...... |
| ២. ប្រូតេអ៊ីន | ខ. អាស៊ីតខ្លាញ់ និងគ្លីសេរ៉ុល | ២ ⇨ ...... |
| ៣. ខ្លាញ់ | គ. ស្ករងាយ | ៣ ⇨ ...... |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកលទ្ធផលចុងក្រោយនៃរំលាយអាហារតាមប្រភេទសារជាតុចិញ្ចឹម។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើមុខងារពោះវៀនធំ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ពោះវៀនធំមាននាទីក្នុងការស្រូបយកទឹក និងអំបិលខនិជទៅក្នុងឈាម។ | ☐ | ☐ |
| ២. ការបំបែកអាហារបែបគីមីនៅតែបន្តកើតមានយ៉ាងខ្លាំងក្លានៅក្នុងពោះវៀនធំ។ | ☐ | ☐ |
| ៣. លាមកត្រូវបានស្តុកទុកជាបណ្តោះអាសន្ននៅត្រង់ចុងពោះវៀនធំ ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃមុខងារពោះវៀនធំ និងការបញ្ចេញកាកសំណល់។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការព្យាករណ៍

ប្រសិនបើមនុស្សម្នាក់មានបញ្ហាសុខភាពដែលធ្វើឱ្យ «**លំពែង**» របស់គាត់មិនអាចផលិតរសលំពែងបាន ប៉ុន្តែ «**ទឹកប្រមាត់**» ពីថ្លើមនៅតែហូរចូលពោះវៀនតូចជាធម្មតា។

1. ផ្អែកលើមេរៀន តើការបំបែកសារធាតុចិញ្ចឹម (កាបូអ៊ីដ្រាត ខ្លាញ់ និងប្រូតេអ៊ីន) នៅក្នុងពោះវៀនតូចនឹងជួបផលវិបាកអ្វីខ្លះ?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

2. តើការមានតែទឹកប្រមាត់គ្រប់គ្រាន់សម្រាប់បំបែកខ្លាញ់ឱ្យទៅជាទម្រង់តូចៗដែលរាងកាយអាចស្រូបយកបានដែរឬទេ? ចូរពន្យល់។

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគ និងបកស្រាយនាទីដាច់ដោយឡែករវាងទឹកប្រមាត់ និងរសលំពែង។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៤ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. អាមីដុង (កាបូអ៊ីដ្រាត)**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **B. បំបែកខ្លាញ់ឱ្យទៅជាអាស៊ីតខ្លាញ់ និងគ្លីសេរ៉ុល** ( HCl មិនមែនជាអង់ស៊ីមបំបែកខ្លាញ់ទេ )។

**សំណួរទី ៣៖**

- ១ ⇨ **គ.** ស្ករងាយ
- ២ ⇨ **ក.** អាស៊ីតអាមីនេ
- ៣ ⇨ **ខ.** អាស៊ីតខ្លាញ់ និងគ្លីសេរ៉ុល

**សំណួរទី ៤៖**

- ១. **ពិត** (ពោះវៀនធំស្រូបយកទឹក និងអំបិលខនិជ )
- ២. **មិនពិត** (ការរំលាយអាហារបានបញ្ចប់តាំងពីក្នុងពោះវៀនតូច )
- ៣. **ពិត** (ពោះវៀនធំ ជាកន្លែងស្តុកលាមក )
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ផលវិបាក៖** ការបំបែក កាបូអ៊ីដ្រាត ខ្លាញ់ និងប្រូតេអ៊ីន នឹងមិនអាចប្រព្រឹត្តទៅបានពេញលេញទេ ព្រោះអង់ស៊ីមក្នុងសេលំពែងមាននាទីបំបែកសារធាតុទាំង ៣ នេះ។
  2. **ការបកស្រាយទឹកប្រមាត់៖** ទឹកប្រមាត់តែម្យ៉ាង "មិនអាច" បំបែកខ្លាញ់ឱ្យទៅជាទម្រង់ដែលស្រូបយកបានឡើយ។ ទឹកប្រមាត់គ្រាន់តែជួយបំបែកខ្លាញ់ឱ្យមានប្រសិទ្ធភាព (បែបមេកានិច ) ប៉ុន្តែត្រូវការអង់ស៊ីមពីលំពែងទើបអាចបំបែកខ្លាញ់ទៅជាអាស៊ីតខ្លាញ់ និងគ្លីសេរ៉ុល (បែបគីមី ) ដើម្បីស្រូបយកបាន។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាការរំលាយជួបបញ្ហា តែមិនបានបញ្ជាក់ច្បាស់ពីភាពខុសគ្នារវាងនាទីទឹកប្រមាត់ និងអង់ស៊ីមលំពែង។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ២៤ : សម្រូបអាហារ និងខ្សែច្រវាក់ចែកចាយសារធាតុចិញ្ចឹម

## អត្ថបទខ្លី៖ ពីពោះវៀនទៅកាន់កោសិកា

ការរំលាយអាហារគ្រាន់តែជាដំណាក់កាលដំបូងប៉ុណ្ណោះ។ ដើម្បីឱ្យរាងកាយទទួលបានថាមពល អាហារដែលរលាយរួចត្រូវឆ្លងកាត់ភ្នាសពោះវៀនចូលទៅក្នុងចរន្តឈាម ដែលយើងហៅថា **«សម្រូបអាហារ»**។ ពោះវៀនតូចមានរចនាសម្ព័ន្ធពិសេសហៅថា **ជ្រាំងពោះវៀន** ដើម្បីបង្កើនល្បឿននៃលំនាំនេះ។ បន្ទាប់មក ថ្លើមដើរតួជានាយកដ្ឋានគ្រប់គ្រង និងចែកចាយសារជាតុចិញ្ចឹមទាំងនោះទៅកាន់សាច់ដុំ និងសរីរាង្គផ្សេងៗតាមតម្រូវការជាក់ស្តែង។




## សំណួរទី ១៖ រចនាសម្ព័ន្ធជ្រាំងពោះវៀន

ផ្អែកលើអត្ថបទមេរៀន តើ «**ជ្រាំងពោះវៀន** » មានលក្ខណៈពិសេសអ្វីខ្លះដែលជួយឱ្យសម្រូបអាហារប្រព្រឹត្តទៅបានយ៉ាងល្អ?

☐A. វាបង្កើនទំហំផ្ទៃពោះវៀនតូច និងមានកោសិកាក្រាស់តែមួយស្រទាប់។

☐B. វាមានកោសិកាក្រាស់ច្រើនស្រទាប់ដើម្បីការពារឈាម។

☐C. វាផលិតអង់ស៊ីមសម្រាប់បំបែកសែលុយឡូសក្នុងពោះវៀនតូច។

☐D. វាមាននាទីស្រូបយកទឹក និងអំបិលខនិជត្រឡប់មកវិញ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់លក្ខណៈរូប និងនាទីរបស់ជ្រាំងពោះវៀនក្នុងសម្រូបអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ តួនាទីបាក់តេរីក្នុងពោះវៀនធំ

បាក់តេរីដែលរស់នៅក្នុងពោះវៀនធំមានទំនាក់ទំនងសហប្រាណជាមួយមនុស្ស។ តើអត្ថប្រយោជន៍មួយណាដែលមនុស្សទទួលបានពីបាក់តេរីទាំងនោះ?

□A. ជួយស្រូបយកស្ករងាយ (គ្លុយកូស) ចូលក្នុងឈាម។

□B. ជួយជួសជុលជាលិកាដែលខូចខាតក្នុងពោះវៀនធំ។

□C. បំបែកកាកសំណល់សែលុយឡូស និងផលិតវីតាមីន K និង B កុំផ្លិច។

□D. ជួយបញ្ចេញកាបូនឌីអុកស៊ីតទៅក្នុងបរិយាកាស។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់នាទីរបស់បាក់តេរីក្នុងពោះវៀនធំចំពោះសុខភាព។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគការចែកចាយសារធាតុចិញ្ចឹម

ក្រោយពីអាហាររលាយជ្រាបចូលក្នុងសរសៃឈាមនៃពោះវៀនតូច តើសរីរាង្គមួយណាជា «**គោលដៅដំបូង**» ដែលឈាមផ្ទុកសារធាតុចិញ្ចឹមត្រូវហូរទៅកាន់?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ស្គាល់នាទីថ្លើមជាអ្នកទទួល និងគ្រប់គ្រងសារធាតុចិញ្ចឹមដំបូងគេ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ចម្លើយខ្លី |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើតុល្យភាពសារធាតុក្នុងថ្លើម

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ស្ករលើសត្រូវបានស្តុកទុកក្នុងថ្លើមក្រោមទម្រង់ជា គ្លីកូសែន ។ | ☐ | ☐ |
| ២. អាស៊ីតអាមីនេដែលលើសមិនអាចផ្តល់ជាថាមពលបានឡើយ។ | ☐ | ☐ |
| ៣. វីតាមីនត្រូវបានស្តុកទុកក្នុងថ្លើម និងបញ្ចេញទៅក្នុងឈាមនៅពេលរាងកាយត្រូវការ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើលំនាំស្តុកទុក និងការប្រើប្រាស់សារធាតុចិញ្ចឹមក្នុងថ្លើម។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការព្យាករណ៍

កីឡាករម្នាក់បានរត់ប្រណាំងយ៉ាងខ្លាំងក្លារហូតដល់អស់កម្លាំង។ ក្នុងពេលនោះ រាងកាយរបស់គាត់ត្រូវការថាមពលជាបន្ទាន់ ប៉ុន្តែគាត់មិនទាន់បានបរិភោគអ្វីឡើយ។




1. ផ្អែកលើមេរៀនស្តីពី "ការប្រើប្រាស់អាហាររលាយ" តើ «**ថ្លើម**» របស់គាត់នឹងឆ្លើយតបយ៉ាងដូចម្តេចដើម្បីផ្តល់ថាមពលឱ្យសាច់ដុំរបស់គាត់បន្តធ្វើចលនាបាន?

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

2. ចូរពន្យល់ពីលំនាំនៃការផ្លាស់ប្តូរសារជាតុដែលស្តុកទុកក្នុងថ្មើម។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគលំនាំបំលែងត្តីកូសែនទៅជាគ្លុយកូសក្នុងស្ថានភាពខ្វះថាមពល។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ A. **វាបង្កើនទំហំផ្ទៃពោះវៀនតូច និងមានកោសិកាក្រាស់តែមួយស្រទាប់** (ដើម្បីឱ្យអាហារជ្រាបចូលងាយ)។

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **C. បំបែកកាកសំណល់សែលុយឡូស និងផលិតវីតាមីន K និង B កុំផ្លិច**។

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **ថ្លើម**។

**សំណួរទី ៤៖**

- ១. **ពិត** (លំនាំស្តុកស្ករលើសត្រឹមត្រូវ)
- ២. **មិនពិត** (មេរៀនបញ្ជាក់ថាអាស៊ីតអាមីណូលើសអាចបំបែកផ្តល់ជាថាមពលបាន)
- ៣. **ពិត** (ថ្លើមជាកន្លែងស្តុកវីតាមីន)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ការឆ្លើយតប៖** ថ្លើមនឹងបញ្ចេញស្ករដែលស្តុកទុកឱ្យទៅក្នុងចរន្តឈាមដើម្បីបញ្ជូនទៅកាន់សាច់ដុំ។
  2. **លំនាំបំលែង៖** ថ្លើមបំលែង «**គ្លីកូសែន**» ដែលជាទម្រង់ស្តុកទុក ឱ្យត្រឡប់ទៅជា «**ស្ករងាយ (គ្លុយកូស)**» វិញ ដើម្បីផ្តល់ថាមពលភ្លាមៗដល់រាងកាយក្នុងស្ថានភាពអាសន្ន។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាថ្លើមបញ្ចេញស្ករ តែមិនបានបញ្ជាក់ពីការបំលែងគ្លីកូសែនទៅជាគ្លុយកូស។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# មេរៀនទី៤ ជំងឺ និងអនាម័យប្រដាប់រំលាយអាហារ

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ២៥ : អនាម័យមាត់ធ្មេញ និងសុខភាពប្រដាប់រំលាយអាហារ

### អត្ថបទខ្លី៖ នារី និងការស្វែងយល់ពី "សត្រូវអាថ៌កំបាំង" របស់ធ្មេញ




ថ្ងៃនេះ **នារី** មានអារម្មណ៍ស្រៀវ និងឈឺធ្មេញនៅពេលញ៉ាំទឹកត្រជាក់ ទើបម្តាយនាំនាងទៅជួបលោកគ្រូពេទ្យធ្មេញ។ នៅទីនោះ លោកគ្រូពេទ្យបានពន្យល់នារីថា៖ "ធ្មេញរបស់ក្មួយគឺជាអ្នកយាមទ្វារដំបូងបង្អស់នៃរាងកាយ។ បើក្មួយទំពាអាហារមិនម៉ដ្ឋទេ ក្រពះរបស់ក្មួយនឹងត្រូវធ្វើការហត់ខ្លាំង"។

រួចមក លោកគ្រូពេទ្យបានយកកញ្ចក់តូចមួយមកបង្ហាញនារីពីប្រហោងតូចមួយលើធ្មេញថ្គាម ហើយប្រាប់ថា៖ "នេះមកពីបាក់តេរីតូចៗស៊ីសំណល់ជាតិស្ករដែលជាប់នឹងធ្មេញក្មួយ រួចពួកវាបញ្ចេញអាស៊ីតមកបំផ្លាញកាចាធ្មេញដែលរឹងមាំឱ្យទៅជាប្រហោង។ បើក្មួយទុកឱ្យប្រហោងនេះជ្រៅទៅៗ វានឹងស៊ីដល់សរសៃប្រសាទ ទើបធ្វើឱ្យក្មួយឈឺបែបនេះ"។ នារីក៏យល់ព្រមឱ្យលោកគ្រូពេទ្យប៉ះធ្មេញ ហើយសន្យាថានឹងដុសធ្មេញឱ្យបានត្រឹមត្រូវដើម្បីការពារ 'អ្នកយាមទ្វារ' របស់នាង។

### សំណួរទី ១៖ ទំនាក់ទំនងរវាងធ្មេញ និងក្រពះ

ផ្អែកលើអត្ថបទមេរៀន ហេតុអ្វីបានជាការទំពាអាហារមិនបានម៉ដ្ឋល្អ អាចបណ្តាលឱ្យមានជំងឺឈឺក្រពះ និងពោះវៀន?

☐A. ព្រោះក្រពះមិនអាចរំលាយអាហារដែលរឹងបានឡើយ។

☐B. ព្រោះវាបង្ខំឱ្យប្រដាប់រំលាយអាហារធ្វើការច្រើន និងហត់ខ្លាំងក្នុងការកិនបំបែក។

☐C. ព្រោះអាហារមិនម៉ដ្ឋធ្វើឱ្យអង់ស៊ីមនៅក្នុងមាត់កើនឡើងខ្លាំងពេក។

☐D. ព្រោះធ្មេញមិនល្អបញ្ចេញបាក់តេរីទៅក្នុងក្រពះ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគទំនាក់ទំនងរវាងគុណភាពនៃការទំពា និងប្រសិទ្ធភាពរំលាយអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

---

### សំណួរទី ២៖ ដំណើរការនៃការកកើតប្រហោងធ្មេញ

តើបាក់តេរីនៅក្នុងមាត់បង្កើតជា «**អាស៊ីត**» ស៊ីកាចាធ្មេញ និងភ្លុកធ្មេញតាមរបៀបណា?

☐A. តាមរយៈការផ្លាស់ប្តូរសីតុណ្ហភាពពីក្តៅទៅត្រជាក់ភ្លាមៗ។

☐B. តាមរយៈការបំប្លែងជាតិស្ករដែលមានក្នុងកម្ទេចអាហារ។

☐C. តាមរយៈការខាំវត្ថុរឹងខ្លាំងដែលធ្វើឱ្យប្រេះធ្មេញ។

☐D. តាមរយៈការផលិតជាតិកាល់ស្យូមចេញពីទឹកមាត់។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ប្រាប់ពីប្រតិកម្មគីមីរវាងបាក់តេរី ជាតិស្ករ និងការបំផ្លាញរចនាសម្ព័ន្ធធ្មេញ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវាយតម្លៃលើមូលហេតុនៃធ្មេញខូច

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ក្តាំងជើងធ្មេញគឺជាកន្លែងដែលមេរោគស្នាក់នៅ និងបង្កឱ្យហើមជើងធ្មេញ។ | ☐ | ☐ |
| ២. ការប្រេះកាចាធ្មេញអាចបណ្តាលមកពីការបរិភោគទឹកកករួចបន្តញុំាទឹកក្តៅភ្លាម។ | ☐ | ☐ |
| ៣. កាលណាប្រហោងធ្មេញធ្លុះដល់ក្លកធ្មេញ យើងនឹងបាត់បង់អារម្មណ៍ឈឺចាប់ភ្លាម។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើកត្តារូបសាស្ត្រ និងជីវសាស្ត្រដែលបណ្តាលឱ្យខូចធ្មេញ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយធ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ វិធីសាស្ត្រថែរក្សាធ្មេញ

យោងតាមការណែនាំក្នុងមេរៀន តើចំណុចណាខ្លះដែលជួយការពារធ្មេញឱ្យមានសុខភាពល្អ? (ជ្រើសរើសបានលើសពីមួយ)

☐A. ពិនិត្យធ្មេញនៅមន្ទីរពេទ្យឱ្យបានទៀងទាត់ (រាល់ ៦ ខែម្តង)។

☐B. ប្រើឈើចាក់ធ្មេញចាក់ចន្លោះធ្មេញឱ្យបានច្រើនដងក្នុងមួយថ្ងៃ។

☐C. ដុសធ្មេញយ៉ាងតិច ២ ដងក្នុងមួយថ្ងៃ បន្ទាប់ពីបរិភោគអាហាររួច។

☐D. បរិភោគភេសជ្ជៈផ្អែមៗជារៀងរាល់ថ្ងៃដើម្បីផ្តល់ថាមពលដល់ធ្មេញ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ទម្លាប់អនាម័យត្រឹមត្រូវដើម្បីការពារធ្មេញ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស (ជ្រើសរើសច្រើន) |
| កម្រិតសមត្ថភាព | កម្រិត ២ |

# សំណួរទី ៥៖ ការវិភាគស្ថានភាព និងការសន្និដ្ឋាន




រតនាមានធ្មេញប្រហោងធំមួយដែលធ្លុះដល់ «**បណ្ដូលធ្មេញ**»។ គេមានអារម្មណ៍ឈឺចាប់ខ្លាំង ប៉ុន្តែគេមិនព្រមទៅព្យាបាលនៅមន្ទីរពេទ្យឡើយ ដោយគិតថាវានឹងបាត់ឈឺទៅវិញដោយខ្លួនឯង។

1. ផ្អែកលើមេរៀន តើការសន្និដ្ឋានរបស់រតនាត្រឹមត្រូវដែរឬទេ?

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

2. ប្រសិនបើគេបន្តទុកធ្មេញនោះដោយមិនព្យាបាល តើអាចមានផលវិបាកអ្វីខ្លះកើតឡើងចំពោះ «ឫសធ្មេញ» ឬ «ឆ្អឹងថ្គាម» របស់គេ? ចូរពន្យល់។

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | ព្យាករណ៍ផលវិបាកនៃការមិនព្យាបាលជំងឺធ្មេញដែលរីករាលដាលដល់បណ្ដូលធ្មេញ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **D. ព្រោះវាបង្ខំឱ្យប្រដាប់រំលាយអាហារធ្វើការច្រើន និងហត់ខ្លាំងក្នុងការកិនបំបែក**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **B. តាមរយៈការបំប្លែងជាតិស្ករដែលមានក្នុងកម្ទេចអាហារ**

**សំណួរទី ៣៖**

- ១. **ពិត** (ក្តាំងជើងធ្មេញជាកន្លែងស្នាក់នៅរបស់មេរោគ)
- ២. **ពិត** (ការប្តូរសីតុណ្ហភាពលឿនធ្វើឱ្យកាចាធ្មេញស្រួយ និងប្រេះ)
- ៣. **មិនពិត** (កាលណាធ្លុះដល់បណ្តូលដែលមានសរសៃប្រសាទ ទើបមានការឈឺចាប់ខ្លាំង)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៤៖** ចម្លើយត្រូវ៖ **A និង C**

**សំណួរទី ៥៖**

- **ពិន្ទុពេញ :** ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ការវាយតម្លៃ៖** ការសន្និដ្ឋានរបស់វេតនាមិនត្រឹមត្រូវទេ (ធ្មេញមិនអាចជាដោយខ្លួនឯងបានឡើយ)។
    2. **ផលវិបាក៖** ប្រសិនបើទុកចោល វានឹងបង្កឱ្យមានការឆ្លងមេរោគធ្ងន់ធ្ងរ រហូតដល់មានខ្ទុះនៅចុងឫសធ្មេញ ឬអាចឈានដល់ការរលាកឆ្អឹងថ្គាម ដែលធ្វើឱ្យការឈឺចាប់កាន់តែខ្លាំង និងពិបាកក្នុងការព្យាបាល។
- **ពិន្ទុខ្លះ :** ឆ្លើយត្រូវថាមានខ្ទុះ តែមិនបានបញ្ជាក់ពីការរលាកឆ្អឹងថ្គាម ឬការសន្និដ្ឋានខុស។
- **គ្មានពិន្ទុ :** ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ២៦ : ទម្លាប់បរិភោគ និងសុខភាពប្រព័ន្ធរំលាយអាហារ

## អត្ថបទខ្លី៖ របៀបរស់នៅដើម្បីប្រព័ន្ធរំលាយអាហារមាំមួន




ការរំលាយអាហារមិនមែនអាស្រ័យតែលើសរីរាង្គដែលមានសុខភាពល្អប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាស្រ័យយ៉ាងខ្លាំងលើទម្លាប់នៃការបរិភោគប្រចាំថ្ងៃរបស់យើងផងដែរ។ ការជ្រើសរើសប្រភេទអាហារ ការរក្សាអារម្មណ៍ក្នុងពេលបរិភោគ និងការយល់ដឹងពីឥទ្ធិពលនៃភេសជ្ជៈ ឬសារធាតុញៀន គឺជាកត្តាចម្បងដែលជួយឱ្យប្រព័ន្ធរំលាយអាហារដំណើរការបានយ៉ាងរលូន។ ការធ្វេសប្រហែសចំពោះអនាម័យ និងទម្លាប់បរិភោគ អាចបណ្តាលឱ្យមានការពុលទូទៅដល់សារពាង្គកាយតាមរយៈការទល់លាមក និងការចុះខ្សោយនៃសរសៃរំលាយអាហារ។

---

### សំណួរទី ១៖ ការជ្រើសរើសរបបអាហារ

យោងតាមអត្ថបទមេរៀន តើរបបអាហារបែបណាដែលត្រូវបានណែនាំដើម្បីថែរក្សាប្រដាប់រំលាយអាហារឱ្យមានសុខភាពល្អ?

□A. អាហារដែលមានខ្លាញ់ច្រើន និងសៃលុយឡូសតិច។

□B. អាហារដែលមានខ្លាញ់តិច និងសៃលុយឡូសច្រើន។

□C. បរិភោគអាហារតែមួយមុខដដែលៗឱ្យបានច្រើន។

□D. បរិភោគឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាននៅពេលឃ្លាន។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ប្រភេទរបបអាហារដែលសមស្របសម្រាប់សុខភាពរំលាយអាហារ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ២៖ ឥទ្ធិពលនៃភេសជ្ជៈក្នុងពេលបាយ

ហេតុអ្វីបានជាគេមិនគួរពិសាភេសជ្ជៈ ឬទឹកច្រើនពេកក្នុងពេលកំពុងបរិភោគបាយ?

□A. ព្រោះវាធ្វើឱ្យរសេរំលាយអាហាររាវ និងកាត់បន្ថយសកម្មភាពរបស់វា។

□B. ព្រោះវាធ្វើឱ្យអាហារប្រែជាស្រួយពេកពិបាកទំពា។

□C. ព្រោះវាធ្វើឱ្យបាក់តេរីនៅក្នុងមាត់កើនឡើងយ៉ាងឆាប់រហ័ស។

□D. ព្រោះវាធ្វើឱ្យសាច់ដុំក្រពះកន្ត្រាក់ខ្លាំងពេក។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីឥទ្ធិពលនៃជាតិរាវចំពោះកំហាប់នៃរសេរំលាយអាហារ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស (ជ្រើសរើសច្រើន) |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវាយតម្លៃលើទម្លាប់រស់នៅ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ការទល់លាមកអាចបណ្តាលឱ្យមានការពុលទូទៅដល់រាងកាយ។ | ☐ | ☐ |
| ២. សុរា និងថ្នាំជក់ ជួយបង្កើនសកម្មភាពរបស់រសេទឹកមាត់ និងរសេក្រពះឱ្យល្អជាងមុន។ | ☐ | ☐ |
| ៣. យើងគួរសម្រាកបន្តិចក្រោយពេលបរិភោគបាយរួច ដើម្បីជួយដល់ការរំលាយអាហារ។ | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើផលប៉ះពាល់នៃសារធាតុញៀន និងទម្លាប់បញ្ចេញចោលចំពោះសុខភាព។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ការបកស្រាយចិត្តសាស្ត្រនៃការបរិភោគ

មេរៀនបានណែនាំថា យើងគួរ "បរិភោគតាមសម្រួលកុំប្រញាប់ និងប្រកបដោយអារម្មណ៍ល្អ"។ តើការបរិភោគដោយមានអារម្មណ៍ល្អ និងមិនប្រញាប់ប្រញាល់ផ្តល់ផលប្រយោជន៍អ្វីដល់ការរំលាយអាហារបែបមេកានិច?

☐A. ជួយឱ្យការទំពាអាហារបានម៉ដ្ឋល្អ និងសម្រាលការងារក្រពះ។

☐B. ជួយឱ្យធ្មេញដុះបានត្រង់ល្អ។

☐C. ជួយឱ្យរាងកាយស្រូបយកវីតាមីនបានដោយមិនបាច់ប្រើអង់ស៊ីម។

☐D. ជួយឱ្យបំពង់អាហាររួមតូចជាងមុន។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគទំនាក់ទំនងរវាងអាកប្បកិរិយាបរិភោគ និងប្រសិទ្ធភាពរំលាយអាហារ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការដោះស្រាយបញ្ហា

សុខ តែងតែបរិភោគអាហារដែលមានជាតិខ្លាញ់ខ្ពស់ មិនចូលចិត្តបរិភោគបន្លែ (សៃលុយឡូស) និងចូលចិត្តញ៉ាំបណ្តើរលេងបណ្តើរ។ មួយរយៈក្រោយមក គេតែងតែមានអាការៈទល់លាមក និងឈឺពោះជារឿយៗ។




1. ផ្អែកលើមេរៀន តើទម្លាប់របស់សុខមានចំណុចខុសឆ្គងអ្វីខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

2. ចូរផ្តល់អនុសាសន៍ចំនួន ៣ ដល់សុខ ដើម្បីកែលម្អសុខភាពប្រដាប់រំលាយអាហាររបស់គេឱ្យប្រសើរឡើងវិញ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បង្កើតដំណោះស្រាយចំពោះបញ្ហាសុខភាពរំលាយអាហារតាមរយៈការកែប្រែទម្លាប់។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **B. អាហារដែលមានខ្លាញ់តិច និងសៃលុយឡូសច្រើន**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **A. ព្រោះវាធ្វើឱ្យរសរំលាយអាហាររាំ និងកាត់បន្ថយសកម្មភាពរបស់វា**

**សំណួរទី ៣៖**

- ១. **ពិត** (ការទល់លាមកបង្កការពុលដល់រាងកាយ)
- ២. **មិនពិត** (សុរា និងថ្នាំជក់ បង្អាក់សកម្មភាពរសរំលាយអាហារ)
- ៣. **ពិត** (ការសម្រាកជួយឱ្យរាងកាយផ្តោតលើការរំលាយអាហារ)
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៤៖**

ចម្លើយត្រូវ៖ **B. ជួយឱ្យការទំពាអាហារបានម៉ដ្ឋល្អ និងសម្រាលការងារក្រពះ**

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ចំណុចខុសឆ្គង៖** បរិភោគខ្លាញ់ច្រើន (ពិបាករំលាយ), ខ្វះសៃលុយឡូស (បណ្តាលឱ្យទល់លាមក), និងបរិភោគទាំងប្រញាប់/គ្មានការសម្រាក (ធ្វើឱ្យប្រព័ន្ធរំលាយអាហារហត់ខ្លាំង)។
  2. **អនុសាសន៍ ៣ យ៉ាង៖** ១. បន្ថយអាហារខ្លាញ់ និងបន្ថែមបន្លែផ្លែឈើ (សៃលុយឡូស)។ ២. បរិភោគឱ្យទៀងទាត់ និងតាមសម្រួល (ទំពាឱ្យម៉ដ្ឋ)។ ៣. បន្ទោបង់ឱ្យបានទៀងពេលជារៀងរាល់ថ្ងៃ។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែចំណុចខុសឆ្គង ឬផ្តល់អនុសាសន៍មិនបានគ្រប់ចំនួនដែលទាមទារ។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ២៧ : ជំងឺ និងតុល្យភាពជាតិទឹកក្នុងប្រព័ន្ធរំលាយអាហារ

## អត្ថបទខ្លី៖ មេរៀនដែល "តារា" រៀនបានពីការឈឺពោះ



បន្ទាប់ពីលេងបាល់ទាត់យ៉ាងសប្បាយរីករាយជាមួយមិត្តភក្តិ តារាមានអារម្មណ៍ឃ្លានខ្លាំង ហើយក៏ប្រញាប់ទិញអាហារសម្រន់នៅក្បែរតារាងបាល់មកញ៉ាំដោយមិនបានលាងដៃឱ្យបានត្រឹមត្រូវឡើយ។ យប់នោះ តារាចាប់ផ្តើមមានអាការៈឈឺពោះ រមួល និងរាកជាច្រើនដង ដែលធ្វើឱ្យគាត់អស់កម្លាំងល្ហិតល្ហៃ និងស្រេកទឹកខ្លាំង។

ម្តាយរបស់តារាបានពន្យល់ថា៖ "នៅពេលកូនញ៉ាំអាហារដោយមិនលាងដៃ មេរោគតូចៗដូចជាបាក់តេរី ឬអាមីប បានលួចចូលទៅក្នុងពោះវៀនរបស់កូន។ ពួកវាបង្កការរំខានដល់ការបឺតស្រូបជាតិទឹករបស់ពោះវៀនធំ ធ្វើឱ្យជាតិទឹកត្រូវបញ្ចេញមកក្រៅទាំងអស់តាមរយៈការរាក"។ តារាបានរៀនសូត្រថា ការរក្សាអនាម័យ និងការញ៉ាំទឹកឆ្អិន មិនមែនគ្រាន់តែជាការស្តាប់តាមម៉ែឪនោះទេ ប៉ុន្តែវាគឺជាការការពាររាងកាយពី "សត្រូវអាថ៌កំបាំង" ដែលមើលមិនឃើញ។

## សំណួរទី ១៖ គ្រោះថ្នាក់នៃជំងឺរាក

យោងតាមអត្ថបទមេរៀន តើគ្រោះថ្នាក់ចម្បងបំផុតដែលអ្នកជំងឺរាកអាចប្រឈមមុខគឺអ្វី?

☐A. ការឡើងទម្ងន់ខុសប្រក្រតី។

☐B. ការប្រែពណ៌ស្បែកទៅជាពណ៌លឿងភ្លាមៗ។

☐C. ការកើនឡើងនៃជាតិសៃលុយឡូសក្នុងឈាម។

☐D. ការបាត់បង់ទឹកយ៉ាងច្រើនពីសារពាង្គកាយ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីផលវិបាកនៃជំងឺរាកចំពោះគុណភាពជាតិទឹក។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការប្រៀបធៀបជំងឺរលាកថ្លើម

ជំងឺរលាកថ្លើមមានច្រើនប្រភេទ (A, B, C)។ ចូរផ្គូផ្គងប្រភេទជំងឺនៅជួរ (A) ទៅនឹងរបៀបនៃការឆ្លងរបស់វា នៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| ប្រភេទជំងឺ ( A) | របៀបឆ្លង ( B) | ចម្លើយ |
|---|---|---|
| ១. រលាកថ្លើមប្រភេទ A | ក. ឆ្លងតាមរយៈឈាម ការប្រើម្ជុលមិនស្អាត ឬការរួមភេទ។ | ១ ⇨ …… |
| ២. រលាកថ្លើមប្រភេទ B និង C | ខ. ឆ្លងតាមរយៈអាហារមិនស្អាត ការប៉ះពាល់ផ្ទាល់ ឬទឹកមានមេរោគ។ | ២ ⇨ …… |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកប្រភពនៃការចម្លងមេរោគរលាកថ្លើមប្រភេទផ្សេងៗគ្នា។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ មូលហេតុនៃអាការៈតឹងពោះរបស់ "វីរៈ"

មួយសប្តាហ៍នេះ វីរៈមានអារម្មណ៍ថាតឹងពោះ និងពិបាកក្នុងការបត់ជើងធំខ្លាំងណាស់។ រាល់ពេលដែលគាត់ព្យាយាមបញ្ចេញកាកសំណល់គាត់មានអារម្មណ៍ឈឺចាប់ ព្រោះលាមករបស់គាត់ប្រែជារឹងខ្លាំង។

នៅពេលទៅពិគ្រោះជាមួយលោកគ្រូពេទ្យ វីរៈបានសារភាពថា គាត់មិនចូលចិត្តញ៉ាំបន្លែ និងផ្លែឈើឡើយ ហើយគាត់ចូលចិត្តញ៉ាំតែអាហារបំពង និងនំកញ្ចប់។ ម្យ៉ាងទៀត គាត់តែងតែរវល់លេងហ្គេម

រហូតដល់ភ្លេចញ៉ាំទឹក និងចូលចិត្ត "ទប់" មិនព្រមទៅបន្ទប់ទឹកភ្លាមៗនៅពេលឈឺបត់ជើងធំ។ លោកគ្រូពេទ្យបានពន្យល់ថា៖ "នៅពេលកូនខ្វះជាតិសរសៃ និងទឹក ពោះវៀនធំរបស់កូននឹងបឺតស្រូបយកជាតិទឹកពីកាកសំណល់អស់ ធ្វើឱ្យវារឹង និងធ្វើដំណើរយឺតយ៉ាវ ដែលនេះហើយគឺជា **ជំងឺទល់លាមក**"។




តើកត្តាណាខ្លះដែលបណ្តាលឱ្យកើតមាន «**ជំងឺទល់លាមក**»? (ជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុត)

□A. បរិភោគអាហារមានសៃលុយឡូសច្រើន និងធ្វើលំហាត់ប្រាណទៀងទាត់។

□B. ការឆ្លងវីរុសតាមរយៈការបញ្ចូលឈាម។

□C. កង្វះជាតិសៃលុយឡូស ផឹកទឹកតិចពេក និងកង្វះលំហាត់ប្រាណ។

□D. បរិភោគអាហារច្រើនហួសកម្រិត និងផឹកទឹកច្រើនពេក។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់មូលហេតុដែលនាំឱ្យមានបញ្ហាចលនាពោះវៀន (ទល់លាមក)។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើរោគសញ្ញា និងការបង្ការ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ស្បែក និងប្រស្រីភ្នែកឡើងពណ៌លឿង ជារោគសញ្ញាមួយនៃជំងឺរលាកថ្លើមប្រភេទ A។ | ☐ | ☐ |
| ២. ការប្រើថ្នាំបញ្ចុះជានិច្ចកាល គឺជាវិធីដ៏ល្អបំផុតដើម្បីព្យាបាលជំងឺទល់លាមកក្នុងរយៈពេលវែង។ | ☐ | ☐ |
| ៣. ដើម្បីបង្ការជំងឺរាក អ្នកជំងឺត្រូវផឹកទឹកឱ្យបានច្រើនដើម្បីជំនួសទឹកដែលបាត់បង់។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃរោគសញ្ញា និងវិធីសាស្ត្រថែទាំអ្នកជំងឺ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការផ្តល់អនុសាសន៍ (កម្រិតខ្ពស់)

គ្រួសារមួយមានទម្លាប់បរិភោគអាហារដែលទិញពីចិញ្ចើមថ្នល់ ដែលគ្មានគម្របបិទបាំងត្រឹមត្រូវ និងប្រើប្រាស់ទឹកត្រីរួមគ្នាជាមួយអ្នកជិតខាងដែលកំពុងមានជំងឺរលាកថ្លើមប្រភេទ A។ មួយខែក្រោយមក សមាជិកក្នុងគ្រួសារនោះចាប់ផ្តើមឈឺក្បាល គ្រុនក្តៅ និងបាត់បង់រសជាតិអាហារ។



1. ផ្អែកលើមេរៀន តើពួកគាត់អាចប្រឈមនឹងជំងឺអ្វី?

.....................................................................................................................................

.....................................................................................................................................

2. ចូរពន្យល់ពីទំនាក់ទំនងរវាង «ទម្លាប់បរិភោគ» និង «ការចម្លងមេរោគ» ក្នុងករណីនេះ ព្រមទាំងផ្តល់អនុសាសន៍ ២ យ៉ាងដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺនេះក្នុងគ្រួសារ។

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគខ្សែបណ្តាញនៃការចម្លងរោគ និងបង្កើតវិធានការបង្ការប្រកបដោយប្រសិទ្ធភាព។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **D. ការបាត់បង់ទឹកយ៉ាងច្រើនពីសារពាង្គកាយ**

**សំណួរទី ២៖**

ចម្លើយត្រូវ៖

- ១ ⇨ ខ. ឆ្លងតាមរយៈអាហារមិនស្អាត ការប៉ះពាល់ផ្ទាល់ ឬទឹកមានមេរោគ។
- ២ ⇨ ក. ឆ្លងតាមរយៈឈាម ការប្រើម្ជុលមិនស្អាត ឬការរួមភេទ។

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **C. កង្វះជាតិសៃលុយឡូស ផឹកទឹកតិចពេក និងកង្វះលំហាត់ប្រាណ**

**សំណួរទី ៤៖**

- ១. **ពិត** (រោគសញ្ញាឡើងលឿង ឬស្វាយ ត្រឹមត្រូវសម្រាប់រលាកថ្លើម)
- ២. **មិនពិត** (មេរៀនបញ្ជាក់ថាត្រូវចៀសវាងការប្រើថ្នាំបញ្ចុះជានិច្ចកាល)
- ៣. **ពិត** (ការផឹកទឹកច្រើនជួយទប់ស្កាត់ការបាត់បង់ទឹកពេលរាក)
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ការវិភាគ៖** ពួកគាត់ប្រឈមនឹង «ជំងឺរលាកថ្លើមប្រភេទ A»។ មេរោគឆ្លងតាមរយៈអាហារមិនស្អាត និងការប៉ះពាល់ផ្ទាល់ ឬប្រើប្រាស់សម្ភារៈរួមគ្នាជាមួយអ្នកជំងឺ។
    2. **អនុសាសន៍៖** ១. បញ្ឈប់ការបរិភោគអាហារមិនស្អាត និងលាងសម្អាតអាហារ/ដៃឱ្យបានល្អមុនបរិភោគ។ ២. ចៀសវាងការប្រើប្រាស់សម្ភារៈហូបចុក ( ទឹកត្រី ស្លាបព្រា ចាន ) រួមគ្នាជាមួយអ្នកជំងឺ និងសម្រាកឱ្យបានគ្រប់គ្រាន់។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវឈ្មោះជំងឺ តែផ្តល់អនុសាសន៍មិនបានសមស្របតាមខ្លឹមសារមេរៀន។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ២៨ : តុល្យភាពអាហារូបត្ថម្ភ និងសុខភាពរាងកាយ

## អត្ថបទខ្លី៖ អាហារូបត្ថម្ភសម្រាប់ថ្ងៃបោះជំរំ



នៅថ្ងៃឈប់សម្រាក ក្រុមរបស់ ពិសិដ្ឋ ដារ៉ា និងបូរ៉ា បាននាំគ្នាទៅបោះជំរំនៅក្នុងព្រៃ។ ដើម្បីត្រៀមខ្លួន ពួកគេត្រូវរៀបចំខ្ចប់អាហារឱ្យបានត្រឹមត្រូវ។ ពិសិដ្ឋដែលជាអ្នករត់ប្រណាំងបាននិយាយថា៖ "យើងត្រូវការ បាយ និងនំប៉័ង ច្រើនព្រោះវាផ្តល់ថាមពលឱ្យយើងដើរភ្នំ"។ សុភីបានបន្ថែមថា៖ "កុំភ្លេច ត្រី ខ ខ្លាញ់ និងសាច់ ផង ដើម្បីជួយជួសជុលសាច់ដុំ និងផ្តល់កម្តៅ"។ ចំណែកបូរ៉ាដែលកាន់សៀវភៅសុខភាពបានរំលឹកថា៖ "យើងក៏ត្រូវមាន បន្លែ ផ្លែឈើ និងទឹកស្អាត ដែរ ទោះបីវាជាក្រុមមិនផ្តល់ថាមពលផ្ទាល់ ប៉ុន្តែវាជួយឱ្យថ្លើម និងតម្រងនោមយើងចម្រោះជាតិពុលបានល្អ និងការពារជំងឺ"។ ពួកគេបានយល់ថា ប្រសិនបើញ៉ាំតែសាច់ដោយគ្មានបន្លែ ឬញ៉ាំតែម្សៅដោយគ្មានទឹក រាងកាយពួកគេនឹងដូចជាម៉ាស៊ីនដែលខ្វះគ្រឿងបន្លាស់ និងឆាប់ខូចមិនខាន។

---

### សំណួរទី ១៖ ការបែងចែកប្រភេទអាហារ

ផ្អែកលើអត្ថបទមេរៀន តើក្រុមអាហារមួយណាខាងក្រោមនេះ ដែលចាត់ទុកជា «**អាហារមិនផ្តល់ថាមពល**» ប៉ុន្តែចាំបាច់បំផុតសម្រាប់សុខភាព?

□A. ក្តួយស៊ីត និងប្រូទីត　　□B. ខ្លាញ់ និងក្តួយស៊ីត

□C. ទឹក អំបិលខនិជ និងវីតាមីន　　□D. ប្រូទីត និងខ្លាញ់

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែករវាងអាហារផ្តល់ថាមពល និងអាហារមិនផ្តល់ថាមពល។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ២៖ វិបត្តិលើសអាហារ

ប្រសិនបើយើងបរិភោគអាហារដែលមាន «**ប្រូទីត (ប្រូតេអ៊ីន)**» ច្រើនហួសហេតុ តើសរីរាង្គពីរណាខ្លះដែលនឹងរងការនឿយហត់ខ្លាំង?

☐A. បេះដូង និងសួត ☐B. ថ្លើម និងតម្រងនោម

☐C. ក្រពះ និងពោះវៀនធំ ☐D. ខួរក្បាល និងសរសៃប្រសាទ

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីផលប៉ះពាល់នៃការលើសជាតិប្រូតេអ៊ីនចំពោះសរីរាង្គចម្រោះ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការគណនាតម្រូវការប្រូទីត

យុវជនម្នាក់មានទម្ងន់ខ្លួន 50kg។ យោងតាមមេរៀនដែលថា យុវជនម្នាក់ត្រូវការប្រូទីតពី 1.5g ទៅ 2g ក្នុងទម្ងន់ខ្លួន1kg សម្រាប់មួយថ្ងៃ។

តើយុវជនរូបនេះត្រូវបរិភោគប្រូទីតយ៉ាងតិចបំផុតចំនួនប៉ុន្មានក្រាមក្នុងមួយថ្ងៃ?

☐A. 1.5g ☐B. 50g

☐C. 75g ☐D. 100g

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | អនុវត្តការគណនាតម្រូវការសារជាតុចិញ្ចឹមតាមទម្ងន់ខ្លួន។ |
| កម្រិតពុទ្ធិ | អនុវត្តន៍ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ការវាយតម្លៃលើផលវិបាកនៃរបបអាហារ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. កង្វះប្រូតេអ៊ីននឹងបង្អាក់ការលូតលាស់ និងមិនអាចជួសជុលកន្លែងខូចខាតបាន។ | ☐ | ☐ |
| ២. ការបរិភោគអាហារផ្តល់ថាមពលច្រើនហួសប្រមាណ មិនផ្តល់ផលវិបត្តិអ្វីដល់រាងកាយឡើយ។ | ☐ | ☐ |
| ៣. កាលណាអ៊ុយរ៉េកើនឡើងក្នុងឈាមខ្លាំង អាស៊ីតអ៊ុយរិចនឹងមានវត្តមានក្នុងសន្លាក់។ | ☐ | ☐ |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃផលប៉ះពាល់ពីវិបត្តិចំណីអាហារ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការព្យាករណ៍

កុមារម្នាក់រស់នៅក្នុងតំបន់ដែលមានសង្គ្រាម និងខ្វះខាតស្បៀងអាហារ។ របបអាហារប្រចាំថ្ងៃរបស់គេមានតែបាយ និងដំឡូង (គ្លុយស៊ីត) ប៉ុណ្ណោះ ដោយគ្មានសាច់ ត្រី ឬសណ្តែក (ប្រូទីត) ឡើយ។



1. តើកុមាររូបនេះនឹងជួបប្រទះវិបត្តិចំណីអាហារប្រភេទអ្វី?

.......................................................................................................................

.......................................................................................................................

2. ចូរពន្យល់ពីផលប៉ះពាល់ដែលនឹងកើតឡើងចំពោះ «រូបរាងកាយ» និង «សមត្ថភាពជួសជុលរបួស» របស់គេ។

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគផលប៉ះពាល់នៃកង្វះប្រូតេអ៊ីនចំពោះការលូតលាស់ និងការជួសជុលជាលិកា។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាគំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. ទឹក អំបិលខនិជ និងវីតាមីន**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **B. ថ្លើម និងតម្រងនោម**

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **C. 75 g** (គណនា៖ 50kg x 1.5g/kg} = 75g)។

**សំណួរទី ៤៖**

- ១. **ពិត** (នាទីប្រូតេអ៊ីនក្នុងការលូតលាស់ និងជួសជុល)
- ២. **មិនពិត** (ការបរិភោគច្រើនហួសនាំឱ្យមានវិបត្តិលើសអាហារ)
- ៣. **ពិត** (ឥទ្ធិពលនៃអ៊ុយរ៉េលើសន្លាក់)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **វិបត្តិ៖** ជួបប្រទះ «វិបត្តិកង្វះអាហារ» ជាពិសេសគឺកង្វះប្រូតេអ៊ីន (ប្រូទីត)។
    2. **ផលប៉ះពាល់៖** រូបរាងកាយនឹងមានការបង្អាក់ការលូតលាស់ (មាឌតូច ឬមិនធំធាត់តាមវ័យ) ហើយប្រសិនបើមានរបួស រាងកាយនឹងមិនអាចជួសជុលកន្លែងខូចខាតបានឡើយ ព្រោះខ្វះប្រូតេអ៊ីនដែលជាគ្រឿងបង្គុំសម្រាប់បង្កើតកោសិកាថ្មី។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាខ្វះអាហារ តែមិនបានបញ្ជាក់ពីផលវិបាកនៃការជួសជុលជាលិកាខូចខាត។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ជំពូកទី៥ អាល់កុល និងថ្នាំជក់

## មេរៀនទី១ ថ្នាំ

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ២៩ : ថ្នាំ និងឥទ្ធិពលនៃគ្រឿងញៀនលើរាងកាយ

**អត្ថបទខ្លី៖ ការពិភាក្សារបស់ក្រុមយុវជនអំពី «សារធាតុគីមី និងរាងកាយ»**




នៅក្នុងម៉ោងសម្រាក ម៉ារី ភារុណ និងកញ្ញា កំពុងជួយគ្នារៀបចំផ្ទាំងរូបភាពសម្រាប់ «ទិវាសុខភាពសាលា»។ ម៉ារីបានលើកឡើងថា៖ «**យើងត្រូវប្រាប់មិត្តភក្តិឱ្យច្បាស់ថា មិនមែនឱ្យតែអ្វីដែលយើងលេបចូលសុទ្ធតែជាអាហារនោះទេ។ ថ្នាំ គឺជាសារធាតុគីមីដែលផ្លាស់ប្តូររបៀបដែលខួរក្បាល និងបេះដូងយើងធ្វើការ**»។

ភារុណបានបន្ថែមដោយចង្អុលទៅរូបភាពឱសថថា៖ «**ត្រូវហើយ! ដូចជាថ្នាំពេទ្យដែរ បើប្រើតាមបញ្ជាគ្រូពេទ្យ វាជួយព្យាបាលជំងឺ តែបើប្រើខុសវាអាចជាគ្រោះថ្នាក់**»។ កញ្ញាដែលកំពុងបិទរូបភាពសញ្ញាខ្វែងលើបារី និងគ្រឿងស្រវឹង បាននិយាយទាំងបារម្ភថា៖ «**អ្វីដែលគួរឱ្យខ្លាចគឺ គ្រឿងញៀន និងសារធាតុញៀនផ្សេងៗ។ វាធ្វើឱ្យមនុស្សបាត់បង់ការចងចាំ ធ្វើឱ្យបេះដូងលោតខុសធម្មតា ហើយអាចបំផ្លាញអនាគតយើងទាំងស្រុង។ យើងត្រូវរៀននិយាយថា ទេ ចំពោះរបស់ទាំងនេះ!**»។ ពួកគេទាំងបីនាក់បានសន្និដ្ឋានថា ការស្វែងយល់ពីភាពខុសគ្នារវាង 'ថ្នាំព្យាបាល' និង 'គ្រឿងញៀន' គឺជាខែលការពារខ្លួនដ៏ល្អបំផុត។

## សំណួរទី ១៖ ឥទ្ធិពលនៃជាតិកាផេអ៊ីន

តើសារធាតុ «**កាផេអ៊ីន**» ដែលមាននៅក្នុងតែ ឬកាហ្វេ មានឥទ្ធិពលទៅលើផ្នែកណាខ្លះនៃរាងកាយ?

□A. ថ្លើម និងតម្រងនោម　　□B. បេះដូង និងខួរក្បាល

□C. ក្រពះ និងពោះវៀន　　□D. ឆ្អឹង និងសាច់ដុំ

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ឥទ្ធិពលនៃ កាផេអ៊ីន លើសរីរាង្គគោលដៅ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការបែងចែកប្រភេទថ្នាំ




យោងតាមមេរៀន តើក្រុមសារធាតុមួយណាខាងក្រោមនេះ ដែលត្រូវបានចាត់ទុកថាជា «**ថ្នាំស្របច្បាប់**»?

តើសារធាតុ «**កាផេអ៊ីន**» ដែលមាននៅក្នុងតែ ឬកាហ្វេ មានឥទ្ធិពលទៅលើផ្នែកណាខ្លះនៃរាងកាយ?

□A. កញ្ឆា និងអាភៀន　　□B. អាភៀន និងស្រាថ្នាំ

□C. ឱសថ ស្រា និងបារី　　□D. កញ្ឆា និងឱសថព្យាបាល

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកភាពខុសគ្នារវាងថ្នាំស្របច្បាប់ និងថ្នាំមិនស្របច្បាប់។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគលក្ខណៈនៃគ្រឿងញៀន

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. អាល់កុលជាថ្នាំដែលធ្វើឱ្យមនុស្សញៀន និងមាននៅក្នុងស្រាបៀរ ឬស្រាថ្នាំ។ | ☐ | ☐ |
| ២. ថ្នាំជក់ដែលកែច្នៃជាបារី មិនសូវផ្តល់គ្រោះថ្នាក់ដល់សុខភាពដូចថ្នាំជក់សម្រាប់ចុកទេ។ | ☐ | ☐ |
| ៣. គ្រឿងញៀនមានឥទ្ធិពលទៅលើប្រព័ន្ធប្រសាទរបស់មនុស្ស។ | ☐ | ☐ |

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃលើលក្ខណៈរួម និងគ្រោះថ្នាក់នៃផលិតផលកែច្នៃពីថ្នាំជក់ និងអាល់កុល |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៤៖ ផលប៉ះពាល់នៃគ្រឿងញៀនលើសមត្ថភាពការងារ



ហេតុអ្វីបានជាមនុស្សដែលប្រើប្រាស់គ្រឿងញៀន (ដូចជា កញ្ឆា អាភៀន ស្រា បារី) មិនអាចបំពេញការងារបានត្រឹមត្រូវ?

☐A. ព្រោះពួកគេនឹងក្លាយជាមនុស្សញៀន ដែលមិនអាចធ្វើការបានល្អនៅពេលមិនបានប្រើថ្នាំទៀងទាត់។

☐B. ព្រោះគ្រឿងញៀនធ្វើឱ្យពួកគេមានកម្លាំងខ្លាំងហួសពីមនុស្សធម្មតា។

☐C. ព្រោះគ្រឿងញៀនជួយឱ្យពួកគេសម្រាកបានច្រើនជាងមុន។

☐D. ព្រោះគ្រឿងញៀនធ្វើឱ្យស្បែក និងភ្នែកប្រែជាពណ៌លឿង។

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| | |
|---|---|
| **លក្ខណៈ** | ការពិពណ៌នា |
| **លទ្ធផលសិក្សា** | បែងចែកភាពខុសគ្នារវាងថ្នាំស្របច្បាប់ និងថ្នាំមិនស្របច្បាប់។ |
| **កម្រិតពុទ្ធិ** | យល់ដឹង |
| **ទម្រង់សំណួរ** | ពហុជ្រើសរើស |
| **កម្រិតសមត្ថភាព** | កម្រិត ២ |

---

**សំណួរទី ៥៖ ការវិភាគស្ថានភាព និងការសន្និដ្ឋាន**

យុវជនម្នាក់គិតថា ការជក់បារី ឬការផឹកស្រា គឺជាទម្លាប់ធម្មតាដែលមិនបង្កគ្រោះថ្នាក់ដល់សង្គមឡើយ ព្រោះវាជា «ថ្នាំស្របច្បាប់»។ ប៉ុន្តែ មួយរយៈក្រោយមក គេចាប់ផ្តើមញៀនខ្លាំង និងមិនអាចផ្តោតអារម្មណ៍រៀនសូត្របានឡើយ ប្រសិនបើមិនបានប្រើប្រាស់វា។




1. តើការយល់ឃើញរបស់យុវជននេះត្រឹមត្រូវដែរឬទេ?

..........................................................................................................................

..........................................................................................................................

2. ចូរពន្យល់ពីទំនាក់ទំនងរវាង «ថ្នាំស្របច្បាប់» និង «គ្រឿងញៀន» ក្នុងករណីនេះ ព្រមទាំងលើកឡើងពីផលវិបាកដែលនឹងកើតមានចំពោះការសិក្សារបស់គេ។

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃពីគ្រោះថ្នាក់នៃថ្នាំស្របច្បាប់ដែលបង្កឱ្យមានភាពញៀន និងផលប៉ះពាល់ដល់ការសិក្សា។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **B. បេះដូង និងខួរក្បាល**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **C. ឱសថ ស្រា និងបារី**

**សំណួរទី ៣៖**

- ១. **ពិត** (អាល់កុលក្នុងស្រាបៀរធ្វើឱ្យញៀន )
- ២. **មិនពិត** (មេរៀនបញ្ជាក់ថា ទោះផលិតផលបែបណាក៏ផ្តល់គ្រោះថ្នាក់ដូចគ្នា )
- ៣. **ពិត** (គ្រឿងញៀនមានឥទ្ធិពលលើប្រព័ន្ធប្រសាទ )
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៤៖**

ចម្លើយត្រូវ៖ **A. ព្រោះពួកគេនឹងក្លាយជាមនុស្សញៀន ដែលមិនអាចធ្វើការបានល្អនៅពេលមិនបានប្រើថ្នាំទៀងទាត់**

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ការវាយតម្លៃ៖** ការយល់ឃើញនេះមិនត្រឹមត្រូវទេ។ ទោះបីជាស្រា និងបារីជា «ថ្នាំស្របច្បាប់» ក៏ពិតមែន ប៉ុន្តែវាគឺជា «គ្រឿងញៀន» ដែលធ្វើឱ្យមនុស្សញៀន និងផ្តល់គ្រោះថ្នាក់ដល់សុខភាពដូចគ្នា។
  2. **ផលវិបាក៖** នៅពេលញៀន ប្រព័ន្ធប្រសាទនឹងរងផលប៉ះពាល់ ធ្វើឱ្យគេបាត់បង់ការផ្តោតអារម្មណ៍ មិនអាចបំពេញការងារ ឬសិក្សាបានត្រឹមត្រូវឡើយ ប្រសិនបើមិនបានប្រើប្រាស់វាឱ្យបានទៀងទាត់ ដែលនាំឱ្យខូចអនាគត។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាស្រា និងបារីជាគ្រឿងញៀន តែមិនបានបញ្ជាក់ពីផលប៉ះពាល់ដល់ប្រព័ន្ធប្រសាទ ឬការសិក្សាឱ្យបានច្បាស់លាស់។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ៣០ : ឱសថ និងខែលការពារសុខភាព

## អត្ថបទខ្លី៖ ការស្វែងយល់ពី «អាវុធសម្ងាត់» ក្នុងកញ្ចប់ថ្នាំ



ថ្ងៃនេះ សុភ័ក្រ បានទៅសួរសុខទុក្ខលោកយាយដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យ។ នៅក្បែរគ្រែលោកយាយ គាត់ឃើញមានថ្នាំជាច្រើនប្រភេទ។ ដោយមានចម្ងល់ សុភ័ក្របានសួរលោកគ្រូពេទ្យថា៖ «ហេតុអ្វីបានជាលោកយាយត្រូវញ៉ាំថ្នាំច្រើនម្ល៉េះ?»។

លោកគ្រូពេទ្យបានញញឹម ហើយពន្យល់ថា៖ ថ្នាំនីមួយៗមាន "តួនាទីពិសេស" ខុសគ្នា៖

- **ថ្នាំបំបាត់ឈឺចាប់៖** ជួយឱ្យស្រួលខ្លួនមួយគ្រា (ដូចជាបាត់ឈឺក្បាល)។
- **ថ្នាំផ្សះ (អង់ទីប្យូទិច)៖** ជា "អ្នកចម្បាំង" ចូលទៅសម្លាប់មេរោគបាក់តេរីដោយផ្ទាល់។
- **វ៉ាក់សាំង៖** ជា "គ្រូបង្វឹក" បង្រៀនកងទ័ពការពារខ្លួនឱ្យស្គាល់សត្រូវទុកជាមុន។

---

## សំណួរទី ១៖ ការសម្គាល់ប្រភេទអង់ទីប្យូទិច

តើឱសថមួយណាខាងក្រោមនេះ ដែលជាប្រភេទ «**អង់ទីប្យូទិច**» ប្រើសម្រាប់សម្លាប់ ឬបញ្ឈប់ការលូតលាស់របស់បាក់តេរី?

☐A. វ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ☐B. ប៉េនីស៊ីលីន និងតេត្រាស៊ីគ្លីន

☐C. ស៊ីរ៉ូបំបាត់ការក្អក ☐D. ថ្នាំបញ្ចុះកម្តៅ

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់អត្តសញ្ញាណឱសថប្រភេទអង់ទីប្យូទិច។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ យន្តការនៃវ៉ាក់សាំង

វ៉ាក់សាំងគឺជាសូលុយស្យុងដែលផ្ទុកមេរោគងាប់ ឬខ្សោយ។ តើការចាក់វ៉ាក់សាំងផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់រាងកាយមនុស្ស?

☐A. ផ្ដល់ភាពស៊ាំសកម្មដើម្បីទប់ទល់នឹងមេរោគដែលចូលមកឈ្លានពាននៅថ្ងៃក្រោយ។

☐B. សម្លាប់បាក់តេរីដែលកំពុងបង្កជំងឺរលាកសួតភ្លាមៗ។

☐C. បំបាត់ការឈឺក្បាល និងបញ្ឈប់ការហៀរសំបោរក្នុងពេលកំពុងគ្រុន។

☐D. ជួយឱ្យរាងកាយទទួលបានថាមពលបន្ថែមដូចអាហារ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីនាទីរបស់វ៉ាក់សាំងក្នុងការបង្កើតភាពស៊ាំ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការបែងចែកក្រុមឱសថ

ចូរផ្គូផ្គងក្រុមឱសថនៅជួរ (A) ទៅនឹងមុខងារចម្បងរបស់វា នៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| ប្រភេទជំងឺ (A) | របៀបឆ្លង (B) | ចម្លើយ |
|---|---|---|
| ១. ឱសថបន្ធូរបន្ថយការឈឺចាប់ | ក. ផ្ដល់ភាពស៊ាំសកម្មដើម្បីការពារជំងឺនាពេលអនាគត។ | ១ ⇨ ...... |
| ២. ឱសថប្រឆាំងនឹងមេរោគ | ខ. បន្ថយការឈឺក្បាល ក្អក និងហៀរសំបោរ។ | ២ ⇨ ...... |
| ៣. ឱសថបង្ការជំងឺ (វ៉ាក់សាំង) | គ. សម្លាប់ឬបញ្ឈប់ការលូតលាស់របស់បាក់តេរីបង្កជំងឺ។ | ៣ ⇨ ...... |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែកនាទីខុសគ្នារវាងការបំបាត់ការឈឺចាប់ ការព្យាបាល និងការបង្ការ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើប្រភពអង់ទីប៊ីយោទិច

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. អង់ទីប៊ីយោទិចអាចផលិតចេញពីបាក់តេរី ផ្សិត និងរុក្ខជាតិមួយចំនួន។ | ☐ | ☐ |
| ២. យើងប្រើវ៉ាក់សាំងដើម្បីព្យាបាលជំងឺរលាកសួតដែលកំពុងឈឺខ្លាំងឱ្យជាសះស្បើយភ្លាមៗ។ | ☐ | ☐ |
| ៣. ឱសថបន្ធូរបន្ថយការឈឺចាប់អាចមានទម្រង់ជាថ្នាំទឹក ថ្នាំគ្រាប់ ឬថ្នាំចាក់។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃប្រភព សណ្ឋាន និងការប្រើប្រាស់ឱសថ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការសម្រេចចិត្ត (កម្រិតខ្ពស់)

សុខ កំពុងឈឺបំពង់កយ៉ាងខ្លាំងដោយសារការឆ្លងបាក់តេរី។ គេបានទៅមន្ទីរពេទ្យ ហើយគ្រូពេទ្យបានផ្តល់ឱសថពីរមុខគឺ៖ **១. ថ្នាំគ្រាប់បំបាត់ការឈឺចាប់** និង **២. អង់ទីប្យូទិច (ប៉េនីស៊ីលីន)**។



1. ផ្អែកលើមេរៀន តើឱសថមួយណាដែលនឹងទៅ «**សម្លាប់មេរោគ**» ដែលបង្កឱ្យសុខឈឺបំពង់ក?

.............................................................................................................................................

.............................................................................................................................................

2. ប្រសិនបើសុខលេបតែថ្នាំបំបាត់ការឈឺចាប់ តើជំងឺរបស់គេនឹងជាសះស្បើយទាំងស្រុងដែរឬទេ? ចូរពន្យល់ពីភាពខុសគ្នានៃឥទ្ធិពលឱសថទាំងពីរនេះ។

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគភាពខុសគ្នារវាងការបំបាត់រោគសញ្ញា និងការកម្ចាត់ភ្នាក់ងារបង្កជំងឺ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **B. ប៉េនីស៊ីលីន និងតេត្រាស៊ីគ្លីន**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **A. ផ្តល់ភាពស៊ាំសកម្មដើម្បីទប់ទល់នឹងមេរោគដែលចូលមកយាយីនៅថ្ងៃក្រោយ**

**សំណួរទី ៣៖**

- ១ ⇨ ខ. បន្ថយការឈឺក្បាល ក្អក និងហៀរសំបោរ។
- ២ ⇨ គ. សម្លាប់ឬបញ្ឈប់ការលូតលាស់របស់បាក់តេរីបង្កជំងឺ។
- ៣ ⇨ ក. ផ្តល់ភាពស៊ាំសកម្មដើម្បីការពារជំងឺនាពេលអនាគត។

**សំណួរទី ៤៖**

- ១. **ពិត** (ប្រភពផលិតអង់ទីប៊ីយោទិចត្រឹមត្រូវ)
- ២. **មិនពិត** (វ៉ាក់សាំងសម្រាប់បង្ការ មិនមែនសម្រាប់ព្យាបាលជំងឺដែលកំពុងឈឺភ្លាមៗទេ)
- ៣. **ពិត** (សណ្ឋានឱសថត្រឹមត្រូវ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ឱសថសម្លាប់មេរោគ៖** គឺអង់ទីប៊ីយោទិច (ប៉េនីស៊ីលីន)។
    2. **ការបកស្រាយ៖** ជំងឺមិនជាសះស្បើយទាំងស្រុងទេ ប្រសិនបើសុខលេបតែថ្នាំបំបាត់ការឈឺចាប់ ព្រោះវាគ្រាន់តែជួយ «**បន្ថយការឈឺចាប់**» មួយគ្រាប៉ុណ្ណោះ ប៉ុន្តែមេរោគបាក់តេរីនៅតែមានវត្តមាន និងលូតលាស់ក្នុងរាងកាយ។ មានតែអង់ទីប៊ីយោទិចទេ ទើបមាននាទី «**សម្លាប់មេរោគ**» ឱ្យអស់ពីខ្លួន។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវឈ្មោះអង់ទីប៊ីយោទិច តែមិនបានពន្យល់ពីភាពខុសគ្នានៃឥទ្ធិពលបំបាត់ការឈឺចាប់ និងការសម្លាប់មេរោគ។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ៣១ : សុវត្ថិភាពឱសថ និងមាគ៌ានៃការស្រូបចូលក្នុងរាងកាយ

## អត្ថបទខ្លី៖ ឱសថ - អាវុធមុខពីរ




វិបុលឆ្ងល់ថា ហេតុអ្វីបានជាថ្នាំខ្លះត្រូវលេប ខ្លះត្រូវចាក់ និងខ្លះទៀតត្រូវហឺត? លោកគ្រូពេទ្យបានពន្យល់វិបុលថា៖ «មិនថាថ្នាំចូលតាមផ្លូវណានោះទេ គោលដៅចុងក្រោយរបស់វាគឺទៅដល់ ចរន្តឈាម ដើម្បីទៅព្យាបាលកន្លែងដែលមានបញ្ហា។ ប៉ុន្តែ កូនត្រូវចាំថា រាល់សារធាតុគីមីទាំងអស់ត្រូវឆ្លងកាត់ ថ្លើម ដែលជា 'រោងចក្រចម្រោះជាតិពុល'។ បើកូនប្រើថ្នាំខុស ឬប្រើដើម្បីតែភាពសប្បាយអផ្សុក ថ្លើមរបស់កូននឹងត្រូវខូចខាតខ្លាំង ព្រោះវាត្រូវធ្វើការលើសកម្លាំងដើម្បីកម្ចាត់ជាតិគីមីទាំងនោះចេញ»។

---

## សំណួរទី ១៖ ការកំណត់អត្តសញ្ញាណការប្រើឱសថខុស

តើសកម្មភាពមួយណាខាងក្រោមនេះ ដែលចាត់ទុកថាជា «**ការប្រើប្រាស់ឱសថមិនត្រឹមត្រូវ**»?

□A. ការប្រើឱសថតាមដំបូន្មាន និងវេជ្ជបញ្ជាគ្រូពេទ្យ។

□B. ការអានស្លាកសញ្ញា និងការណែនាំមុនពេលប្រើថ្នាំ។

□C. ការប្រើប្រាស់ឱសថដើម្បីបំបាត់ភាពធុញទ្រាន់ ឬដើម្បីចុះសម្រុងនឹងមិត្តភក្តិ។

□D. ការពិភាក្សាជាមួយអ្នកឯកទេសពេទ្យមុននឹងប្រើឱសថ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ភាពខុសគ្នារវាងការប្រើប្រាស់ថ្នាំត្រឹមត្រូវ និងមិនត្រឹមត្រូវ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ សុវត្ថិភាពក្នុងការទុកដាក់ឱសថ

ដើម្បីធានាសុវត្ថិភាពដល់កុមារតូចៗនៅក្នុងផ្ទះ តើការអនុវត្តមួយណាដែលត្រឹមត្រូវបំផុត?

☐A. ទុកឱសថនៅកន្លែងដែលកុមារងាយនឹងមើលឃើញ និងយកបាន។

☐B. ដាក់ឱសថទាំងអស់ឱ្យខ្ពស់ហួសពីដៃកុមារ។

☐C. ទុកឱសថចាស់ៗដែលគ្មានស្លាកសញ្ញាឱ្យកុមាររៀនអាន។

☐D. ចែករំលែកឱសថផ្ទាល់ខ្លួនឱ្យទៅកុមារដែលមិនស្គាល់គ្នាប្រើប្រាស់។

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់វិធានការសុវត្ថិភាពក្នុងការរក្សាទុកឱសថ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ល្បឿននៃឥទ្ធិពលឱសថ

ហេតុអ្វីបានជាឱសថដែល «**ចាក់បញ្ចូល**» ទៅក្នុងសរសៃវ៉ែន ឬសាច់ដុំ មានឥទ្ធិពលរហ័សជាងការលេប?

☐A. ព្រោះវាមានរសជាតិឆ្ងាញ់ជាងថ្នាំគ្រាប់។

☐B. ព្រោះវាឆ្លងកាត់ភ្នាសស្លេស្មនៃរន្ធច្រមុះ។

☐C. ព្រោះវាត្រូវឆ្លងកាត់ការរំលាយនៅក្នុងក្រពះយូរជាង។

☐D. ព្រោះវាជ្រាបចូលយ៉ាងរហ័សទៅក្នុងសរសៃឈាមដោយផ្ទាល់។

**តារាងបញ្ជាក់លក្ខណៈបច្ចេកទេស**

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគល្បឿននៃឥទ្ធិពលឱសថតាមរយៈវិធីសាស្ត្រប្រើប្រាស់ខុសៗគ្នា។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

### សំណួរទី ៤៖ ការវាយតម្លៃលើផលប៉ះពាល់ និងការប្រើប្រាស់

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ការប្រើឱសថច្រើនជាងវេជ្ជបញ្ជា ក៏ត្រូវបានចាត់ទុកថាជាការប្រើឱសថខុសដែរ។ | ☐ | ☐ |
| ២. ឥទ្ធិពលធ្ងន់ធ្ងរនៃការប្រើឱសថមិនត្រឹមត្រូវរួមមាន ការក្អួត ព្រិលភ្នែក និងវិលមុខ។ | ☐ | ☐ |
| ៣. ឱសថដែលលេបចូល នឹងជ្រាបចូលក្នុងឈាមតាមរយៈសួតភ្លាមៗដោយមិនឆ្លងកាត់ក្រពះ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃនិយមន័យ ផលវិបាក និងដំណើរការស្រូបថ្នាំក្នុងរាងកាយ ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

---

### សំណួរទី ៥៖ ការវិភាគស្ថានភាព និងការដោះស្រាយបញ្ហា (កម្រិតខ្ពស់)

តារា ឃើញដបថ្នាំមួយនៅក្នុងផ្ទះដែលគ្មានស្លាកសញ្ញាបង្ហាញឈ្មោះ ឬកាលបរិច្ឆេទឈប់ប្រើឡើយ។ មិត្តភក្តិរបស់គេម្នាក់បានប្រាប់ថា "លេបវាទៅ វានឹងជួយឱ្យមានកម្លាំងខ្លាំងក្នុងការរត់"។



1. តើតារាគួរធ្វើតាមមិត្តភក្តិដែរឬទេ?

..............................................................................................................

..............................................................................................................

..............................................................................................................

2. ចូរលើកឡើងនូវ «**បម្រាប់សុវត្ថិភាព**» យ៉ាងតិច ២ ចំណុចពីក្នុងមេរៀន ដើម្បីពន្យល់ពីមូលហេតុដែលតារាមិនគួរប្រើថ្នាំនោះ និងវិធីដែលគេគួរចាត់ចែងចំពោះដបថ្នាំនោះ។

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | អនុវត្តវិធានការសុវត្ថិភាពឱសថក្នុងស្ថានភាពជាក់ស្តែង និងការពារគ្រោះថ្នាក់ ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. ការប្រើប្រាស់ឱសថដើម្បីបំបាត់ភាពធុញទ្រាន់ ឬដើម្បីចុះសម្រុងនឹងមិត្តភក្តិ**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **B. ដាក់ឱសថទាំងអស់ឱ្យខ្ពស់ហួសពីដៃកុមារ**

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **D. ព្រោះវាជ្រាបចូលយ៉ាងរហ័សទៅក្នុងសរសៃឈាមដោយផ្ទាល់**

**សំណួរទី ៤៖**

- ១. **ពិត** (ការប្រើលើសកម្រិតជាការប្រើខុស)
- ២. **ពិត** (ពាក្យសញ្ញាជូនដំណើរត្រឹមត្រូវតាមមេរៀន)
- ៣. **មិនពិត** (ថ្នាំលេបត្រូវឆ្លងកាត់ក្រពះ ឬពោះវៀនតូចសិន មិនមែនស្រូបភ្លាមៗទេ)
- *(ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ)*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ការសម្រេចចិត្ត៖** តារាមិនគួរធ្វើតាមមិត្តភក្តិឡើយ។
    2. **បម្រាប់សុវត្ថិភាព៖** ១. មិនត្រូវប្រើឱសថដែលមនុស្សមិនស្គាល់ម្នាក់ឱ្យយើងឡើយ (មិត្តភក្តិមិនមែនគ្រូពេទ្យ)។ ២. ត្រូវបោះចោលឱសថចាស់ៗ និងឱសថគ្មានស្លាកបិទ (ដើម្បីជៀសវាងការភាន់ច្រឡំ និងគ្រោះថ្នាក់)។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាមិនគួរប្រើ តែលើកបម្រាប់សុវត្ថិភាពបានតែ ១ ចំណុច ឬពន្យល់មិនបានច្បាស់តាមខ្លឹមសារមេរៀន។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# មេរៀនទី២ ថ្នាំជក់ និងបារី

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ៣២ : ថ្នាំជក់ - ឃាតករលាក់មុខ និងមហន្តរាយសុខភាព

### អត្ថបទខ្លី៖ ការអង្កេតរបស់ ដារ៉ា ចំពោះ "ផ្សែងពុល"




នៅពេលដើរកាត់តារាងបាល់ទាត់ ដារ៉ាបានឃើញមនុស្សមួយក្រុមជក់បារី ហើយគាត់សង្កេតឃើញថា ពួកគេធាប់ហត់ និងដកដង្ហើមមិនចង់រួចនៅពេលរត់លេង។

លោកគ្រូពេទ្យបានពន្យល់ដារ៉ាថា៖ «បារីមួយដើមមានសារធាតុពុលរាប់ពាន់ប្រភេទ។ សារធាតុ **នីកូទីន** ធ្វើឱ្យខួរក្បាលពួកគេញៀននឹងវា។ **ជ័រថា** កំពុងតែកកជាប់ក្នុងសួតដូចជាជ័រក្រាលថ្នល់ដែលបង្កឱ្យកើតមហារីក។ អ្វីដែលសំខាន់បំផុតគឺ **ឧស្ម័នកាបូនម៉ូណូអុកស៊ីត** ដែលចូលទៅដណ្ដើមកន្លែងអុកស៊ីសែនក្នុងឈាម ធ្វើឱ្យបេះដូងត្រូវធ្វើការធ្ងន់ដើម្បីរុញឈាមទៅចិញ្ចឹមរាងកាយ។ នោះហើយជាមូលហេតុដែលពួកគេគ្មានកម្លាំង និងងាយមានគ្រោះថ្នាក់ដល់បេះដូង»។

### សំណួរទី ១៖ សារធាតុបង្កភាពញៀន

តើសារធាតុគីមីមួយណាដែលមាននៅក្នុងបារី ដែលធ្វើឱ្យអ្នកជក់ញៀន និងមិនអាចបញ្ឈប់ការជក់បារីបាន?

☐A. ជ័រថា ☐B. ឧស្ម័នកាបូនម៉ូណូអុកស៊ីត ☐C. នីកូទីន ☐D. អុកស៊ីសែន

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់អត្តសញ្ញាណសារធាតុបង្កភាពញៀនក្នុងបារី។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ការដឹកជញ្ជូនអុកស៊ីសែនក្នុងឈាម

ហេតុអ្វីបានជាការស្រូបផ្សែងបារីដែលមាន «**ឧស្ម័នកាបូនម៉ូណូអុកស៊ីត**» ធ្វើឱ្យបេះដូងត្រូវខំធ្វើការខ្លាំងតែបានផលតិចតួច?

□A. ព្រោះវាធ្វើឱ្យឈាមហូរលឿនពេកទៅកាន់ខួរក្បាល។

□B. ព្រោះវាភ្ជាប់ជាមួយគោលិកាក្រហមមាំជាងអុកស៊ីសែន នាំឱ្យការចែកចាយអុកស៊ីសែនត្រូវបាត់បង់។

□C. ព្រោះវាធ្វើឱ្យសួតរីកធំជាងមុន នាំឱ្យបេះដូងពិបាករុញឈាម។

□D. ព្រោះវាធ្វើឱ្យសរសៃឈាមរីកធំ ដែលបណ្តាលឱ្យចុះសម្ពាធឈាម។

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគយន្តការនៃឧស្ម័នកាបូនម៉ូណូអុកស៊ីតលើការដឹកជញ្ជូនអុកស៊ីសែន។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៣៖ ការបែងចែកជំងឺសួត

ចូរផ្គូផ្គងប្រភេទជំងឺសួតនៅជួរ (A) ទៅនឹងការពិពណ៌នាអំពីលក្ខណៈជំងឺនៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| ជំងឺ (A) | លក្ខណៈជំងឺ (B) | ចម្លើយ |
|---|---|---|
| ១. ជំងឺរលាកទងសួត | ក. ជញ្ជាំងខណ្ឌរវាងកូនថង់សួតត្រូវបានបំផ្លាញ បង្កើតបានថង់សួតធំៗចំនួន ២-៣។ | ១ ⇨ ...... |
| ២. ជំងឺហើមសួត | ខ. ៨០% បណ្ដាលមកពីការជក់បារី និងកើនឡើងតាមចំនួនបារីដែលបានជក់។ | ២ ⇨ ...... |
| ៣. ជំងឺមហារីកសួត | គ. រោមល្អិតៗក្នុងទងសួតធ្វើការមិនបានល្អ នាំឱ្យក្អកញឹកញាប់ និងបញ្ចេញស្លេស្មច្រើន។ | ៣ ⇨ ...... |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែករោគសញ្ញា និងលក្ខណៈនៃជំងឺសួតដែលបង្កដោយបារី។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើឥទ្ធិពលនៃជំរ័ថា

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ជ័រថាជាធាតុរាវខ្មៅស្អិត ដែលបណ្ដាលឱ្យកើតមហារីកនៅកន្លែងដែលផ្សែងបារីប៉ះពាល់ផ្ទាល់។ | ☐ | ☐ |
| ២. ជ័រថាជួយសម្អាតរោមល្អិតៗក្នុងទងសួតឱ្យមានភាពស្រឡះល្អ។ | ☐ | ☐ |
| ៣. ជ័រថាធ្វើឱ្យក្រចកដៃ ធ្មេញ និងជាលិកាសួតឡើងពណ៌លឿង។ | ☐ | ☐ |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃឥទ្ធិពលជ័រថាលើសរីរាង្គ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការព្យាករណ៍ (កម្រិតខ្ពស់)



លោក "ក" ជាអ្នកជក់បារីរ៉ាំរ៉ៃ។ គាត់ចាប់ផ្តើមមានអាការៈ «ចុកទ្រូងយ៉ាងខ្លាំងនៅពេលខំប្រឹងធ្វើការងារ» ប៉ុន្តែវានឹងធូរស្រាលវិញនៅពេលគាត់សម្រាក។ គ្រូពេទ្យប្រាប់ថា គាត់កំពុងប្រឈមនឹងជំងឺសរសៃឈាមក្បូរ៉ូណែ។

1. ផ្អែកលើមេរៀន តើអាការៈរបស់គាត់ហៅថាអ្វី?

..........................................................................................................................................

..........................................................................................................................................

2. ចូរពន្យល់ពីមូលហេតុវិទ្យាសាស្ត្រដែលធ្វើឱ្យគាត់មានអាការៈឈឺចាប់បែបនេះ និងគ្រោះថ្នាក់ដែលនឹងកើតមាន ប្រសិនបើសរសៃឈាមក្បូរ៉ូណែរបស់គាត់ត្រូវបានស្ទះទាំងស្រុង។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគទំនាក់ទំនងរវាងការជក់បារី ជំងឺសរសៃឈាមក្បូរ៉ូណែ និងការគាំងបេះដូង។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាគំណៃ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. នីកូទីន**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **B. ព្រោះវាភ្ជាប់ជាមួយគោលិកាក្រហមមាំជាងអុកស៊ីសែន...**

**សំណួរទី ៣៖**

- ១ ⇨ គ. រោមល្អិតៗក្នុងទងសួតធ្វើការមិនបានល្អនាំឱ្យ ក្អកញឹកញាប់ និងបញ្ចេញស្លេស្មច្រើន។
- ២ ⇨ ក. ជញ្ជាំងខណ្ឌរវាងកូនថង់សួតត្រូវបានបំផ្លាញ បង្កើតបានថង់សួតធំៗចំនួន ២-៣។
- ៣ ⇨ ខ. ៨០% បណ្តាលមកពីការជក់បារី និងកើនឡើងតាមចំនួនបារីដែលបានជក់។

**សំណួរទី ៤៖**

- ១. **ពិត** (ជំរថាជាកាស៊ីណូសែនបង្កមហារីក)
- ២. **មិនពិត** (ជំរថាធ្វើឱ្យរោមល្អិតៗធ្វើការមិនបានត្រឹមត្រូវ)
- ៣. **ពិត** (ជំរថាធ្វើឱ្យឡើងពណ៌លឿងលើធ្មេញ និងក្រចក)
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **អាការៈ៖** ហៅថា «ការចុកទ្រូង»។
    2. **មូលហេតុ និងគ្រោះថ្នាក់៖** ការឈឺចាប់កើតឡើងដោយសារសរសៃឈាមក្បូរ៉ូណែរួមតូច នាំឈាមទៅចិញ្ចឹមសាច់ដុំបេះដូងមិនគ្រាន់។ ប្រសិនបើសរសៃឈាមស្ទះទាំងស្រុង បេះដូងនឹងមិនអាចទទួលអាហារ និងអុកស៊ីសែនបានឡើយ ដែលនាំឱ្យកើត «ជំងឺគាំងបេះដូង (គាំងបេះដូង)» ដែលអាចបណ្តាលឱ្យស្លាប់។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវឈ្មោះជំងឺ តែមិនពន្យល់ពីមូលហេតុនៃការខ្វះអុកស៊ីសែនក្នុងសាច់ដុំបេះដូង។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ៣៣ : ការជក់បារីអកម្ម

## អត្ថបទខ្លី៖ ផ្សែងបារី និងសិទ្ធិទទួលបានខ្យល់ស្អាត




នៅថ្ងៃសម្រាក វិបុលបានទៅអង្គុយលេងនៅសួនច្បារសាធារណៈ។ ក្បែរនោះ គាត់ឃើញបុរសម្នាក់កំពុងជក់បារី ហើយខ្យល់បានបក់ផ្សែងនោះមកចំវិបុល និងកុមារតូចៗដែលកំពុងលេងនៅក្បែរនោះ។ វិបុលចាប់ផ្តើមក្អក និងមានអារម្មណ៍ថប់ដង្ហើម។ គាត់ចាំបានថាលោកគ្រូពេទ្យធ្លាប់ពន្យល់ថា៖ «ទោះបីកូនមិនមែនជាអ្នកជក់ផ្ទាល់ ប៉ុន្តែការដកដង្ហើមយកផ្សែងពីអ្នកដទៃចូលសួត ហៅថា **ការជក់បារីអកម្ម**។ ផ្សែងនេះមានជាតិពុលដូចអ្នកជក់បារីដែរ ហើយវាអាចធ្វើឱ្យកុមារតូចៗងាយឈឺសួត និងប៉ះពាល់ដល់ការលូតលាស់»។ វិបុលមានអារម្មណ៍ថា វាជារឿងមិនយុត្តិធម៌ឡើយ ដែលសុខភាពរបស់គាត់ត្រូវរងគ្រោះដោយសារទម្លាប់របស់អ្នកដទៃក្នុងទីសាធារណៈ។

## សំណួរទី ១៖ និយមន័យនៃការជក់បារីអកម្ម

តើអ្វីទៅដែលហៅថា «**ការជក់បារីអកម្ម**»?

□A. ការព្យាយាមជក់បារីដោយខ្លួនឯងដើម្បីឱ្យមានកម្លាំងខ្លាំង។

□B. ការប្រើប្រាស់បារីអេឡិចត្រូនិកជំនួសឱ្យបារីធម្មតា។

□C. ការស្រូបយកខ្យល់ក្នុងបរិយាកាសដែលមានផ្សែងបារីពីអ្នកដទៃដោយស្វ័យប្រវត្តិ។

□D. ការជក់បារីតែនៅក្នុងបន្ទប់បិទជិតម្នាក់ឯង។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់និយមន័យនៃការជក់បារីដោយប្រយោល។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

### សំណួរទី ២៖ ផលប៉ះពាល់លើទារក និងកុមារ

យោងតាមមេរៀន តើទារកដែលកើតពីម្ដាយដែលស្រូបផ្សែងបារីពីអ្នកដទៃជាប្រចាំក្នុងពេលមានផ្ទៃពោះ អាចជួបប្រទះវិបាកអ្វីខ្លះ? (ជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុត)

□A. កើតមកមិនគ្រប់ទម្ងន់ មិនគ្រប់លក្ខណៈ ឬអាចស្លាប់ភ្លាមក្រោយកើត។

□B. កើតមកមានទម្ងន់ខ្ពស់លើសកម្រិត និងឆ្លាតវាងវៃ។

□C. មានប្រព័ន្ធស៊ាំរឹងមាំជាងកុមារដទៃទៀត។

□D. មិនមានផលប៉ះពាល់អ្វីឡើយ ព្រោះទារកនៅក្នុងស្បូនមានរបាំងការពារ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីគ្រោះថ្នាក់នៃផ្សែងបារីចំពោះម្ដាយ និងទារកក្នុងផ្ទៃ។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

### សំណួរទី ៣៖ ការវិភាគលើគុណភាពការងារ និងសីលធម៌

ហេតុអ្វីបានជាគេចាត់ទុក ការជក់បារីនៅក្នុងការិយាល័យ ឬទីប្រជុំជន ធ្វើឱ្យគុណភាពថយចុះ?

□A. ព្រោះវាធ្វើឱ្យបុគ្គលិកចំណាយពេលច្រើនក្នុងការជក់បារី។

□B. ព្រោះផ្សែងបារីបង្កផលប៉ះពាល់ដល់បរិស្ថានដូចឧស្ម័នពុល និងនាំឱ្យសមត្ថភាពពិចារណាថយចុះ។

□C. ព្រោះវាមិនមានផាសុកភាពសម្រាប់អ្នកជក់បារីក្នុងការអង្គុយធ្វើការ។

□D. ព្រោះវាជួយឱ្យបុគ្គលិកទាំងអស់ចេះចែករំលែកបារីគ្នាទៅវិញទៅមក។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| | |
|---|---|
| លក្ខណៈ | ការពិពណ៌នា |
| លទ្ធផលសិក្សា | វិភាគឥទ្ធិពលនៃផ្សែងបារីលើសមត្ថភាពបញ្ញា និងបរិយាកាសការងារ។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ៣ |

### សំណួរទី ៤៖ ការវាយតម្លៃលើឥទ្ធិពលចំពោះកុមារ

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. កុមារដែលស្រូបផ្សែងបារីយូរអង្វែង នឹងមានការលូតលាស់យឺតទាំងរាងកាយ និងសតិបញ្ញា។ | ☐ | ☐ |
| ២. ផ្សែងបារីជួយឱ្យកុមារដែលមានជំងឺហឺតស្រឡះទងសួត និងដកដង្ហើមបានស្រួលជាងមុន។ | ☐ | ☐ |
| ៣. ការជក់បារីរបស់ឪពុកម្ដាយផ្ដល់គំរូមិនល្អ ដែលនាំឱ្យកូនយកតម្រាប់តាម។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| | |
|---|---|
| លក្ខណៈ | ការពិពណ៌នា |
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃផលប៉ះពាល់ផ្សែងបារីលើកុមារ និងឥទ្ធិពលសង្គម។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

### សំណួរទី ៥៖ ការវិភាគស្ថានភាព និងសិទ្ធិបុគ្គល

លោក "ខ" ជក់បារីនៅក្នុងភោជនីយដ្ឋានដែលមានមនុស្សច្រើន ទោះបីជាមានស្លាកសញ្ញា "ហាមជក់បារី" ក៏ដោយ។ គាត់បានប្រាប់អ្នកដែលត្អូញត្អែរថា "នេះជាសិទ្ធិសេរីភាពរបស់ខ្ញុំក្នុងការជក់បារី ព្រោះខ្ញុំបានបង់លុយទិញបារីដោយខ្លួនឯង"។




1. ផ្អែកលើខ្លឹមសារមេរៀន តើការលើកឡើងរបស់លោក "ខ" ត្រឹមត្រូវដែរឬទេ?

......................................................................................................................................

......................................................................................................................................

......................................................................................................................................

2. ចូរពន្យល់ពីរបៀបដែលសកម្មភាពរបស់គាត់ «រំលោភសិទ្ធិអ្នកដទៃ» និងផលប៉ះពាល់ដែលគាត់បង្កដល់បរិយាកាសនៅក្នុងភោជនីយដ្ឋាននោះ។

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគតុល្យភាពរវាងសិទ្ធិបុគ្គល និងការទទួលខុសត្រូវចំពោះសុខភាពសាធារណៈ ។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. ការស្រូបយកខ្យល់ក្នុងបរិយាកាសដែលមានផ្សែងបារីពីអ្នកដទៃដោយស្វ័យប្រវត្តិ**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **A. កើតមកមិនគ្រប់ទម្ងន់ មិនគ្រប់លក្ខណៈ ឬអាចស្លាប់ភ្លាមក្រោយកើត**

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **B. ព្រោះផ្សែងបារីបង្កផលប៉ះពាល់ដល់បរិស្ថានដូចឧស្ម័នពុល និងនាំឱ្យសមត្ថភាពពិចារណាថយចុះ**

**សំណួរទី ៤៖**

- ១. **ពិត** (ផលប៉ះពាល់លើការលូតលាស់កុមារត្រឹមត្រូវ)
- ២. **មិនពិត** (ផ្សែងបារីធ្វើឱ្យជំងឺហឺតកាន់តែធ្ងន់ធ្ងរឡើង)
- ៣. **ពិត** (ឪពុកម្ដាយជាគំរូដល់កូន)
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ការវាយតម្លៃ៖** ការលើកឡើងរបស់លោក "ខ" មិនត្រឹមត្រូវទេ។ សិទ្ធិសេរីភាពបុគ្គលមិនត្រូវរំលោភលើសុខភាពអ្នកដទៃឡើយ។
  2. **ការពន្យល់៖** សកម្មភាពរបស់គាត់កំពុង «រំលោភសិទ្ធិអ្នកមិនជក់បារី» ក្នុងការទទួលបានខ្យល់អាកាសបរិសុទ្ធ។ ផ្សែងបារីរបស់គាត់ធ្វើឱ្យបរិយាកាសអាប់អួរ មានក្លិនអាក្រក់ ពិបាកដកដង្ហើម និងបង្កហានិភ័យជំងឺដល់មនុស្សគ្រប់រូបក្នុងភោជនីយដ្ឋាន ជាពិសេសកុមារ និងស្ត្រីមានផ្ទៃពោះ។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថារំលោភសិទ្ធិគេ តែមិនបានពន្យល់ពីផលប៉ះពាល់ដល់បរិយាកាស ឬអ្នកជុំវិញខ្លួនឱ្យបានច្បាស់លាស់។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ៣៤ : យុទ្ធសាស្ត្រឈ្នះផ្សែងបារី និងការកសាងសង្គមមានសុខភាពល្អ

## អត្ថបទខ្លី៖ ផ្លូវឆ្ពោះទៅរកការផ្តាច់បារី



សីហា មានការត្រេកអរយ៉ាងខ្លាំងនៅពេលឃើញ ពូសុខ សម្រេចចិត្តបោះបង់ការជក់បារីដែលគាត់បានធ្វើអស់រយៈពេល ១០ ឆ្នាំមកហើយ។

ពូសុខប្រាប់សីហាថា៖ «វាមិនងាយស្រួលទេក្មួយ! រាល់ពេលដែលពូចង់ឈប់ ពូមានអារម្មណ៍មួម៉ៅ ដៃញ័រ និងពិបាកក្នុងចិត្តណាស់ ព្រោះខួរក្បាលពូវាស៊ាំនឹងជាតិ **នីកូទីន** ទៅហើយ»។ សីហាបានលើកទឹកចិត្តពូ ហើយរំលឹកពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើដូចជា ការដាក់រូបភាពខ្លាចៗលើកញ្ចប់បារី និងការតម្លើងថ្លៃបារី។

សីហាបានណែនាំពូថា៖ «រាល់ពេលដែលពូចង់ជក់ ពូសាកដកដង្ហើមវែងៗ ឬក្រេបទឹកបន្តិចម្តងៗ ដើម្បីឱ្យខួរក្បាលបំភ្លេចចំណង់នោះមួយគ្រា»។ ត្រឹមតែប៉ុន្មានសប្តាហ៍ ពូសុខចាប់ផ្តើមមានអារម្មណ៍ថាដកដង្ហើមបានស្រួល និងមានកម្លាំងជាងមុន។

## សំណួរទី ១៖ វិធានការរបស់រដ្ឋាភិបាល

តើចំណុចមួយណាខាងក្រោមដែលជាសកម្មភាពរបស់ «**រដ្ឋាភិបាល**» ក្នុងការបង្ការការជក់បារី?

□A. ការណែនាំឱ្យអ្នកជក់បារីប្តូរទៅជក់បារីដែលមានតម្លៃថោកជាងមុន។

□B. ការបង្កើតកន្លែងជក់បារីឱ្យបានច្រើននៅតាមសាលារៀន និងមន្ទីរពេទ្យ។

□C. ការដំឡើងអត្រាពន្ធដារលើថ្នាំជក់ និងហាមឃាត់ការផ្សាយពាណិជ្ជកម្មបារី។

□D. ការលើកទឹកចិត្តឱ្យកុមារសាកល្បងជក់បារីដើម្បីឱ្យស្គាល់រសជាតិ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់វិធានការសាធារណៈក្នុងការកាត់បន្ថយការប្រើប្រាស់ថ្នាំជក់។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ២៖ ចំណុចចាប់ផ្តើមនៃការបញ្ឈប់ការជក់បារី

ផ្អែកលើវិធីសាស្ត្របញ្ឈប់ការជក់បារី តើកត្តាអ្វីដែលត្រូវបានចាត់ទុកថាជា «**ចំណុចសំខាន់បំផុត**» ដែលនាំឱ្យការឈប់ជក់បារីអាចសម្រេចទៅបាន?

□A. ការតាំងចិត្តយ៉ាងមុតមាំក្នុងការសម្រេចចិត្តឈប់។

□B. ការមានប្រាក់ច្រើនសម្រាប់ទិញស្ករកៅស៊ូ។

□C. ការរង់ចាំរហូតដល់មានអារម្មណ៍ចង់ឈប់នៅឆ្នាំក្រោយ។

□D. ការជក់បារីឱ្យអស់ពីកញ្ចប់សិនមុននឹងឈប់។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីសារៈសំខាន់នៃកត្តាចិត្តសាស្ត្រ (ការតាំងចិត្ត) ក្នុងការកែប្រែទម្លាប់។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការទប់ទល់នឹងចំណង់ជក់បារីខ្លាំង

នៅពេលអ្នកជក់មានចំណង់ជក់បារីខ្លាំងម្តងៗ (ដែលជាធម្មតាមានរយៈពេលតែ ៣-៥ នាទី) តើវិធីសាស្ត្រសាមញ្ញមួយណាដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការទប់ទល់?

□A. ការនៅក្បែរអ្នកដែលកំពុងជក់បារីដើម្បីហឹតក្លិន។

□B. ការដេកនៅស្ងៀមម្នាក់ឯងក្នុងបន្ទប់ងងឹត។

□C. ការទទួលទានកាហ្វេ ឬគ្រឿងស្រវឹងបន្ថែម។

□D. ការក្រេបទឹកបន្តិចម្តងៗឱ្យអស់មួយកែវ ឬដកដង្ហើមវែងៗ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| | |
|---|---|
| លក្ខណៈ | ការពិពណ៌នា |
| លទ្ធផលសិក្សា | យល់ដឹងពីសារៈសំខាន់នៃកត្តាចិត្តសាស្ត្រ (ការតាំងចិត្ត) ក្នុងការកែប្រែទម្លាប់។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

### សំណួរទី ៤៖ ការវាយតម្លៃលើរោគសញ្ញាញៀន

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. រោគសញ្ញាញៀនដូចជា ការមួម៉ៅ ឈឺក្បាល នឹងកើនឡើងខ្លាំងជានិច្ចរហូតដល់ស្លាប់។ | ☐ | ☐ |
| ២. នៅថ្ងៃទី ៣ ឬទី ៤ នៃការឈប់ជក់បារី អ្នកជក់នឹងចាប់ផ្តើមមានអាការៈស្រួលខ្លួន និងដកដង្ហើមស្រឡះ។ | ☐ | ☐ |
| ៣. ការកំណត់កាលបរិច្ឆេទឱ្យច្បាស់លាស់ (ដូចជាថ្ងៃនេះ) ជួយការពារកុំឱ្យការតាំងចិត្តធ្លាក់ចុះ។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| | |
|---|---|
| លក្ខណៈ | ការពិពណ៌នា |
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃដំណើរការសេរីវិទ្យាក្នុងកំឡុងពេលផ្តាច់បារី។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

### សំណួរទី ៥៖ ការវិភាគស្ថានភាព និងការរៀបចំផែនការ (កម្រិតខ្ពស់)

ពូ "ស" ចង់ឈប់ជក់បារី ប៉ុន្តែគាត់តែងតែបរាជ័យរាល់ពេលជួបជុំមិត្តភក្តិដែលផឹកស្រា និងជក់បារី។ គាត់គិតថាគាត់មិនអាចឈប់បានទេ ព្រោះរាល់ពេលឈប់ គាត់តែងតែមានអារម្មណ៍តប់ប្រមល់ និងមួម៉ៅខ្លាំង។




1. ផ្អែកលើមេរៀន ចូរពន្យល់ពូ "ស" ថា តើអាការៈមួម៉ៅរបស់គាត់ជាអ្វី?

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

2. ចូរផ្តល់ "ផែនការសកម្មភាព" ចំនួន ៣ ចំណុច ដើម្បីជួយគាត់ឱ្យជៀសផុតពីការល្បួង និងទប់ទល់នឹងចំណង់បារីក្នុងសប្តាហ៍ដំបូង។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគរោគសញ្ញាញៀន និងបង្កើតយុទ្ធសាស្ត្រផ្តាច់បារីក្នុងស្ថានភាពសង្គមជាក់ស្តែង។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. ការដំឡើងអត្រាពន្ធដារលើថ្នាំជក់ និងហាមឃាត់ការផ្សាយពាណិជ្ជកម្មបារី**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **A. ការតាំងចិត្តយ៉ាងមុតមាំក្នុងការសម្រេចចិត្តឈប់**

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **D. ការក្រេបទឹកបន្តិចម្តងៗឱ្យអស់មួយកែវ ឬដកដង្ហើមវែងៗ**

**សំណួរទី ៤៖**

- ១. **មិនពិត** (រោគសញ្ញាញៀននឹងថយចុះជាលំដាប់ មិនមែនកើនឡើងរហូតទេ)
- ២. **ពិត** (អាការៈនឹងល្អប្រសើរឡើងនៅថ្ងៃទី ៣ ឬទី ៤)
- ៣. **ពិត** (ការកំណត់ថ្ងៃច្បាស់លាស់ជួយឱ្យការអនុវត្តមានប្រសិទ្ធភាព)
- *ត្រូវតែគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ការពន្យល់៖** អាការៈមួម៉ៅ និងតប់ប្រមល់នោះគឺជា «រោគសញ្ញាញៀន» ដែលកើតឡើងធម្មតានៅប៉ុន្មានថ្ងៃដំបូង ហើយវានឹងថយចុះជាលំដាប់។
    2. **ផែនការសកម្មភាព (ជ្រើសរើស ៣ ក្នុងចំណោម)៖** ១. នៅឆ្ងាយពីអ្នកជក់បារី និងកន្លែងផឹកស្រា (ដើម្បីកុំឱ្យមានចំណង់)។ ២. បោះបារី និងកែវស្មារបារីចោលឱ្យអស់ពីផ្ទះ។ ៣. អនុវត្តវិធីទប់ទល់ចំណង់ខ្លាំង (ក្រេបទឹក ដកដង្ហើមវែងៗ ឬធ្វើពលកម្មស្រាលៗ)។ ៤. សុំការគាំទ្រពីគ្រួសារ។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវតែចំណុចរោគសញ្ញាញៀន ឬផ្តល់ផែនការមិនបានគ្រប់ចំនួន ឬមិនសមស្របតាមមេរៀន។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

## មេរៀនទី៣ អាល់កុល និងថ្នាំជក់

តំណភ្ជាប់វីដេអូមេរៀន

សូមស្កេន QR Code ដើម្បីស្វែងយល់ពីខ្លឹមសារគោលតាមរយៈវីដេអូ។

## ប្រធានបទទី ៣៥ : គ្រឿងស្រវឹង - ឧបសគ្គនៃប្រព័ន្ធប្រសាទ និងសុខភាពរាងកាយ

### អត្ថបទខ្លី៖ ការអង្កេតរបស់ «សុវណ្ណ» ចំពោះឥទ្ធិពលនៃគ្រឿងស្រវឹង



នៅក្នុងពិធីជប់លៀងមួយ សុវណ្ណបានសង្កេតឃើញបុរសម្នាក់ ដែលបានផឹកគ្រឿងស្រវឹងច្រើន ចាប់ផ្តើមនិយាយមិនច្បាស់ ដើរទ្រេតទ្រោត និងឆ្លើយតបយឺតយ៉ាវខុសពីធម្មតា។ សុវណ្ណនឹកឃើញមេរៀនវិទ្យាសាស្ត្រដែលលោកគ្រូបានបង្រៀនថា៖ «អាល់កុលមិនមែនជាថ្នាំបង្កើនកម្លាំងចិត្តទេ ផ្ទុយទៅវិញវាគឺជាសារធាតុដែលធ្វើឱ្យ **ប្រព័ន្ធប្រសាទធ្លាក់ទឹកចិត្ត**។ វារារាំងការបញ្ជូនព័ត៌មានពីខួរក្បាលទៅកាន់សាច់ដុំ ធ្វើឱ្យយើងបាត់បង់ម្ចាស់ការលើការចងចាំ និងការទប់លំនឹងខ្លួន»។ គាត់ក៏ដឹងទៀតថា ក្នុងពេលជាមួយគ្នានោះ **ថ្លើម** របស់បុរសម្នាក់នោះកំពុងធ្វើការយ៉ាងធ្ងន់ធ្ងរដើម្បីចម្រោះជាតិអាល់កុលចេញពីឈាម ដើម្បីការពារកុំឱ្យរាងកាយរងគ្រោះថ្នាក់ខ្លាំងពេក។

### សំណួរទី ១៖ ឥទ្ធិពលលើប្រព័ន្ធប្រសាទ

តើគ្រឿងស្រវឹងមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះការបញ្ជូនព័ត៌មាននៅក្នុងរាងកាយ?

☐A. ធ្វើឱ្យការបញ្ជូនព័ត៌មានពីខួរក្បាលទៅសរីរាង្គមានល្បឿនលឿនជាងមុន។

☐B. ធ្វើឱ្យយឺតយ៉ាវដល់ការបញ្ជូនព័ត៌មានពីខួរក្បាលទៅសរីរាង្គ និងពន្យឺតរយៈពេលឆ្លើយតប។

☐C. ជួយឱ្យខួរក្បាលប្រមូលអារម្មណ៍បានល្អ និងចងចាំបានច្បាស់លាស់។

☐D. មិនមានឥទ្ធិពលអ្វីឡើយចំពោះប្រព័ន្ធប្រសាទ។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ឥទ្ធិពលនៃគ្រឿងស្រវឹងលើប្រព័ន្ធប្រសាទ។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

### សំណួរទី ២៖ ដំណើរការបំបែកជាតិពុលក្នុងថ្លើម

តើការពណ៌នាមួយណាខាងក្រោមដែលត្រឹមត្រូវអំពីការ «**ស្វាងស្រវឹង**»?

□A. ការហាត់ប្រាណ និងការស្រូបខ្យល់បរិសុទ្ធជួយបង្កើនល្បឿនថ្លើមក្នុងការបំបែកអាល់កុល។

□B. ការងូតទឹកត្រជាក់ និងការផឹកកាហ្វេខ្មៅជួយឱ្យឆាប់ស្វាងស្រវឹងភ្លាមៗ។

□C. ការស្វាងស្រវឹងត្រូវការពេលវេលា ព្រោះថ្លើមអាចបំបែកសារធាតុពុលបានក្នុងកម្រិតកំណត់ក្នុងមួយម៉ោង។

□D. ការក្អួតចេញមកវិញ គឺជាវិធីសាស្ត្រតែមួយគត់ដែលធ្វើឱ្យជាតិអាល់កុលអស់ពីឈាម។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីយន្តការបំបែកអាល់កុលរបស់ថ្លើម និងកត្តាពេលវេលា។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៣៖ ការវិភាគផលប៉ះពាល់តាមបរិមាណ

ចូរផ្គូផ្គងបរិមាណនៃការផឹកគ្រឿងស្រវឹងនៅជួរ (A) ទៅនឹងរោគសញ្ញាដែលកើតឡើងនៅជួរ (B) ឱ្យបានត្រឹមត្រូវ៖

| បរិមាណ (A) | រោគសញ្ញា (B) | ចម្លើយ |
|---|---|---|
| ១. ផឹក ២-៣ កែវដំបូង | ក. ស្រវាំងភ្នែក ច្របូកច្របល់ សមត្ថភាពបញ្ញាសាច់ដុំចុះខ្សោយ។ | ១ ⇨ ...... |
| ២. ផឹក ២-៣ កែវបន្តទៀត | ខ. អារម្មណ៍ធូរស្បើយ ប្រតិកម្មឆ្លើយតបយឺត។ | ២ ⇨ ...... |
| ៣. ផឹកបន្តទៀតជាច្រើនកែវ | គ. និយាយឡូលៗ អាកប្បកិរិយាឆ្គាំឆ្គង រំជួលចិត្តខ្លាំង។ | ៣ ⇨ ...... |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | បែងចែករោគសញ្ញានៃការពុលអាល់កុលតាមកម្រិតប្រើប្រាស់។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ផ្គូផ្គង |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ៤៖ ការវាយតម្លៃលើផលប៉ះពាល់រយៈពេលវែង

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ការផឹកស្រារយៈពេលយូរអាចបណ្តាលឱ្យកើតជំងឺក្រិនថ្លើម និងមហារីកបំពង់អាហារ ។ | ☐ | ☐ |
| ២. អាហារដែលមាននៅក្នុងក្រពះ ជួយលុបបំបាត់កម្រិតនៃការពុលស្រាទាំងស្រុង។ | ☐ | ☐ |
| ៣. គ្រឿងស្រវឹងមិនជ្រាបចូលទៅក្នុងជាលិកាខួរក្បាលរបស់រាងកាយឡើយ។ | ☐ | ☐ |

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| | |
|---|---|
| លក្ខណៈ | ការពិពណ៌នា |
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃផលវិបាកសុខភាព និងលក្ខណៈរូបសាស្ត្រនៃអាល់កុល។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

## សំណួរទី ៥៖ ការវិភាគស្ថានភាព និងការសន្និដ្ឋាន (កម្រិតខ្ពស់)

លោក "ក" បានផឹកស្រាបៀរអស់ជាច្រើនដបក្នុងពិធីជប់លៀងមួយ។ គាត់មានអារម្មណ៍ថាខ្លួនឯងនៅស្វាហាប់ ហើយចង់បើកបររថយន្តត្រឡប់ទៅផ្ទះវិញ។ មិត្តភក្តិរបស់គាត់បានព្យាយាមឃាត់ ប៉ុន្តែគាត់និយាយថា "មិនអីទេ ខ្ញុំទើបតែងូតទឹកត្រជាក់ និងផឹកកាហ្វេខ្មៅរួច ខ្ញុំស្វាហាប់ណាស់"។




1. តើការជឿជាក់លើខ្លួនឯងរបស់លោក "ក" ត្រឹមត្រូវតាមលក្ខណៈវិទ្យាសាស្ត្រដែរឬទេ?

..........................................................................................................

..........................................................................................................

2. ចូរពន្យល់ពីគ្រោះថ្នាក់ដែលនឹងកើតឡើង ប្រសិនបើគាត់បើកបរក្នុងស្ថានភាពបែបនេះ ដោយផ្សារភ្ជាប់ទៅនឹង «រយៈពេលឆ្លើយតប» និង «ការបញ្ជូនព័ត៌មានពីខួរក្បាល»។

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគគ្រោះថ្នាក់នៃការបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង និងបដិសេធជំនឿខុសឆ្គងពីការស្វាងស្រវឹង។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ A. ធ្វើឱ្យយឺតយ៉ាវដល់ការបញ្ជូនព័ត៌មានពីខួរក្បាលទៅសរីរាង្គ និងពន្យឺតរយៈពេលឆ្លើយតប

**សំណួរទី ២៖**

ចម្លើយត្រូវ៖ C. ការស្វាងស្រវឹងត្រូវការពេលវេលា ព្រោះថ្លើមអាចបំបែកសារធាតុពុលបានក្នុងកម្រិតកំណត់...

**សំណួរទី ៣៖**

- ១ ⇨ ខ. អារម្មណ៍ធូរស្បើយ ប្រតិកម្មឆ្លើយតបយឺត។
- ២ ⇨ គ. និយាយឡូលៗ អាកប្បកិរិយាឆ្គាំឆ្គង រំជួលចិត្តខ្លាំង។
- ៣ ⇨ ក. ស្រវាំងភ្នែក ប្រឫកប្រឫល សមត្ថភាពបញ្ញាសាច់ដុំចុះខ្សោយ។

**សំណួរទី ៤៖**

- ១. **ពិត** (ជំងឺក្រិនថ្លើម និងមហារីកជាផលប៉ះពាល់រយៈពេលវែង)
- ២. **មិនពិត** (អាហារគ្រាន់តែបន្ថយអត្រាជ្រាបចូល តែមិនកាត់បន្ថយកម្រិតពុលទេ)
- ៣. **ពិត** (អាល់កុលចែកចាយតែក្នុងសរីរាង្គមានជាតិទឹក មិនចូលជាលិកាខ្លាញ់ទេ)
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ការវាយតម្លៃ៖** មិនត្រឹមត្រូវតាមលក្ខណៈវិទ្យាសាស្ត្រទេ ការងូតទឹក ឬផឹកកាហ្វេមិនធ្វើឱ្យឆាប់ស្វាងស្រវឹងឡើយ។
    2. **ការពន្យល់គ្រោះថ្នាក់៖** ការបើកបរនឹងមានគ្រោះថ្នាក់ខ្លាំង ព្រោះអាល់កុលធ្វើឱ្យ «ការបញ្ជូនព័ត៌មានពីខួរក្បាល» យឺតយ៉ាវ ដែលនាំឱ្យ «រយៈពេលឆ្លើយតប» ទៅនឹងហេតុការណ៍ចៃដន្យលើដងផ្លូវត្រូវពន្យឺត។ លើសពីនេះ គាត់អាចមានការស្រវាំងភ្នែក និងបាត់បង់សមត្ថភាពបញ្ញាសាច់ដុំ ដែលងាយបង្កគ្រោះថ្នាក់ចរាចរណ៍បំផុត។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាគ្រោះថ្នាក់ តែមិនបានបញ្ជាក់ពីការភាន់ច្រឡំរឿងវិធីស្វាងស្រវឹង ឬមិនបានប្រើពាក្យបច្ចេកទេស "រយៈពេលឆ្លើយតប"។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទ ទី៣៦ : ឥទ្ធិពលគ្រឿងស្រវឹងលើរាងកាយស្ត្រី និងសុខភាពគភ៌

## អត្ថបទខ្លី៖ វិចិត្រ និងការស្វែងយល់ពី "គ្រោះថ្នាក់ដែលមើលមិនឃើញ"




វិចិត្របានអានខិត្តប័ណ្ណសុខភាពមួយនៅមន្ទីរពេទ្យ ខណៈពេលរង់ចាំបងស្រីរបស់គាត់ដែលកំពុងមានផ្ទៃពោះទៅពិនិត្យសុខភាព។

នៅក្នុងនោះមានសរសេរថា៖ «គ្រឿងស្រវឹងមិនមែនជាមិត្តរបស់មនុស្សគ្រប់គ្នានោះទេ ជាពិសេសគឺស្ត្រី»។ លោកគ្រូពេទ្យបានពន្យល់វិចិត្របន្ថែមថា៖ «ដោយសារលក្ខណៈជីវសាស្ត្រ រាងកាយស្ត្រីបំបែកជាតិអាល់កុលបានយឺតជាងបុរស ធ្វើឱ្យវាស្ថិតក្នុងឈាមបានយូរ និងមានគ្រោះថ្នាក់ជាង។ ប៉ុន្តែអ្វីដែលគួរឱ្យបារម្ភបំផុតនោះគឺសម្រាប់បងស្រីកូនដែលកំពុងមានផ្ទៃពោះ ប្រសិនបើគាត់ផឹកស្រា ជាតិអាល់កុលនឹងជ្រាបតាមឈាមឆ្លងកាត់ **សុក** ទៅដល់ទារកផ្ទាល់តែម្តង។ វាអាចធ្វើឱ្យទារកលូតលាស់មិនធម្មតា ឬមានពិការភាពខួរក្បាលតាំងពីកំណើត»។ វិចិត្រក៏យល់ច្បាស់ថា ហេតុអ្វីបានជាគ្រូពេទ្យណែនាំឱ្យបងស្រីគាត់អនុវត្តគោលការណ៍ «**សូន្យអាល់កុល**»។

## សំណួរទី ១៖ មូលហេតុនៃកំហាប់អាល់កុលខ្ពស់ចំពោះស្ត្រី

ប្រសិនបើបុរស និងស្ត្រីដែលមានទម្ងន់ស្មើគ្នា ផឹកគ្រឿងស្រវឹងក្នុងបរិមាណដូចគ្នា តើហេតុអ្វីបានជាស្ត្រីមានកំហាប់ជាតិអាល់កុលក្នុងឈាមខ្ពស់ជាងបុរស?

□A. ព្រោះរាងកាយស្ត្រីមានជាតិទឹកច្រើនជាងបុរស។

□B. ព្រោះស្ត្រីមានថ្លើមធំជាងបុរស ដែលធ្វើឱ្យស្រូបអាល់កុលលឿន។

□C. ព្រោះរាងកាយស្ត្រីផ្ទុកជាតិខ្លាញ់ច្រើនជាង និងមានជាតិទឹកតិចជាងបុរស។

□D. ព្រោះអរម៉ូនស្ត្រីជួយកាត់បន្ថយការស្រវឹងបានលឿន។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគមូលហេតុរូបសាស្ត្រ(ជាតិទឹក និងខ្លាញ់ ដែលប៉ះពាល់ដល់កំហាប់អាល់កុល |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

## សំណួរទី ២៖ ឥទ្ធិពលនៃថ្នាំពន្យារកំណើត និងអរម៉ូន

តើការប្រើប្រាស់ «**ថ្នាំពន្យារកំណើត**» ជះឥទ្ធិពលយ៉ាងដូចម្តេចដល់ការបញ្ចេញជាតិអាល់កុលពីរាងកាយស្ត្រី?

□A. ជួយឱ្យរាងកាយបញ្ចេញជាតិអាល់កុលបានលឿនជាងធម្មតា។

□B. ធ្វើឱ្យពេលវេលាដើម្បីបញ្ចេញជាតិអាល់កុលពីរាងកាយយូរជាងស្ត្រីដែលមិនប្រើប្រាស់។

□C. ជួយការពារថ្លើមមិនឱ្យខូចដោយសារគ្រឿងស្រវឹង។

□D. មិនមានឥទ្ធិពលអ្វីទាល់តែសោះចំពោះការបញ្ចេញជាតិអាល់កុល។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីអន្តរកម្មរវាងថ្នាំពន្យារកំណើត និងការបញ្ចេញជាតិអាល់កុល។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ៣៖ ការវាយតម្លៃលើសុខភាពស្ត្រី និងគភ៌

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ស្ត្រីដែលផឹកគ្រឿងស្រវឹងច្រើន ប្រឈមមុខនឹងការកើតជំងឺមហារីកដោះខ្ពស់ជាងធម្មតា។ | □ | □ |
| ២. ជាតិអាល់កុលមិនអាចឆ្លងកាត់សុកទៅដល់ទារកក្នុងផ្ទៃបានឡើយ។ | □ | □ |
| ៣. គ្មានកម្រិតនៃការទទួលទានគ្រឿងស្រវឹងណាមួយដែលចាត់ទុកថាមានសុវត្ថិភាពឡើយ ក្នុងកំឡុងពេលមានផ្ទៃពោះ។ | □ | □ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃភាពត្រឹមត្រូវនៃហានិភ័យមហារីក និងសុវត្ថិភាពគភ៌។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

### សំណួរទី ៤៖ ផលវិបាកចំពោះទារក (ចង្កោមរោគសញ្ញា)

តើទារកដែលកើតពីម្តាយញៀនគ្រឿងស្រវឹងក្នុងកំឡុងពេលមានផ្ទៃពោះ អាចជួបប្រទះបញ្ហាអ្វីខ្លះ?

□A. មានមុខមាត់មិនប្រក្រតី ពិការផ្នែករាងកាយ និងមានអាការៈញៀនក្រោយពេលកើត។

□B. មានប្រាជ្ញាឆ្លាតវាងវៃ និងរូបរាងកាយរឹងមាំជាងទារកដទៃ។

□C. កើតមកគ្រប់លក្ខណៈ ប៉ុន្តែមានបញ្ហាស្បែកឡើងពណ៌លឿងតែប៉ុណ្ណោះ។

□D. មិនមានបញ្ហាអ្វីឡើយ ប្រសិនបើម្តាយឈប់ផឹកស្រាត្រឹម ១ ថ្ងៃមុនសម្រាល។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ផលវិបាកនៃចង្កោមរោគសញ្ញាស្លាប់ដោយគ្រឿងស្រវឹងលើទារក។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ២ |

### សំណួរទី ៥៖ ការវិភាគស្ថានភាព និងការផ្តល់ដំបូន្មាន (កម្រិតខ្ពស់)



ស្ត្រីម្នាក់មានផ្ទៃពោះ ៥ ខែ។ មិត្តភក្តិរបស់គាត់បានប្រាប់ថា "ផឹកស្រាក្រហមបន្តិចបន្តួចមិនអីទេ វាមិនប៉ះពាល់ដល់កូនទេ ថែមទាំងជួយឱ្យឈាមរត់ស្រួលទៀតផង"។

1. ផ្អែកលើអនុសាសន៍របស់អង្គការពិភពលោកក្នុងមេរៀន តើដំបូន្មានរបស់មិត្តភក្តិគាត់ត្រឹមត្រូវដែរឬទេ?

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

2. ចូរពន្យល់ពីផលប៉ះពាល់ដែលអាចកើតមានចំពោះគភ៌ (ទារកក្នុងផ្ទៃ) និងផ្តល់អនុសាសន៍ដ៏ល្អបំផុតសម្រាប់ស្ត្រីរូបនោះ។

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគគ្រោះថ្នាក់នៃការបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង និងបដិសេធជំនឿខុសឆ្គងពីការស្ទាងស្រវឹង។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. ព្រោះរាងកាយស្ត្រីផ្ទុកជាតិខ្លាញ់ច្រើនជាង និងមានជាតិទឹកតិចជាងបុរស**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **B. ធ្វើឱ្យពេលវេលាដើម្បីបញ្ចេញជាតិអាល់កុលពីរាងកាយយូរជាង...**

**សំណួរទី ៣៖**

- ១. **ពិត** (ហានិភ័យមហារីកដោះកើនឡើង)
- ២. **មិនពិត** (អាល់កុលអាចឆ្លងកាត់សុកទៅដល់ទារកបានយ៉ាងងាយ)
- ៣. **ពិត** (អង្គការពិភពលោកបញ្ជាក់ថាគ្មានកម្រិតសុវត្ថិភាពឡើយ)
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៤៖**

ចម្លើយត្រូវ៖ **A. មានមុខមាត់មិនប្រក្រតី ពិការផ្នែករាងកាយ និងមានអាការៈញៀនក្រោយពេលកើត**

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
  1. **ការវាយតម្លៃ៖** ដំបូន្មានមិត្តភក្តិមិនត្រឹមត្រូវ និងមានគ្រោះថ្នាក់បំផុត។
  2. **ការពន្យល់ និងអនុសាសន៍៖** ជាតិអាល់កុលអាចឆ្លងកាត់សុកទៅបំផ្លាញទារក ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដូចជា រលូតកូន កូនកើតមិនគ្រប់ខែ ឬពិការភាពរាងកាយ និងខួរក្បាល (ចង្កោមរោគសញ្ញាស្លាប់ដោយគ្រឿងស្រវឹង)។ អនុសាសន៍ល្អបំផុតគឺ «**មិនត្រូវទទួលទានគ្រឿងស្រវឹងទាល់តែសោះ**» ក្នុងកំឡុងពេលមានផ្ទៃពោះ ដើម្បីសុវត្ថិភាពទាំងស្រុងរបស់កូន។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាគ្រោះថ្នាក់ តែមិនបានបញ្ជាក់ពីការឆ្លងកាត់សុក ឬផលវិបាកជាក់លាក់ដូចជាការរលូតកូន ឬពិការភាព។
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ប្រធានបទទី ៣៧ : មាគ៌ាឆ្ពោះទៅរកការផ្តាច់គ្រឿងស្រវឹង និងការស្តារកម្លាំងចិត្ត

## អត្ថបទខ្លី៖ ជ័យជម្នះលើភាពញៀន




សុខាមានការបារម្ភពីពូរបស់គាត់ដែលតែងតែផឹកស្រាស្រវឹងជារៀងរាល់ថ្ងៃ។ ប៉ុន្តែថ្ងៃនេះ សុខាសប្បាយចិត្តណាស់ព្រោះពូបានសម្រេចចិត្តទៅមន្ទីរពេទ្យដើម្បីផ្តាច់ស្រា។

លោកគ្រូពេទ្យបានពន្យល់សុខាថា៖ «ការផ្តាច់ស្រាមិនមែនគ្រាន់តែការឈប់ផឹកភ្លាមៗដោយខ្លួនឯងនោះទេ ព្រោះរាងកាយអ្នកញៀនខ្លាំងអាចនឹងមានប្រតិកម្មគ្រោះថ្នាក់។ យើងត្រូវការ **ឱសថពិសេស** ដើម្បីជួយឱ្យរាងកាយពូកែសម្របខ្លួន និងការ **ប្រឹក្សាយោបល់** ដើម្បីពង្រឹងស្មារតីគាត់»។

សុខាបានសន្យាថានឹងនៅក្បែរផ្តល់កម្លាំងចិត្ត និងរៀបចំសកម្មភាពកម្សាន្តផ្សេងៗឱ្យពូ ដើម្បីកុំឱ្យពូមានអារម្មណ៍ឯកោ។ គ្រូពេទ្យបានបញ្ជាក់ថា៖ «ការតាំងចិត្តរបស់ពូ គឺជាម៉ាស៊ីន ចំណែកគ្រួសារ និងគ្រូពេទ្យ គឺជាអ្នកជួយរុញឱ្យម៉ាស៊ីននោះដើរទៅមុខ»។

## សំណួរទី ១៖ ការប្រើប្រាស់ឱសថក្នុងការផ្តាច់ស្រា

តើនរណាខ្លះដែលមានសិទ្ធិចេញវេជ្ជបញ្ជាឱ្យអ្នកញៀនគ្រឿងស្រវឹងប្រើប្រាស់ឱសថដើម្បីកាត់បន្ថយអាការៈញៀន?

☐A. មិត្តភក្តិ ឬសមាជិកគ្រួសារដែលធ្លាប់ញៀនស្រា។

☐B. តែខ្លួនអ្នកញៀនផ្ទាល់ដែលចង់ឈប់ផឹកស្រា។

☐C. គ្លីនិកឯកទេស ឱសថស្ថានឯកទេស និងគ្រូពេទ្យឯកទេសដែលមានការអនុញ្ញាត។

☐D. អ្នកលក់ដូរនៅតាមទីផ្សារសាធារណៈ។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ប្រភពត្រឹមត្រូវ និងច្បាប់ក្នុងការប្រើប្រាស់ឱសថផ្គាប់ស្រា។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ២៖ ទីតាំងសម្រាប់ការផ្តល់ប្រឹក្សា

តើការប្រឹក្សាផ្តាច់ការញៀនគ្រឿងស្រវឹងអាចធ្វើឡើងនៅកន្លែងណាខ្លះ?

☐A. នៅក្នុងហាងលក់គ្រឿងស្រវឹង ឬកន្លែងជប់លៀង។

☐B. នៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលគ្រឿងស្រវឹង។

☐C. នៅមន្ទីរពិសោធន៍គីមីវិទ្យាតែម្យ៉ាងគត់។

☐D. មិនចាំបាច់មានកន្លែងច្បាស់លាស់ទេ ព្រោះការញៀននឹងបាត់ទៅវិញដោយឯកឯង។

តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | កំណត់ទីតាំងស្ថាប័នដែលផ្តល់សេវាគាំទ្រការផ្តាច់គ្រឿងស្រវឹង។ |
| កម្រិតពុទ្ធិ | ចងចាំ |
| ទម្រង់សំណួរ | ពហុជ្រើសរើស |
| កម្រិតសមត្ថភាព | កម្រិត ១ |

## សំណួរទី ៣៖ អន្តរាគមន៍គ្រួសៗសម្រាប់អ្នកទើបចាប់ផ្តើម

តើ "អ្នកផ្តល់អន្តរាគមន៍គ្រួសៗ" (ដែលជាមនុស្សធម្មតាដែលបានទទួលការបណ្តុះបណ្តាល) បំពេញភារកិច្ចអ្វីខ្លះដើម្បីជួយអ្នកដែលទើបចាប់ផ្តើមប្រើប្រាស់គ្រឿងស្រវឹង? (ជ្រើសរើសបានលើសពីមួយ)

☐A. សាកសួរព័ត៌មាន និងផ្តល់ឯកសារអប់រំពីរបៀបកាត់បន្ថយ ឬបញ្ឈប់ការប្រើប្រាស់។

☐B. ចែកឱសថផ្តាច់ស្រាឱ្យអ្នកញៀនប្រើប្រាស់ដោយខ្លួនឯងនៅផ្ទះ។

☐C. ណាត់ជួបជាទៀងទាត់ដើម្បីតាមដាន និងបន្តជួយអន្តរាគមន៍។

☐D. បង្ខំឱ្យអ្នកញៀនផឹកកាហ្វេខ្មៅឱ្យបានច្រើនដើម្បីឱ្យឆាប់ស្វាង។

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | យល់ដឹងពីតួនាទី និងសកម្មភាពគាំទ្ររបស់អ្នកផ្តល់អន្តរាគមន៍សហគមន៍។ |
| កម្រិតពុទ្ធិ | យល់ដឹង |
| ទម្រង់សំណួរ | ពហុជ្រើសរើស (ជ្រើសរើសច្រើន) |
| កម្រិតសមត្ថភាព | កម្រិត ២ |

### សំណួរទី ៤៖ ការវាយតម្លៃលើប្រសិទ្ធភាពនៃការផ្តាច់ស្រា

សូមគូសសញ្ញា ☑ ក្នុងប្រអប់ "ពិត" ឬ "មិនពិត" ចំពោះការពណ៌នាខាងក្រោម៖

| ការពណ៌នា | ពិត | មិនពិត |
|---|---|---|
| ១. ការប្រើឱសថផ្តាច់ស្រានឹងមានប្រសិទ្ធភាពខ្ពស់ លុះត្រាតែប្រើគួបផ្សំជាមួយការតាំងចិត្តខ្ពស់របស់សាមីខ្លួន។ | ☐ | ☐ |
| ២. វិធីប្រឹក្សានីមួយៗមានប្រសិទ្ធភាពដូចៗគ្នាលើអ្នកញៀនគ្រប់រូប ដោយមិនបាច់ផ្លាស់ប្តូរឡើយ។ | ☐ | ☐ |
| ៣. អន្តរាគមន៍ត្រួសៗរយៈពេល ៥-៣០ នាទី អាចជួយឱ្យអ្នកទើបចាប់ផ្តើមផឹកស្រាដឹងពីវិធីជួយខ្លួនឯង។ | ☐ | ☐ |

### តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វាយតម្លៃកត្តាដែលជះឥទ្ធិពលដល់ជោគជ័យនៃការផ្តាច់គ្រឿងស្រវឹង។ |
| កម្រិតពុទ្ធិ | វិភាគ |
| ទម្រង់សំណួរ | ចម្លើយឆ្លាស់ |
| កម្រិតសមត្ថភាព | កម្រិត ៣ |

### សំណួរទី ៥៖ ការវិភាគស្ថានភាព និងការស្នើដំណោះស្រាយ (កម្រិតខ្ពស់)

បុរសម្នាក់ជាអ្នកញៀនស្រាពុំរ៉ៃ។ គាត់ចង់ឈប់ផឹកស្រាណាស់ ប៉ុន្តែគាត់ខ្លាចការទៅមន្ទីរពេទ្យ ហើយគាត់ក៏មិនចង់ឱ្យគ្រួសារដឹងដែរ។ គាត់សម្រេចចិត្តទិញ "ថ្នាំផ្តាច់ស្រា" តាមបណ្តាញសង្គមដែលគេអះអាងថា "ផឹកហើយនឹងឈប់ចង់ផឹកស្រាភ្លាមៗ" មកប្រើប្រាស់ដោយខ្លួនឯង។




1. ផ្អែកលើមេរៀន តើវិធីសាស្ត្ររបស់បុរសរូបនេះត្រឹមត្រូវ និងមានសុវត្ថិភាពដែរឬទេ?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

2. ចូរលើកឡើងនូវហេតុផលវិទ្យាសាស្ត្រ និងផ្តល់អនុសាសន៍ ៣ ចំណុចពីក្នុងមេរៀន ដើម្បីជួយឱ្យគាត់ផ្តាច់ស្រាបានជោគជ័យ និងមានសុវត្ថិភាព។

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

## តារាងបញ្ជាក់លក្ខណៈបច្ចេកទេស

| លក្ខណៈ | ការពិពណ៌នា |
|---|---|
| លទ្ធផលសិក្សា | វិភាគគ្រោះថ្នាក់នៃការប្រើឱសថដោយគ្មានវិជ្ជាបញ្ជា និងបង្កើតផែនការផ្តាច់ស្រាប្រកបដោយសុវត្ថិភាព។ |
| កម្រិតពុទ្ធិ | វាយតម្លៃ និងបង្កើតថ្មី |
| ទម្រង់សំណួរ | សំណួរចម្លើយវែង |
| កម្រិតសមត្ថភាព | កម្រិត ៥ |

# អត្រាកំណែ

**សំណួរទី ១៖**

ចម្លើយត្រូវ៖ **C. គ្លីនិកឯកទេស ឱសថស្ថានឯកទេស និងគ្រូពេទ្យឯកទេសដែលមានការអនុញ្ញាត**

**សំណួរទី ២៖**

ចម្លើយត្រូវ៖ **D. នៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលគ្រឿងស្រវឹង**

**សំណួរទី ៣៖**

ចម្លើយត្រូវ៖ **A និង C**

**សំណួរទី ៤៖**

- ១. **ពិត** (ការតាំងចិត្តជាកត្តាសំខាន់គួបផ្សំនឹងឱសថ)
- ២. **មិនពិត** (មេរៀនបញ្ជាក់ថាវិធីប្រឹក្សានីមួយៗមានប្រសិទ្ធភាពខុសៗគ្នាលើអ្នកញៀនម្នាក់ៗ)
- ៣. **ពិត** (អន្តរាគមន៍គ្រួសារជួយផ្តល់ព័ត៌មាន និងវិធីជួយខ្លួនឯង)
- *ត្រូវគូសត្រូវទាំងអស់ទើបបានពិន្ទុពេញ*

**សំណួរទី ៥៖**

- **ពិន្ទុពេញ** : ឆ្លើយត្រូវតាមលក្ខខណ្ឌពីរ៖
    1. **ការវាយតម្លៃ៖** មិនត្រឹមត្រូវ និងមិនមានសុវត្ថិភាពឡើយ។ ការប្រើឱសថផ្តាច់ស្រាត្រូវតែមានវេជ្ជបញ្ជាពីគ្រូពេទ្យឯកទេស។
    2. **អនុសាសន៍ ៣ យ៉ាង៖** ១. ត្រូវទៅពិភាក្សាជាមួយគ្រូពេទ្យឯកទេសដើម្បីទទួលបានវេជ្ជបញ្ជាឱសថត្រឹមត្រូវ។ ២. ស្វែងរកការផ្តល់ប្រឹក្សានៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលឱ្យបានទៀងទាត់។ ៣. ត្រូវមានការតាំងចិត្តខ្ពស់ និងស្វែងរកការគាំទ្រពីអ្នកផ្តល់អន្តរាគមន៍ ឬមនុស្សជុំវិញខ្លួន។
- **ពិន្ទុខ្លះ** : ឆ្លើយត្រូវថាគ្រោះថ្នាក់តែផ្តល់អនុសាសន៍មិនបានគ្រប់ចំនួនឬមិនផ្អែកលើខ្លឹមសារមេរៀន
- **គ្មានពិន្ទុ** : ឆ្លើយខុស ឬមិនឆ្លើយ។

# ឯកសារយោង


- Preah Sisowath NGS. (2022). *NGS, Preah Sisowath*. យកមកវិញពី NGS, Preah Sisowath: https://www.youtube.com/@ngspreahsisowath4702
- ឌូរសិក្សា. (2026). *Duraseksa*. យកមកវិញពី Duraseksa: https://sekhalay.duraseksa.gov.kh/subject/66
- អ.យ.ក. (2025). *សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី៧.* ភ្នំពេញ: គ្រឹស្ថានបោះពុម្ពផ្សាយ.